**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងរដ្ឋបាលខណ្ឌចំការមនបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ជាវ ដារ៉ា**

សាស្ត្រាចារ្យណែនាំ

លោក **ហៀង សាង**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal university of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងរដ្ឋបាលខណ្ឌចំការមនបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ជាវ ដារ៉ា**

សាស្ត្រាចារ្យណែនាំ
លោក **ហៀង សាង**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ ១៥

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ដារ ដារ៉ា ជានិស្សិតថ្នាក់បរិញ្ញាប័ត្រ ផ្នែករដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយគោរព និងសម្តែងការដឹងគុណ កត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

- **លោកឪពុក ឡេង ហាច និង អ្នកម្តាយ លី សុខគាង**

ដែលលោកបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សារូបកូន ដោយមិនឲ្យកូនខ្វះខាតអ្វីឡើយ។ លើសពីនេះទៅទៀតលោកទាំងពីរបានផ្គត់ផ្គង់នូវប្រាក់កាក់ឲ្យកូនបានរៀនសូត្រតាំងពីមត្តេយ្យ រហូតដល់ថ្នាក់ឧត្តមសិក្សាដើម្បីឲ្យកូនបានក្រេបយកនូវចំណេះវិជ្ជាដើម្បីជាប្រយោជន៍សម្រាប់ទៅថ្ងៃអនាគត។ ក្រៅពីនេះទៀត លោកទាំងពីរបានទូន្មានអប់រំកូនឲ្យខិតខំរៀនសូត្រ ដើម្បីក្លាយជាកូនល្អ សិស្សល្អ មិត្តល្អ ពលរដ្ឋល្អ និងជៀសវាងនូវអំពើមិនល្អទាំងឡាយទាំងពួងនៅក្នុងសង្គម។ រូបខ្ញុំមិនអាចបំភ្លេចបាននូវ គុណូបការៈ ដ៏ថ្លៃថ្លា និងធំធេងមិនអាចកាត់ថ្លៃបានឡើយ មានតែប្រាមដៃដប់លើកបន់ស្រន់ដល់វត្ថុស័ក្តិសិទ្ធិឲ្យជួយតាមថែរក្សាលោកទាំងទ្វេ ហើយខ្ញុំបាទនឹងតបស្នងសងគុណលោកទាំងពីរដោយការដឹងគុណជារៀងរហូតអស់មួយជីវិត។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរងព្រឹទ្ធបុរសព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំបង្ហាត់បង្រៀនផ្តល់នូវចំណេះដឹងដល់រូបខ្ញុំបាទចាប់តាំងពីឆ្នាំទី១ រហូតដល់ឆ្នាំទី៤ ជាពិសេស សូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **ហៀង សាង** ក្នុងការចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ការណែនាំ តម្រង់ទិស សម្របសម្រួល និងផ្តល់ដំបូន្មានល្អៗដល់ខ្ញុំដែលជាមូលដ្ឋានគំនិតដ៏សំខាន់ក្នុងការសរសេរប្រធានបទមួយនេះឲ្យលេចចេញជារូបរាង។

ជាទីបញ្ចប់ ខ្ញុំសូមជូនស្នាដៃ និងគុណតម្លៃទាំងឡាយ ដែលបានទទួលពីការសិក្សាស្រាវជ្រាវមួយនេះជូនចំពោះអស់លោកអ្នកដែលមានគុណ ដូចដែលខ្ញុំបានរៀបរាប់ខាងលើ។ យើងខ្ញុំសូមប្តេជ្ញាចិត្តថា នឹងយកនូវចំណេះដឹង បញ្ញា ស្មារតី កម្លាំងកាយចិត្ត ដែលមានទៅជួយសង្គមកម្ពុជាមួយនេះឲ្យសមនឹងការតបស្នងជួយជ្រោមជ្រែងដ៏មានតម្លៃរបស់អ្នកទាំងអស់គ្នា។ ជាមួយនឹងគ្នានេះដែរ ក៏សូមប្រសិទ្ធពរជ័យជូនដល់អស់លោកលោកស្រី ឲ្យទទួលនូវសុខសុភមង្គលទាំងផ្លូវកាយ និងផ្លូវចិត្តគ្រប់ពេលវេលាតរៀងទៅ។

# អារម្ភកថា

បន្ទាប់ពីឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈរយៈពេល៤ឆ្នាំ ចាប់ពីឆ្នាំ ២០១៨ ដល់ ២០២២ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជំនាន់ទី១៥ ក្រុម P៤C0៣ ខ្ញុំបានទទួលនូវចំនេះដឹង ក៏ដូចជាបទពិសោធន៍ជាច្រើនទាំងមុខជំនាញ និងចំណេះដឹងផ្នែកសង្គមផងដែរអំពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់ដែលបានបង្ហាត់បង្រៀនខ្ញុំ អស់ពីម្លាំងកាយ កម្លាំងចិត្តដែរធ្វើឲ្យខ្ញុំបានទទួលបានលទ្ធផលល្អមកដល់សព្វថ្ងៃនេះ។ ដូច្នេះហើយដើម្បីធ្វើការវាយតម្លៃលើចំណេះដឹងរបស់ខ្ញុំ រូបខ្ញុំបាទបានលើកយកនូវប្រធានបទមួយស្តីពី " ការគ្រប់គ្រងរដ្ឋបាលខណ្ឌចំការមនបច្ចុប្បន្ន" មកធ្វើជាការស្រាវជ្រាវសរសេរសារណាក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់ខ្ញុំ។

មូលហេតុដែលរូបខ្ញុំបាទ បានសម្រេចចិត្តលើកយកប្រធានបទមួយនេះមកសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយសារតែខ្ញុំយល់ឃើញថា ការគ្រប់គ្រងរដ្ឋបាល គឺជាវិស័យមួយសំខាន់ក្នុងចំណោមវិស័យផ្សេងៗ។ ដោយហេតុថាវិស័យនេះគឺជាគន្លងសម្រាប់ការគ្រប់គ្រងក្រសួងស្ថាប័ននានា ឲ្យមានការប្រព្រឹត្តិទៅដោយរលូន។ ដោយអនុលោមទៅតាម ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨ បានបង្កើតមានឡើងនូវសមូហភាពមូលដ្ឋាន ដែលជាដែនដីរដ្ឋបាលនៅជិតប្រជាពលរដ្ឋ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្តល់សេវាសាធាណៈ ក៏ដូចជា ដឹងច្បាស់ពីសុខទុក្ខរបស់ប្រជាពលរដ្ឋ។

ម៉្យាងវិញទៀត ខ្ញុំបានសង្កេតឃើញថា ឯកសារដែលខ្ញុំបានពីការសរសេរនេះនឹងក្លាយជាបច្ច័យមួយសម្រាប់កិច្ចការស្រាវជ្រាវដែលលោកសាស្ត្រាចារ្យបានដាក់ឲ្យ ឬយកទៅធ្វើជាឯកសារដើម្បីអានសម្រាប់ពង្រីកនូវចំណេះដឹងបន្ថែមទៀត។ ទន្ទឹមនេះផងដែរ រាល់ការលើកយកមកបង្ហាញ និងការបញ្ចេញទស្សនៈនៅក្នុងឯកសារនេះមុខជានឹងមានការខ្វះចន្លោះនៅត្រង់កន្លែងមួយជាក់ជាពុំខាន ដូច្នេះហើយ ខ្ញុំបាទរីករាយនឹងទទួលនូវរាល់ការរិះគន់ទាំងឡាយក្នុងន័យស្ថាបនាពីសំណាក់លោក លោកស្រី បណ្ឌិត សាស្ត្រាចារ្យ បញ្ញវន្ត និងមិត្តអ្នកអានទាំងអស់ ដើម្បីជាបទពិសោធន៍ និងជួយឲ្យខ្ញុំអភិវឌ្ឍ និងកែប្រែនូវរាល់កំហុសដែលខ្វះខាតទាំងប៉ុន្មានឲ្យបានល្អប្រសើរឡើងវិញ និងមានភាពពេញលេញ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ..... **១**

១. លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ១

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ..... ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ..... ២

៥. វិធីសាស្រ្តនៃការស្រាវជ្រាវ ..... ២

៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ..... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៣

**ជំពូកទី១**

**រំលឹកទ្រឹស្តី**

**១.១. និយមន័យ និងពាក្យគន្លឹះ** ..... ៥

១.១.១ និយមន័យរដ្ឋបាល ..... ៥

១.១.២ និយមន័យនៃពាក្យរដ្ឋបាលសាធារណៈ ..... ៥

១.១.៣ និយមន័យពាក្យគ្រប់គ្រង ..... ៧

**១.២ ប្រវត្តិរដ្ឋបាលនៅកម្ពុជា** ..... ៧

១.២.១ រដ្ឋបាលមុនអាណានិគមនិយមបារាំង ..... ៧

១.២.២ រដ្ឋបាលសម័យអាណានិគមនិយមបារាំង ..... ៩

១.២.៣ រដ្ឋបាលក្រោយអាណានិគមនិយមបារាំង ..... ៩

**១.៣ គោលការណ៍នៃការរៀបចំរដ្ឋបាល** ..... ១០

១.៣.១ មជ្ឈការ ..... ១០

១.៣.២ វិមជ្ឈការ ..... ១១

១.៣.៣ វិសហមជ្ឈការ ..... ១៣

**១.៤ អភិបាលកិច្ចល្អ** ..... ១៣

១.៤.១ ការណ៍អភិបាលកិច្ចល្អ ..... ១៣

## ជំពូកទី២

## ស្ថានភាពទូទៅរបស់ខណ្ឌចំការមន

**២.១ ទិដ្ឋភាពទូទៅក្នុងខណ្ឌចំការមន** ........ ២១

២.១.១ ប្រវត្តិរបស់សាលាខណ្ឌចំការមន ........ ២១

២.១.២ ស្ថានភាពភូមិសាស្ត្រ ........ ២១

២.១.៣ ស្ថានភាពប្រជាសាស្ត្រ ........ ២៣

**២.២ សន្តិសុខ និងសណ្តាប់ធ្នាប់ខណ្ឌចំការមន** ........ ២៣

២.២.១ សុវត្ថិភាពបុគ្គល ........ ២៤

២.២.២ សុវត្ថិភាពសម្ភារ ........ ២៥

២.២.៣ សុវត្ថិភាពចំណីអាហារ ........ ២៦

## ជំពូកទី៣

## តួនាទី និងការកិច្ចរដ្ឋបាលខណ្ឌចំការមន

**៣.១. ក្រុមប្រឹក្សាខណ្ឌចំការមន** ........ ២៨

៣.១.១ សិទ្ធិអំណាចក្រុមប្រឹក្សាខណ្ឌចំការមន ........ ២៨

៣.១.២ របៀបរបបការងាររបស់ក្រុមប្រឹក្សាខណ្ឌចំការមន ........ ២៩

៣.១.៣ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌចំការមន ........ ៣០

**៣.២ គណៈអភិបាលខណ្ឌចំការមន** ........ ៣២

៣.២.១ តួនាទីគណៈអភិបាលខណ្ឌចំការមន ........ ៣២

៣.២.២ របៀបរបបការងាររបស់គណៈអភិបាលខណ្ឌចំការមន ........ ៣៥

៣.៣ ទំនាក់ទំនងរវាងក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌ ........ ៣៧

**៣.៤ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខណ្ឌចំការមន** ........ ៣៨

៣.៤.១ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ........ ៤០

៣.៤.២ គណៈកម្មាធិការពិគ្រោះយោបលកិច្ចការនារី និងបច្ចេកទេស ........ ៤៥

៣.៤.៣ គណៈកម្មាធិការលទ្ធកម្ម ........ ៥០

**៣.៥ នាយករដ្ឋបាលសាលាខណ្ឌចំការមន** ........ ៥១

**៣.៦ ការិយាល័យចំណុះសាលាខណ្ឌចំការមន** ........ ៥៣

៣.៦.១ សាលាខណ្ឌចំការមន ........ ៥៣

៣.៦.២ របៀបរបបការងាររបស់ការិយាល័យចំណុះសាលាខណ្ឌចំការមន ..... ៥៩
**៣.៧ ទំនាក់ទំនងការងារ** ..... ៦០
៣.៧.១ ទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌជាមួយរដ្ឋបាលរាជធានី ..... ៦០
៣.៧.២ ទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌជាមួយរដ្ឋបាលសង្កាត់ ..... ៦១
៣.៧.៣ ទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត ..... ៦២
៣.៧.៤ ទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌជាមួយវិស័យឯកជន និងសង្គមស៊ីវិល ..... ៦២
**៣.៨.គណនេយ្យភាព** ..... ៦២
៣.៨.១. គណនេយ្យភាពចំពោះប្រជាពលរដ្ឋ ..... ៦២
៣.៨.២. គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន ..... ៦៣
៣.៨.៣. គណនេយ្យភាពផ្ទៃក្នុង ..... ៦៣

## ជំពូកទី៤

## បញ្ហាប្រឈម និងដំណោះស្រាយ

**៤.១ បញ្ហាប្រឈម** ..... ៦៥
**៤.២ ដំណោះស្រាយ** ..... ៦៦
៤.២.១ ការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលខណ្ឌចំការមន ..... ៦៦
៤.២.២ ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ..... ៦៧
៤.២.៣ ការរៀបចំហិរញ្ញវត្ថុ ..... ៦៨
៤.២.៤ ការផ្តល់សេវាសាធារណៈ ..... ៦៩
**សេចក្តីសន្និដ្ឋាន** ..... ៧០
**អនុសាសន៍** ..... ៧១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ការគ្រប់គ្រងរដ្ឋបាល គឺជាផ្នែកមួយដ៏សំខាន់បំផុតក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍ មិនថាប្រទេសអភិវឌ្ឍ ឬកំពុងតែអភិវឌ្ឍទេគឺត្រូវតែមានការគ្រប់គ្រងរដ្ឋបាល។ រីឯប្រទេសកម្ពុជាយើងវិញ គឺជាប្រទេសមួយដែលស្ថិតនៅក្នុងតំបន់អាស៊ាន និងជាប្រទេសដែលកំពុងអភិវឌ្ឍផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់គោលនយោបាយដើម្បីឲ្យប្រទេសមានសេដ្ឋកិច្ចរីកចម្រើនជឿនលឿន មានស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ និងដើម្បីឲ្យសមស្របទៅនឹងការវិវឌ្ឍរបស់សង្គមជាតិ ។ ម្យ៉ាងវិញទៀត នៅក្នុងពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំយកចិត្តទុកដាក់រកវិធីសាស្ត្រណាដែលមានប្រសិទ្ធភាពខ្ពស់ អាចផ្តល់ឲ្យមានសេវាសាធារណៈជូនប្រជាពលរដ្ឋឆាប់រហ័សមានភាពងាយស្រួល និងទាន់ពេលវេលា ដូច្នេះហើយរដ្ឋាភិបាលបានដាក់ឲ្យអនុវត្តនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដែលមានគោលដៅក្នុងការអភិវឌ្ឍចាក់គ្រឹះលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន និងលើកកម្ពស់សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ ការរៀបចំរដ្ឋបាលក្នុងប្រទេសកម្ពុជាបែងចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ហើយការបែងចែកនេះត្រូវទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

យោងតាមមាត្រា ៤ នៃច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨ បានកំណត់ថា ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ រាជធានីភ្នំពេញចែកជា ខណ្ឌ ខណ្ឌចែកជាសង្កាត់។

ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យមានប្រសិទ្ធភាព រាជធានីភ្នំពេញក៏បានបែងចែករចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់រាជធានី ខណ្ឌ និងសង្កាត់ផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើកំណែទម្រង់នូវប្រព័ន្ធរដ្ឋបាលដោយបានធ្វើប្រតិភូកម្មនូវមុខងារជាច្រើន និងជាបន្តបន្ទាប់ដល់រដ្ឋបាលថ្នាក់រាជធានី ដើម្បីអាចមានសមត្ថកិច្ចក្នុងការដោះស្រាយ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ ដើម្បីជាស្ពានឈានដល់ ការបកស្រាយលើប្រធានបទខាងលើឱ្យបានស៊ីជម្រៅ ក៏ដូចជាឲ្យមានភាពច្បាស់លាស់បន្ថែមទៀតនោះ រូបខ្ញុំបាទបានលើកយកចំណោទបញ្ហាមួយចំនួនដើម្បីមកធ្វើការបកស្រាយដែលបញ្ហាទាំងអស់នោះរួមមាន៖ តើសាលាខណ្ឌចំការមនមានរចនាសម្ព័ន្ធគ្រប់គ្រងដូចម្តេចខ្លះ? តើរចនាសម្ព័ន្ធ និងការអនុវត្តមុខងារ និងតួនាទីរបស់ក្រុមប្រឹក្សាថ្នាក់រាជធានីមានអ្វីខ្លះ ហើយមានទំនាក់ទនងអ្វីខ្លះនៅក្នុង ការអនុវត្តមុខងាររបស់ក្រុមប្រឹក្សា គណៈអភិបាល ក៏ដូចជាអង្គភាពពាក់ព័ន្ធ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺមានគោលបំណងនៅក្នុងការរួមចំណែកបង្កើននូវចំណេះដឹងដល់រូបខ្ញុំដែលបានធ្វើការសិក្សាស្រាវជ្រាវ និងចែករំលែកនូវចំណេះដឹងទាក់ទងនឹងរដ្ឋបាលខណ្ឌចំការមន ដែលរួមមានដំណើរការអនុវត្តការងារកិច្ចការរដ្ឋបាល ទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌ និងអង្គភាពចំណុះ ក៏ដូចជាអង្គភាពពាក់ព័ន្ធ ។

គោលបំណងនៃសារណានេះ ផ្តោតសំខាន់ទៅលើចំណុចមួយចំនួនដូចជាៈ

- សិក្សាអំពីដំណើរការទូទៅនៃការអនុវត្តកិច្ចការរដ្ឋបាលថ្នាក់ខណ្ឌចំការមន
- សិក្សាអំពីតួនាទី ភារកិច្ច និងមុខងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌចំការមន
- សិក្សាអំពីទំនាក់ទំនងផ្សេងៗរបស់រដ្ឋបាលខណ្ឌចំការមន
- សិក្សាអំពីបញ្ហាប្រឈម និងដំណោះស្រាយរបស់រដ្ឋបាលខណ្ឌចំការមន ហើយការស្រាវជ្រាវនេះដែរ ផ្តោតទៅលើការវិភាគការគ្រប់គ្រងរដ្ឋបាលថ្នាក់ខណ្ឌ និងយុទ្ធសាស្ត្រពាក់ព័ន្ធដើម្បីស្វែងរកចំណុចខ្វះខាតមួយចំនួន ដំណោះស្រាយមួយចំនួនរបស់រដ្ឋបាលខណ្ឌ រួចធ្វើការសន្និដ្ឋាន និងចូលរួមបន្ថែមជាការផ្តល់ជាអនុសាសន៍មួយចំនួននៅក្នុងនាមជានិស្សិត។ ព្រមទាំងបានយល់ដឹងកាន់តែច្បាស់លាស់ពីការគ្រប់គ្រងរដ្ឋបាលខណ្ឌ ហើយវាក៏ជាឯកសារមួយសម្រាប់តម្កល់ទុកក្នុងសាកលវិទ្យាល័យ ដើម្បីឲ្យនិស្សិតជំនាន់ក្រោយបានធ្វើការសិក្សាបន្ទាប់បន្សំ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

រាល់ស្នាដៃនៃការស្រាវជ្រាវ គឺសុទ្ធតែមានគោលបំណងសំខាន់ៗនៅក្នុងការស្រាវជ្រាវ។ វិសាលភាពដែលយោងទៅតាមកម្រិត និងរយៈពេលនៃការស្រាវជ្រាវប្រធានបទ ការគ្រប់គ្រងរដ្ឋបាលខណ្ឌចំការមនបច្ចុប្បន្ន។ ការស្រាវជ្រាវនេះ ផ្តោតទៅលើការអនុវត្តមុខងារ និងតួនាទីរបស់ក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌចំការមន ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌចំការមន បញ្ហាប្រឈមនានានៃការអនុវត្តមុខងារ និងគោលនយោបាយ និងយុទ្ធសាស្ត្រដែលបានចេញដោយរាជរដ្ឋាភិបាល ក៏ដូចជាសាលាខណ្ឌចំការមនក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែរកើតមានឡើង។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដោយសារតែស្ថានភាពនៃការរីករាលដាលខ្លាំងនៃជំងឺកូវីដ១៩ នៅទូទាំងប្រទេសកម្ពុជា ជាពិសេសរាជធានីភ្នំពេញ ជាមូលហេតុដែរធ្វើឲ្យខ្ញុំពិបាកក្នុងការប្រមូលឯកសារ និងទិន្នន័យពាក់ព័ន្ធនិងការគ្រប់គ្រងរដ្ឋបាលខណ្ឌចំការមនបច្ចុប្បន្ន។

សម្រាប់ការសិក្សាស្រាវជ្រាវប្រធានបទ ការគ្រប់គ្រងរដ្ឋបាលខណ្ឌចំការមនបច្ចុប្បន្ន នេះគឺខ្ញុំធ្វើការស្វែង

យល់ពីបណ្ដាឯកសារនានា លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធដូចជា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស កម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ របាយការណ៍បូកសរុបលទ្ធផលការងាររបស់សាលាខណ្ឌចំការមន និងតាមប្រព័ន្ធអ៊ីនធឺណែត គេហទំព័រផ្សេងៗមួយចំនួន។ បន្ទាប់មកគឺខ្ញុំបានប្រមូលផ្តុំឯកសារ និងពត៌មានដែរប្រមូលបានយកមកវិភាគ និងសរសេរជាសារណាបញ្ចប់ការសិក្សានេះឡើង។

## ៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាពីប្រធានបទនេះពិតជាមានសារៈសំខាន់ ផ្អែកលើចំណុចមួយចំនួនដូចខាងក្រោម៖

- អ្នកអានគ្រប់រូបអាចដឹងឱ្យកាន់តែច្បាស់អំពី **"ការគ្រប់គ្រងរដ្ឋបាលខណ្ឌចំការមនបច្ចុប្បន្ន"** ដែលរាល់សកម្មភាពទាំងអស់នេះសុទ្ធសឹងតែជាអ្វីដែលប្រជាជនគ្រប់រូបគួរតែដឹង។
- ការសិក្សាលើប្រធានបទនេះមានសារៈសំខាន់ដល់ខ្ញុំផងដែរ ដោយហេតុថាការសិក្សាលើប្រធានបទនេះបានអនុញ្ញាតឱ្យយើងបានស្វែងយល់ពីខ្លឹមសារនៃប្រធានបទ និងព័ត៌មានបន្ថែមដែលបានមកពីការស្រាវជ្រាវ និងបានជាបទពិសោធន៍ក្នុងការសរសេរ និងបំណិនបន្ថែមនៅក្នុងជីវិត។ ម្យ៉ាងវិញទៀតការសរសេរអត្ថបទសិក្សាស្រាវជ្រាវនេះ គឺជាគោលបំណងរបស់ខ្ញុំតាំងពីថ្នាក់មូលដ្ឋានមក ហេតុដូចនេះហើយ ការសរសេរនេះគឺមានអត្ថន័យយ៉ាងជ្រៅជ្រះសម្រាប់ខ្ញុំដោយមិនមែនត្រឹមតែជាកាតព្វកិច្ចក្នុងការបញ្ចប់ការសិក្សាប៉ុណ្ណោះទេ។
- ជាមួយគ្នាផងដែរ ការស្រាវជ្រាវមួយនេះបានផ្តល់នូវពុទ្ធិតាមរយៈការស្វះស្វែងទាញយកប្រភពព័ត៌មានដកស្រង់នូវខ្លឹមសារល្អៗដែលទាក់ទងទៅនឹង **"ការគ្រប់គ្រងរដ្ឋបាលខណ្ឌចំការមនបច្ចុប្បន្ន"** ព្រមទាំងប្រភពនៃលិខិតបទដ្ឋានគតិយុត្តនានា ជាពិសេសនោះកិច្ចការមួយនេះអាចឲ្យខ្ញុំបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។
- ទន្ទឹមនឹងនេះ កិច្ចការមួយនេះក៏អាចចូលរួមចំណែកក្នុងការផ្សព្វផ្សាយអំពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធព្រមទាំងស្នាដៃ និងសមិទ្ធផលផ្សេងៗដែលសម្រេចកន្លងមកលើគ្រប់ផ្នែករួមទាំងសមិទ្ធផលសំខាន់ៗពាក់ព័ន្ធនឹងការងារការកែទម្រង់រដ្ឋបាលសាធារណៈដល់សាធារណជនឲ្យបានដឹង។ ក្រៅពីនេះកិច្ចការមួយនេះនឹងផ្តល់ជាប្រយោជន៍ដល់អ្នកសិក្សាជំនាន់ក្រោយសម្រាប់យកទៅសិក្សា និងសិក្សាស្រាវជ្រាវបន្តផងដែរ។

## ៧. រចនាសម្ពន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៣ កថាខណ្ឌ និង ៤ ជំពូកដូចខាងក្រោម

- សេចក្តីផ្តើម
- ជំពូកទី១ ៖ ការរំលឹកទ្រឹស្តី

- ជំពូកទី២ ៖ ស្ថានភាពទូទៅខណ្ឌចំការមន
- ជំពូកទី៣៖ តួនាទី និងភារកិច្ចរបស់រដ្ឋបាលខណ្ឌចំការមន
- ជំពូកទី៤៖ បញ្ហាប្រឈម និងដំណោះស្រាយ
- សេចក្ដីសន្និដ្ឋាន
- អនុសាសន៍
- ឧបសម្ព័ន្ធ

# ជំពូកទី១
# រំលឹកទ្រឹស្តី

# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១ និយមន័យ និងពាក្យគន្លឹះ

### ១.១.១ និយមន័យរដ្ឋបាល

មុននឹងឈានទៅដល់ការយល់ដឹងនូវអ្វីដែលហៅថាអំណាចរដ្ឋបាលសាធារណៈ យើងគប្បីយល់នូវពាក្យ " រដ្ឋបាល" "រដ្ឋបាលសាធារណៈ " ជាមុនសិន ។

ពាក្យថា "រដ្ឋបាល" មានប្រភពមកពីពាក្យថា " រដ្ឋ និងបាល" រដ្ឋ មានន័យថា បុរី ឬនគរ។ រដ្ឋបាល មានន័យថា ជាការមើលខុសត្រូវថែរក្សា ឬការគ្រប់គ្រងដូច្នេះយើងអាចនិយាយបានថារដ្ឋបាលគឺជាការគ្រប់គ្រង នគរ ឬរដ្ឋ។

ប៉ុន្តែបើតាមអត្ថន័យទូទៅដែលជាការអនុវត្តជាក់ស្តែងនោះរដ្ឋបាលមានអត្ថន័យសំខាន់ពីរយ៉ាង៖

- ន័យជាអង្គការ សំដៅលើការគ្រប់គ្រងលើការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពមួយ។ ឧទាហរណ៍ ក្រសួងមហាផ្ទៃ។
- ន័យជាសកម្មភាពកិច្ចការរដ្ឋបាលរបស់ក្រសួង ឬស្ថាប័ន។

រដ្ឋបាល គឺជាសកម្មភាពមួយដែលបម្រើការរស់នៅរាល់ថ្ងៃជាប្រចាំ ពោលគឺសកម្មភាពបម្រើប្រយោជន៍ទាំងឡាយណាដែលទាក់ទងទៅនឹងការរស់នៅ ឬតម្រូវការជាប្រចាំរាល់ថ្ងៃរបស់មនុស្សទូទៅក្នុងសង្គម។

រដ្ឋបាល មានបេសកកម្មបម្រើឲ្យផលប្រយោជន៍សាធារណៈ ហើយមានលក្ខណៈជាប្រចាំនោះគឺមានន័យថាបម្រើផលប្រយោជន៍ក្នុងការរស់នៅជាប្រចាំរាល់ថ្ងៃ គេអាចឲ្យនិយមន័យជាសង្ខេបបានថា៖[1]

ក. រដ្ឋបាល គឺជាម៉ាស៊ីនដែលប្រមូលផ្តុំចូលគ្នា (គោលនយោបាយ លិខិតបទដ្ឋាន ប្រព័ន្ធរចនាសម្ព័ន្ធ អង្គការចាត់តាំងបុគ្គលិក...) ដែលផ្តល់ជាប្រាក់ដោយថវិការដ្ឋ ហើយមានការទទួលខុសត្រូវក្នុងការគ្រប់គ្រង មានគោលដៅឆ្ពោះទៅរកការងារទាំងឡាយរបស់រដ្ឋាភិបាល មានការធ្វើអន្តរសកម្មភាពជាមួយភ្នាក់ងារពាក់ព័ន្ធនានា ដែលមាននៅក្នុងរដ្ឋសង្គម ក៏ដូចជាបរិស្ថានដែលមាននៅខាងក្រៅផ្សេងៗទៀត។

ខ. ជាការគ្រប់គ្រង និងការអនុវត្តគ្រប់ប្រភេទនៃសកម្មភាពរបស់រដ្ឋាភិបាល គឺមានការពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិនានា និងសេចក្តីសម្រេចចិត្តដែលធ្វើឡើងដោយរដ្ឋាភិបាល និងគ្រប់គ្រងទៅលើបញ្ញត្តិស្តីពីសេវាសាធារណៈ។

### ១.១.២ និយមន័យនៃពាក្យរដ្ឋបាលសាធារណៈ

[1]UNDP Practice: Public Administration Reform

ចំណែកឯពាក្យ **រដ្ឋបាលសាធារណៈ** មានន័យដូចខាងក្រោម ៖

- ការឲ្យនិយមន័យទៅលើពាក្យ **រដ្ឋបាលសាធារណៈ** មានច្រើន និងមានលក្ខណៈស្មុគស្មាញដោយផ្អែកទៅប្រព័ន្ធលើពិភពលោកយើងនេះ ជាពិសេសនៅក្នុងការគ្រប់គ្រងរដ្ឋបាលនៃប្រព័ន្ធច្បាប់ Common Law និង Civil Law។ ទស្សនៈវិទូខាងច្បាប់មួយចំនួនបានឲ្យនិយមន័យខុសប្លែកៗពីគ្នាដូចជា៖

- លោក រ៉ូល ហ្គូសមេន (Raul Guzment) យល់ថា ទីណាមានរដ្ឋាភិបាលទីនោះត្រូវមានរដ្ឋបាលសាធារណៈ មានន័យថារដ្ឋបាលសាធារណៈ គឺជាកិច្ចសហប្រតិបត្តិការរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាលដើម្បីសម្រេចបានគោលដៅអ្វីមួយក្នុងការបម្រើផលប្រយោជន៍សាធារណៈ។

- លោក រ៉ូប៊ីត ព្រីសធូស (Robert Presthus) យល់ថា រដ្ឋបាលសាធារណៈ គឺជាទិដ្ឋភាពនៃការគ្រប់គ្រងដែលធ្វើឡើង ដោយភ្នាក់ងារផ្លូវការរបស់រដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់។ លើសពីនេះទៅទៀត កាលណាគេនិយាយពីពាក្យ រដ្ឋបាលសាធារណៈ គឺចង់និយាយសំដៅទៅលើរដ្ឋបាល ឬរាជការ។

- បើផ្អែកតាមការឲ្យនិយមន័យ នៃរដ្ឋបាលសាធារណៈនៅក្នុងនីតិរដ្ឋបាលវិញវាមានន័យពីរយ៉ាងគឺ៖ ទីមួយតាមមុខងារ ឬសកម្មភាព និងទីពីរន័យតាមអង្គការ។ ន័យទាំងពីរនេះអាចប្រើបានទាំងវិស័យឯកជន និងវិស័យសាធារណៈ។ ឧទាហរណ៍ កិច្ចការរដ្ឋបាលក្រុមហ៊ុនម៉ាស៊ីនកិនស្រូវ (វិស័យឯកជន) កិច្ចការរដ្ឋបាលរបស់ក្រសួងពាណិជ្ជកម្ម (វិស័យសាធារណៈ)។ មុខងាររដ្ឋបាលសំដៅទៅលើការបម្រើដែលមានប្រភពដើមចេញពីភាសាឡាតាំង Minister មានន័យថា បាវបម្រើ។ មុខងាររដ្ឋបាលការពីសម័យចក្រភពរ៉ូម៉ាំងជាមុខងារអនុវត្តច្បាប់ (នីតិប្រតិបត្តិ)។ នាពេលបច្ចុប្បន្ននេះរដ្ឋបាលសាធារណៈលែងមានមុខងារនៅក្នុងការធ្វើសេចក្ដីសម្រេចផ្សេងៗ។

តាមន័យមុខងាររដ្ឋបាលសាធារណៈ គឺជាសកម្មភាពក្នុងការបំពេញសេចក្ដីត្រូវការរបស់សមូហភាព ឬផលប្រយោជន៍រួមលើកលែងតែសកម្មភាពរបស់នីតិប្បញ្ញត្តិ និងតុលាការដែលមានរបបគតិយុត្តផ្ទាល់ខ្លួន។

រីឯតាមន័យអង្គការវិញ រដ្ឋបាលសាធារណៈ គឺជាសកម្មភាពរបស់អង្គការ ដែលមានតួនាទីបម្រើផលប្រយោជន៍ទូទៅទោះបីជាអង្គការនោះមានលក្ខន្តិកៈបែបណាក៏ដោយ (អង្គការមានលក្ខន្តិកៈខុសគ្នា) ឧទាហរណ៍ បុគ្គលសាធារណៈ (រដ្ឋ គ្រឹះស្ថានសាធារណៈ...) បុគ្គលឯកជន ក្រុមហ៊ុន សហគមន៍អង្គការ..) និងគណៈវិជ្ជាជីវៈ ( គណៈមេធាវី...)។

ម្យ៉ាងវិញទៀត គេបានឲ្យនិយមន័យរដ្ឋបាលសាធារណៈ ដោយផ្អែកទៅលើនិយមន័យបែបនយោបាយ តាមច្បាប់ តាមការគ្រប់គ្រង និងតាមអាជីព។

- តាមបែបច្បាប់ រដ្ឋបាលសាធារណៈជាច្បាប់ដែលកំពុងចូលជាធរមាន( កំពុងអនុវត្ត)
- តាមការគ្រប់គ្រង រដ្ឋបាលសាធារណៈជាសិល្បៈនៃការគ្រប់គ្រងនៅក្នុងរដ្ឋាភិបាល ។

- ចំណែកឯតាមន័យអាជីពវិញ រដ្ឋបាលសាធារណៈ ជាប្រភេទនៃអាជីពមួយ។
- តាមបែបនយោបាយ រដ្ឋបាលសាធារណៈ គឺជាជំហាននៃការធ្វើគោលនយោបាយសាធារណៈ។

### ១.១.៣ និយមន័យពាក្យគ្រប់គ្រង

សំដៅលើសកម្មភាពជាច្រើនផ្សេងៗ ដែលគេប្រើប្រាស់ដើម្បីដឹកនាំនៅក្នុងគ្រួសារ កុលសម្ព័ន្ធ ក្រុមហ៊ុន ស្ថាប័ន រដ្ឋ ប្រទេស តំបន់ ឬពិភពលោកទាំងមូល ដើម្បីសម្រេចបាននូវគោលបំណងជាក់លាក់មួយចំនួន។ ដោយសារចំនួនបុគ្គលិកច្រើន ការគ្រប់គ្រងកាន់តែមានភាពស្មុគស្មាញទៅតាមទំហំនៃស្ថាប័ន រចនាសម្ព័ន្ធមានភាពស្មុគស្មាញ បច្ចេកវិទ្យាខ្ពស់ កិច្ចសហប្រតិបត្តិការទូលំទូលាយ និងភាពផ្សេងគ្នានៃវប្បធម៌ការងារ ។ល។ ការគ្រប់គ្រងត្រូវការជំនាញ និងចំណេះដឹងជាច្រើនដូចជា៖ ការស្វែងយល់ពីអង្គការ វិធីសាស្រ្ត និងបែបបទគ្រប់គ្រង ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ ភាពជាអ្នកដឹកនាំ ការត្រួតពិនិត្យ លើការគ្រប់គ្រងសវនកម្មគណនេយ្យ និងការវាយតម្លៃការងារគោលនយោបាយ ក្រមសីលធម៌ការងារ ច្បាប់ការងារ និងវប្បធម៌ផ្សេងៗនៃការងារ។ល។ ជំនាញ និងចំណេះដឹងខាងលើអាចទទួលបានតាមការសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាផ្សេងៗ បទពិសោធន៍ការងារ សិក្ខាសាលា ការប្រឹក្សាយោបល់ និងវគ្គបណ្ដុះបណ្ដាលជាដើម។

## ១.២ ប្រវត្តិរដ្ឋបាលនៅកម្ពុជា

យើងនឹងធ្វើការសិក្សាដោយត្រួសៗពីប្រវត្តិសាស្រ្តខ្មែរ ដើម្បីស្វែងយល់អំពីរបបនៃការគ្រប់គ្រងរដ្ឋបាលខ្មែរតាំងពីជំនាន់ដើម (សម័យមុនបារាំងចូលស្រុក) រហូតដល់សម័យបច្ចុប្បន្ននេះ។

### ១.២.១ រដ្ឋបាលមុនអាណានិគមនិយមបារាំង

គឺជារបបរាជានិយមដែលព្រះមហាក្សត្រក្ដោបអំណាចទាំងអស់ដោយផ្ទាល់តែមួយអង្គឯង ជាពិសេសអំណាចនយោបាយ និងអំណាចរដ្ឋបាល។ ព្រះមហាក្សត្រមិនធ្វើច្បាប់ដោយផ្ទាល់ព្រះអង្គទេ គឺទ្រង់យកច្បាប់ដែលចេញពីគម្ពីរវេទ និងទំនៀមទម្លាប់មកប្រតិបត្តិតែម្ដង។ ព្រះមហាក្សត្រចេញព្រះរាជក្រឹត្យ បញ្ជាតែក្នុងវិស័យរដ្ឋបាល និងក្នុងនីតិវិធីតុលាការខ្លះតែប៉ុណ្ណោះ។ ព្រះអង្គទ្រង់ធ្វើសវនាការកិច្ចការរដ្ឋបាល កាលសម័យយុគកណ្ដាល (Moyen Age) ពីរដងក្នុងមួយថ្ងៃ[2]។ ព្រះអង្គក៏ជាចៅក្រមផងដែរ កាលសម័យនោះព្រះមហាក្សត្រត្រូវតែដឹកនាំចំបាំងដោយផ្ទាល់ព្រះអង្គទើបសមជាមហាក្សត្រ ពីព្រោះព្រះអង្គត្រូវធ្វើគំរូដល់មេទ័ពផ្សេងទៀតដែលលោកជាមេបញ្ជាការកំពូលនោះ។ ព្រះអង្គទ្រង់ជាអធិបតីនៃសេនាបតីសភាដែលមានសមាសភាពដូចតទៅៈ

-សេនាបតី" ឧកញ៉ា ឬសម្ដេច" ឥឡូវយើងហៅថា នាយករដ្ឋមន្រ្តី

-សេនាបតី " ឧកញ៉ា យោមរាជ" ឥឡូវយើងហៅថា រដ្ឋមន្រ្តីក្រសួងយុត្តិធម៌

-សេនាបតី " ឧកញ៉ាវាំង" ជារដ្ឋមន្រ្តី នៃព្រះបរមរាជវាំង និង ហិរញ្ញវត្ថុ

[2] កំណត់ហេតុរបស់សាស្រ្តាចារ្យចិន លោកជីតាហ្វាន់ ឆ្នាំ១២៦៩

-សេនាបតី "ឧកញ៉ា ឬសម្តេចចក្រី" ជារដ្ឋមន្ត្រីខាងដឹកជញ្ជូនតាមជើងគោក និងខាងកងទ័ព

-សេនាបតី " ឧកញ៉ា ក្រឡាហោម" ជារដ្ឋមន្ត្រី ខាងដឹកជញ្ជូនតាមផ្លូវទឹកសមុទ្រ សេនាបតីមានន័យ ដូចយើងឥឡូវដែលហៅថា "រដ្ឋមន្ត្រី" ចំណែកងសក្តិជា " ឧកញ៉ា ឬសម្តេច" គឺជាយសដែលព្រះមហាក្សត្រប្រទានបន្ថែម។ គោរមងារ " សម្តេច" ធំជាង " ឧកញ៉ា"។

ការរៀបចំរដ្ឋបាលដែនដី គឺមានៈ[3]

**ក. ដី** ដែលជាអតីតរាជាណាចក្រនៃប្រទេសដែលស្តេចខ្មែរវាយយកមកចំណុះរួមបញ្ចូល យកជាដីខ្មែរតែម្តង។ តាំងពីបរាជ័យនៅលង្វែកកាលពីក្នុងឆ្នាំ ១៥៩៣ មកឯកសារសំខាន់ៗបាត់អស់ ហេតុដូចនេះ យើងពុំអាចដឹងដោយច្បាស់ថាដីនោះមានចំនួនប៉ុន្មានពិតប្រាកដទេ។ យើងមិនដឹងច្បាស់ថាមានខេត្តចំនួន ៩០ ឬ ១០១ខេត្តទេ ពីព្រោះវាទៅជារឿងព្រេងអស់ទៅហើយ ដោយសារការរលំរលាយនៃបន្ទាយលង្វែក។ ស្តេចដែលត្រូវកាន់កាប់ដីនោះគេហៅថាស្តេចក្រាញ់ ដែលមានអំណាចតែងតាំង ឬដេញចោលមន្ត្រីទាំងអស់ដែលនៅក្នុងដីនោះ។ ស្តេចក្រាញ់មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ តាំងពីពាក់កណ្តាលសតវត្សទី ១៩ មកព្រះបាទអង្គឌួង (សោយរាជ្យ ១៨៤៥ ដល់ ១៨៦០) បានលុបចោលស្តេចក្រាញ់ជាបន្តបន្ទាប់មកលើការកាន់កាប់ដីទាំងនោះ និងដកអំណាចអស់ពីស្តេចក្រាញ់ឲ្យនៅសល់តែងារប៉ុណ្ណោះ។

**ខ.មឿង** គឺជាការបែងចែករដ្ឋបាលដែនដី។ មន្ត្រីដែលគ្រប់គ្រងកាន់កាប់មឿងក្នុងនាមនៃព្រះមហាក្សត្រគេហៅថាចៅមឿង ព្រះបាទអង្គឌួងក្រោយមកព្រះអង្គមិនចង់ឲ្យមានឈ្មោះមឿងដែលជាឈ្មោះសៀម ព្រះអង្គក៏ឲ្យផ្លាស់ឈ្មោះ ហើយហៅថា ខេត្តវិញ។ ដូច្នេះឈ្មោះ ខេត្ត កើតពីសម័យព្រះអង្គឌួងហើយនៅជាប់រហូតដល់សព្វថ្ងៃនេះ។ នៅឆ្នាំ១៨៨៤ មាន ៥៧ ខេត្ត។

**គ.ស្រុក** ជាឈ្មោះមួយដែលខ្មែរទូទៅហៅសម្រាប់សម្គាល់ភូមិកំណើតរបស់ខ្លួនកាលមុន សម័យបារាំងចូលមក គឺមិនមែនជាមណ្ឌលរដ្ឋបាលឡើយ។ ស្រុកនេះជាភូមិឥឡូវយើងហៅថាឃុំ កើតឡើងពីគ្រួសារមួយ ឬច្រើន ហេតុដូច្នេះបានជាជួនកាលគេឲ្យឈ្មោះ ភូមិ ស្រុក។

កាលសម័យនោះ កាលណារាស្ត្រនិយាយថា ចៅហ្វាយស្រុក គាត់ចង់និយាយចៅហ្វាយខេត្តវិញទេ។ ពួកចាស់ៗក្នុងស្រុកជំនុំគ្នាជាក្រុមជំនុំហើយចាត់អ្នកក្នុងចំណោមជនណា ដែលមានវ័យនៅក្មេងជាងគាត់ហើយដែលមានបញ្ញាឆ្លាតវាងវៃធ្វើការឲ្យស្រុកខ្លួន គេហៅមេស្រុក។ ដូច្នេះតាមប្រវត្តិសាស្ត្រ មេស្រុកគឺជាអ្នកជំនួយការតែប៉ុណ្ណោះ។

ក្រោយមកបញ្ចូលក្នុងជំនុំរបស់ស្រុក នូវអតីតមន្ត្រី អាចារ្យវត្ត អ្នកប្រាជ្ញអក្សរសាស្ត្រដើម្បីជួយគិតការងារ។ គេ

[3] សៀវភៅរដ្ឋបាលសាធារណៈ សាស្ត្រាចារ្យ កេត ឧត្តម ឆ្នាំ២០១៣

ឲ្យឈ្មោះក្រុមនោះថាក្រុមពញា ហើយពួកនេះធ្វើការឥតបៀវត្សអ្វីទេ។ ក្រុមពញានេះបានបង្កើតភ្នាក់ងារជំនួយមេស្រុក ដែលគេហៅថា ជំទប់។ ហើយជំទប់ក៏អាចរកស្មៀនឲ្យជួយសរសេរ ឬធ្វើការងារផ្សេងៗបានដែរ។ គេទាំងអស់គ្នាធ្វើការគ្មានប្រាក់ខែទេពីព្រោះពុំទាន់មានការបង្កើតលុយចាយនៅឡើយ គេទទួលបានអំណោយជារង្វាន់ ដូចជាអង្ករ ត្រី។ ព្រះបាទអង្គឌួងទ្រង់បានបង្កើតប្រាក់ឲ្យចាយនៅក្នុងពាក់កណ្តាលសតវត្សទី១៩។

**១.២.២ រដ្ឋបាលសម័យអាណានិគមនិយមបារាំង**

យើងដឹងហើយថា បារាំងបានធ្វើសន្ធិសញ្ញាមួយនៅឆ្នាំ ១៨៦៣ ដាក់ប្រទេសកម្ពុជា ឲ្យនៅក្រោមអាណាព្យាបាល (Protectorate) របស់ប្រទេសបារាំង។ ម្ភៃឆ្នាំក្រោយសន្ធិសញ្ញាឆ្នាំ ១៨៦៣ គឺនៅថ្ងៃទី ១៧ ខែ មិថុនា ១៨៨៤ សន្ធិសញ្ញាមួយទៀត ដែលបារាំងបានបង្ខំឲ្យព្រះបាទនរោត្តមបានចុះព្រះហស្តលេខាទាំងក្តៅក្រហាយនោះ បានធ្វើឲ្យប្រទេសខ្មែរក្លាយទៅជាប្រទេសមួយស្ថិតនៅក្រោមអាណានិគមបារាំង ថ្វីបើគេសរសេរជាផ្លូវការថាអាណាព្យាបាលក៏ដោយ។ សេនាបតីសភាត្រូវប្រជុំក្រោមអធិបតីរបស់លោក Resident Superieur កិច្ចប្រជុំលែងនៅក្រោមព្រះរាជាធិបតីរបស់មហាក្សត្រខ្មែរដូចកាលពីដើមទៀតឡើយ។

ក្នុងវិស័យរដ្ឋបាលបារាំងបានយកគំនូររចនាសម្ព័ន្ធរបស់បារាំង ដែលបានអនុវត្តនៅប្រទេសវៀតណាមយកមកចម្លងដាក់ទាំងស្រុងនៅប្រទេសខ្មែរ នៅត្រួតពីលើចៅហ្វាយខេត្តខ្មែរមានលោក Resident បារាំងម្នាក់នៅគ្រប់ខេត្ត Resident នេះមានអំណាចខ្លាំងណាស់លើមន្ត្រីទាំងអស់ លើចៅហ្វាយខេត្តខ្មែរទៀត។ ក្នុងខេត្តនីមួយៗមានចែកជា arrondissements (ដែលយើងហៅរហូតដល់សព្វថ្ងៃនេះថា ស្រុក) និងជា Communes ( ដែលយើងហៅថា ឃុំ)។

**១.២.៣ រដ្ឋបាលក្រោយអាណានិគមនិយមបារាំង**

ក្រោយពីបានទទួលឯករាជ្យមកដល់ឆ្នាំ ១៩៧៥ បារាំងបានកាន់កាប់ប្រទេសខ្មែរជាង ៩០ឆ្នាំទើបសុខចិត្តប្រគល់ឲ្យខ្មែរនូវឯករាជ្យភាពជាតិវិញ ដោយសាស្នាព្រះហស្ត ព្រះបាទនរោត្តមសីហនុព្រះមហាក្សត្រខ្មែរ និងដោយសារការរួមសាមគ្គីរបស់ប្រជាពលរដ្ឋខ្មែរ ប្រកបដោយសេចក្តីប្តេជ្ញាចិត្តយ៉ាងមុតមាំ។ បារាំងដកចេញទៅមែនតែអ្វីៗដែលបារាំងបានបង្កើតហើយទេ ក្នុងវិស័យរដ្ឋបាល ទាំងរចនាសម្ព័ន្ធ ទាំងរបៀបធ្វើការក៏នៅបន្តជាប់ជានិច្ចក្នុងរបបរាស្ត្រនិយម (រាជាណាចក្រទី១) ក៏ដូចជារបបសាធារណៈរដ្ឋខ្មែរ លន់ នល់ ផងដែរ។ លិខិតស្នាមផ្លូវការច្រើន សរសេរជាភាសាបារាំង របៀបធ្វើការ និងច្បាប់ទាំងឡាយនៅតែទៅតាមបារាំងទាំងអស់ពីព្រោះពួកជំនាញការ Experts ច្រើនតែពួកបារាំង។ នៅលើក្រដាសមានច្បាប់ដែលឲ្យសិទ្ធិទៅរាស្ត្រ តាម ឃុំ ខេត្តគ្រប់គ្រងផ្ទាល់កិច្ចការទាំងឡាយជាប្រយោជន៍ដល់ឃុំ ខេត្ត។

ប៉ុន្តែតាមប្រវត្តិជាក់ស្តែងអំណាចចៅហ្វាយខេត្ត អភិបាលខេត្ត ចៅហ្វាយក្រុង (អភិបាលក្រុង) និងចៅហ្វាយស្រុក (អភិបាលស្រុក) ដែលតំណាងកណ្តាលនោះនៅតែខ្លាំងដូចជំនាន់មុនដដែល។ ពីឆ្នាំ ១៩៧៥

មកដល់ឆ្នាំ១៩៩៣ ប្រជាពលរដ្ឋចង់កាន់កាប់វាសនាជាតិដោយខ្លួនឯង គឺចង់រំដោះខ្លួនពីរបបអាណានិគមដែលខ្មែរគ្នាឯងធ្វើជំនួសបារាំងនោះ។ ខ្មែរក្រហមបានឆក់ឱកាសនេះបានដាក់ពាក្យស្លោក ឯករាជ្យម្ចាស់ការ ដើម្បីទាក់ទាញចិត្តរាស្ត្រដែលចង់បាន។ ប៉ុន្តែជាអកុសលចំពោះរាស្ត្រ ដោយសារខ្មែរក្រហមមិនធ្វើអាណានិគមថ្មីទេ តែធ្វើរបបផ្តាច់ការឃោឃៅកាប់សម្លាប់ឥតត្រាប្រណីហួសវិស័យដែលប្រជាពលរដ្ឋទាំងអស់មិននឹកស្មានដល់។ លទ្ធិកម្មុយនីសផ្តាច់ការបានគ្រប់គ្រងប្រទេសពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយទើបតែធ្វើកំណែទម្រង់នយោបាយទៅរកសេដ្ឋកិច្ចទីផ្សារសេរីជាជំហានៗតាំងពីឆ្នាំ ១៩៧៩ រហូតមកដល់ការបង្កើតរាជាណាចក្រទី២ នៅឆ្នាំ១៩៩៣ ដោយការជួយជ្រោមជ្រែងពីសហគមអន្តរជាតិ ដែលប្រជាពលរដ្ឋខ្មែរស្គាល់ហៅថា អ៊ុនតាក់ ( UNTAC = United Nations Transitional Authority of Cambodia)។ រាជាណាចក្រទី២ ( Second-Kingdom) បើយោងតាមរដ្ឋធម្មនុញ្ញ ១៩៩៣ យើងបានសង្កេតឃើញថា ប្រទេសកម្ពុជាក៏បានធ្វើដំណើរឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ កម្មវិធីរបស់រាជរដ្ឋាភិបាលក៏មានចែងក្នុងទិសដៅថ្មីនេះដែរ។ យើងខិតខំកសាងស្តារប្រទេសឲ្យទៅជាប្រទេសមួយមានការអភិវឌ្ឍ និងជាប្រទេសនីតិរដ្ឋ ដោយសារផលវិបាកដែលបានបង្កឡើងដោយសង្គ្រាមរ៉ាំរ៉ៃជាងម្ភៃឆ្នាំមកនោះ ឧបសគ្គមានលើមតិសេរីនិយម។

ស្ថានភាពប្រទេសយើង បើតាមការសង្កេតក្នុងប្រវត្តិសាស្ត្រកន្លងមកនេះ យើងឃើញថាការអភិវឌ្ឍទៅមិនឆ្ងាយពីការប្រមូលអំណាចទៅតាមថ្នាក់លើ ( អំណាចកណ្តាល) ដូចតែពីសម័យដើមដែរ។ ទោះជាយ៉ាងណាក៏ដោយ យើងសង្ឃឹមថា នាថ្ងៃខាងមុខ ធនធានមនុស្ស នឹងកើតឡើងដោយសារតែការសិក្សាអប់រំបានរីកចម្រើនឡើងជាងសព្វថ្ងៃ ដែលជាកត្តាមួយអាចនាំឲ្យមានការអនុវត្តន៍នយោបាយបានសម្រេច ។

## ១.៣ គោលការណ៍នៃការរៀបចំរដ្ឋបាល

ក្នុងការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋនីមួយៗលើពិភពលោកយើងនេះ គឺគេធ្វើទៅតាមស្ថានភាពជាក់ស្តែង ប្រសិនបើដែនដីរដ្ឋនោះធំគេធ្វើការគ្រប់គ្រងដែនដីនោះ ដោយបែងចែកចេញជា តំបន់ ខេត្ត ស្រុក ឃុំ..។ ការបែងចែកបែបនេះ គឺគេធ្វើឡើងដើម្បីងាយស្រួលក្នុងការគ្រប់គ្រងលើដែនដីវិសាលភាពនេះ។ ប៉ុន្តែរដ្ឋដែលមានទំហំដែនដីតូច តែពុំអាចបែងចែកដែនដីនេះជាតំបន់ ខេត្ត ស្រុក ឃុំ បាននោះទេគេធ្វើការបែងចែកបានត្រឹមតែមណ្ឌលតូចៗប៉ុណ្ណោះ។ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាលដែនដីនេះតែងតែអនុវត្តនូវគោលការណ៍ជាសកលចំនួន២ គឺ៖

- គោលការណ៍គ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធមជ្ឈការ
- គោលការណ៍គ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធវិមជ្ឈការ

### ១.៣.១ មជ្ឈការ

ក.និយមន័យ

ប្រព័ន្ធមជ្ឈការ គឺជាការគ្រប់គ្រងរដ្ឋមួយប្រភេទ ដែលរដ្ឋាភិបាលដឹកនាំរដ្ឋបាលរបស់រដ្ឋដោយផ្ទាល់ ហើយអាជ្ញាធរដែនដីគ្រាន់តែជាស្ពានប៉ុណ្ណោះ។

បើគេនិយាយពីប្រព័ន្ធមជ្ឈការ គឺគេនិយាយពីអំណាចកណ្តាល។ អំណាចកណ្តាល គឺជាអំណាចរបស់រដ្ឋាភិបាលដែលកាន់កាប់ដោយនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រី រដ្ឋលេខាធិការប្រធាន ស្ថាប័នរដ្ឋទាំងឡាយ។ មជ្ឈការ ជាប្រព័ន្ធរដ្ឋបាលមួយដែលនៅក្នុងនោះ អំណាចសម្រេចសេចក្តី និងបញ្ជាចេញពីអំណាចកណ្តាលទាំងអស់ជាតំណាងនៃរដ្ឋ។

ប្រព័ន្ធមជ្ឈការមានគោលដៅបីចម្បងដូចតទៅ ៖

- នីតិបុគ្គលសាធារណៈមានតែមួយ (រដ្ឋ)
- អំណាចសម្រេចសេចក្តី និងបញ្ជាប្រមូលផ្តុំនៅរដ្ឋបាលកណ្តាល
- រដ្ឋបាលទាំងអស់ត្រូវរៀបចំតាមគោលការណ៍ឋានានុក្រម ដែលស្ថិតនៅក្រោមចំណុះ និងការត្រួតពិនិត្យផ្ទាល់របស់អំណាចកណ្តាល ឬរដ្ឋបាលកណ្តាល។ ភ្នាក់ងាររដ្ឋបាលគ្រប់ជាន់ថ្នាក់ដែលមានទីតាំងនៅមូលដ្ឋាននានា បំពេញតួនាទីជាអ្នកប្រើប្រាស់អំណាចរដ្ឋបាលហើយ ត្រូវស្ថិតនៅក្រោមអំណាចឋានានុក្រមរបស់អំណាចកណ្តាល។ ភ្នាក់ងារទាំងនេះទទួលបញ្ជាពីរដ្ឋបាលកណ្តាល និងទទួលបន្ទុកអនុវត្តន៍បញ្ជាទាំងនោះ ចំណែកសិទ្ធិ និងគំនិតផ្តួចផ្តើមរបស់ខ្លួនក៏មានកម្រិតដែរ។

ខ.ចរិកលក្ខណៈនៃរដ្ឋបាលមជ្ឈការ

ក្នុងការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធមជ្ឈការនេះគឺ គេធ្វើការគ្រប់គ្រងតាមរាងសាជីដោយអំណាចក្នុងការធ្វើការសម្រេចទាំងអស់ជាសិទ្ធិផ្តាច់មុខរបស់រដ្ឋាភិបាល ដូចនេះរាល់ការបង្កើត រាល់ការសម្រេច ការកែប្រែអ្វីៗដោយរដ្ឋាភិបាលទាំងអស់។

អាស្រ័យដោយការរីកចម្រើនជាលំដាប់នៃបេសកកម្ម តួនាទីភារកិច្ចរបស់រដ្ឋក្នុងការបម្រើផលប្រយោជន៍ទូទៅ តម្រូវឲ្យរដ្ឋបាលកណ្តាលរំលែកអំណាចមួយចំនួនដែលអាចធ្វើទៅបានឲ្យអាជ្ញាធរមូលដ្ឋានជួយសម្រេច។ ការរំលែកនេះព្រោះរដ្ឋបាលកណ្តាលមានភារកិច្ចកាន់តែច្រើន បញ្ហារាប់មិនអស់នាំឲ្យលិចលង់ទៅដោយសំណុំរឿងធ្វើឲ្យការងារកកស្ទះ។ ម្យ៉ាងទៀតធ្វើឲ្យមានគម្លាតធំពេករវាងរដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋាន ពេលរដ្ឋមិនបានដឹងពីសុខទុក្ខរាស្ត្រប្រជាឡើយ។

**១.៣.២ វិមជ្ឈការ**

ក. និយមន័យ

វិមជ្ឈការ មានន័យថា រាជរដ្ឋាភិបាលប្រគល់នូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឲ្យទៅក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដូចជាក្រុមប្រឹក្សារាជធានី

ក្រុង ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងអស់។[4]

ប្រព័ន្ធវិមជ្ឈការ គឺជាប្រព័ន្ធនៃកិច្ចអភិបាលសំដៅអនុញ្ញាតឲ្យចំពោះសមូហភាពមនុស្សជាតិមួយ (ការរំលែកអំណាចខាងដែនដី) ឬចំពោះកិច្ចការមួយ (ការរំលែកអំណាចខាងបច្ចេកទេស) ដើម្បីអភិបាលដោយខ្លួនឯង ក្រោមការត្រួតពិនិត្យរបស់រដ្ឋដោយឲ្យនូវបុគ្គលភាពគតិយុត្ត អំណាចផ្ទាល់ខ្លួន និងធនធាន។

ប្រព័ន្ធវិមជ្ឈការ គឺជាប្រព័ន្ធមួយដែលអាជ្ញាធរ រដ្ឋបាលកណ្តាលទទួលស្គាល់នូវសិទ្ធិអំណាចក្នុងការសម្រេចរបស់អាជ្ញាធររដ្ឋបាលមូលដ្ឋានដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នានា។ នៅក្នុងការទទួលស្គាល់នូវសិទ្ធិអំណាចរបស់អាជ្ញាធរមូលដ្ឋាននេះ ការផ្ទេរអំណាច និងផ្ទេរការទទួលខុសត្រូវលើកិច្ចការមួយចំនួនឲ្យអាជ្ញាធរមូលដ្ឋានចាត់ចែងការងារដើម្បីបម្រើផលប្រយោជន៍មូលដ្ឋានខ្លួន។ ម្យ៉ាងទៀតវិមជ្ឈការ គឺរាជរដ្ឋាភិបាលប្រគល់ឲ្យក្រុមប្រឹក្សានូវភាពជាម្ចាស់ លើមុខងារសិទ្ធិអំណាច និងធនធានដើម្បីឆ្លើយតបត្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហានេះ។

ខ.ចរិតលក្ខណៈនៃរដ្ឋបាលវិមជ្ឈការ

បើទោះបីជា ទម្រង់នៃការរៀបចំនេះមានប្រគល់នូវសិទ្ធិអំណាចទៅឲ្យសមូហភាពដែនដីក្នុងការសម្រេចប្រកបដោយស្វ័យភាពក៏ដោយ ក៏មានកិច្ចការមួយចំនួនធំសំខាន់ចាំបាច់ផ្សេងទៀតដែលជាអាជ្ញាធររដ្ឋបាលកណ្តាលអោបក្រសោបតែម្នាក់ឯងនោះគឺៈ

- កិច្ចការការពារជាតិ ( កងទ័ព)
- កិច្ចការសន្តិសុខ ( នគរបាល)
- កិច្ចការពាណិជ្ជកម្មក្រៅប្រទេស
- កិច្ចការតុលាការ
- កិច្ចការបោះពុម្ពប្រាក់
- កិច្ចការធ្វើច្បាប់
- កិច្ចការការទូត
- ធនធានធម្មជាតិ ... ។

ក្នុងប្រព័ន្ធនេះអំណាចកណ្តាល បានប្រគល់ទៅឲ្យសមូហភាពដែនដីធ្វើភាគច្រើនជាកិច្ចការផ្នែកសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ ជាពិសេសការងារអភិវឌ្ឍ។

[4] សៀវភៅស្តីពីស្ថាប័នរដ្ឋបាល នៃព្រះរាជាណាចក្រកម្ពុជា សាស្ត្រាចារ្យ ឥន យឿន ឆ្នាំ២០១៣ ទំព័រទី២៣

### ១.៣.៣ វិសហមជ្ឈការ

ក.និយមន័យ វិសហមជ្ឈការ

វិសហមជ្ឈការមានន័យថា រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ផ្ទេរប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ) និងបុគ្គលិកទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តមុខងារនោះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ។ ក្នុងន័យនេះ ភាពជាម្ចាស់មិនបានផ្តល់ជូនអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាឡើយ។ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលបានរក្សាទុកនូវភាពជាម្ចាស់នោះ។

ខ.ចរិតលក្ខណៈវិសហមជ្ឈការ

ក្នុងការគ្រប់គ្រង់រដ្ឋបាលតាមបច្ចេកទេសនេះ គឺគ្រប់គ្រងតាមឋានានុក្រមរដ្ឋបាល ដែលរដ្ឋបាលថ្នាក់កណ្តាលបានផ្តល់ឲ្យសម្រេចតាមលំដាប់ថ្នាក់រៀងខ្លួន។ រាល់ប្រព័ន្ធការងារ គឺតាំងតំណាងរដ្ឋបាលកណ្តាលដោយមិនមានការបោះឆ្នោតជ្រើសតាំងអ្វីឡើយ ពោលគឺអាជ្ញាធរមូលដ្ឋានកើតមានឡើងនូវសិទ្ធិក្នុងការសម្រេចអាស្រ័យដោយសប្បុរសធម៌របស់អាជ្ញាធររដ្ឋបាលកណ្តាលប៉ុណ្ណោះ។ អាជ្ញាធរមូលដ្ឋានគ្មានថវិកាផ្ទាល់ខ្លួនទេ គឺប្រើថវិការបស់ជាតិ ហើយក៏គ្មានសិទ្ធិក្នុងការជ្រើសរើសបុគ្គលិកដែរ។

## ១.៤ អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ ត្រូវបានគេឲ្យនិយមន័យផ្សេងគ្នាជាច្រើនអាស្រ័យនឹងស្ថានភាពជាក់ស្តែង។ ជាសាមញ្ញ អភិបាលកិច្ចល្អមានន័យថា ជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ។

### ១.៤.១ ការណ៍អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ ជាវិធីសាស្ត្រ ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ដោយបំពេញនូវគោលការណ៍ទាំង ៩ ៖[5]

#### ១.៤.១.១ ការចូលរួម

ការចូលរួមក្នុងបរិបទអភិបាលកិច្ចល្អ គឺគេសំដៅទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រី (អាជ្ញាធរ ប្រជាពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាលនានា និងអ្នកពាក់ព័ន្ធផ្សេងៗទៀត) ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តនោះ។ សារៈសំខាន់នៃការចូលរួម គឺដើម្បីធានាថាព័ត៌មានទាំងឡាយស្តីពីបញ្ហាតម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវបានប្រមូល និងវិភាគបានគ្រប់ជ្រុងជ្រោយមុន

[5] យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅ កម្ពុជាដំណាក់កាលទី ២

នឹងធ្វើការសម្រេចចិត្ត ។

ជាទូទៅ ការចូលរួមធ្វើឡើងតាមពីររបៀបគឺ ការចូលរួមដោយផ្ទាល់ និងការចូលរួមតាមរយៈអ្នកតំណាង។

ក. ការចូលរួមដោយផ្ទាល់

ការចូលរួមដោយផ្ទាល់មានន័យថា ជាការចូលរួមរបស់អ្នកពាក់ព័ន្ធគ្រប់រូបដោយខ្លួនឯងផ្ទាល់ នៅក្នុងដំណើរនៃការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តនោះ។ ក្នុងរបបប្រជាធិបតេយ្យប្រជាពលរដ្ឋមានសិទ្ធិចូលរួមដោយផ្ទាល់ពាក់ព័ន្ធទៅនឹងកិច្ចការសាធារណៈនឹងនៅក្នុងសកម្មភាពអភិវឌ្ឍមូលដ្ឋាន ដូចជាៈ

- ការបោះឆ្នោត
- ការចូលរួមក្នុងគណបក្សនយោបាយ
- ការឈរឈ្មោះបោះឆ្នោត
- ការបង្កើតសមាគម សហគមន៍នានា
- ការចូលរួមនៅក្នុងដំណើរការ និងធ្វើសេចក្តីសម្រេចចិត្តនៅក្នុងការកសាងផែនការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន
- ការចូលរួមជាកម្លាំងពលកម្ម និងធនធានរបស់ ប្រជាពលរដ្ឋនៅក្នុងសកម្មភាពអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនក៏ចាត់ទុកជាការចូលរួមដោយផ្ទាល់ដែរ។ល ។

ខ. ការចូលរួមតាមរយៈអ្នកតំណាង

ការចូលរួមតាមរយៈអ្នកតំណាងមានន័យថា អ្នកតំណាងរបស់ប្រជាពលរដ្ឋចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចនោះ។ អ្នកតំណាង ត្រូវតែមានការបំពេញតួនាទីជាអ្នកតំណាងឲ្យឆន្ទៈ និងផលប្រយោជន៍ប្រជាពលរដ្ឋដែលខ្លួនតំណាងឲ្យ។

អ្នកតំណាងប្រជាពលរដ្ឋ អាចត្រូវបានជ្រើសរើសតាមនីតិវិធីផ្សេងៗទៅតាមលក្ខណៈ និងស្ថានភាពជាក់ស្តែងដូចជា :

- ការតែងតាំង ឬការជ្រើសរើសដោយមានការព្រមព្រៀងឯកភាពគ្នា
- ការបោះឆ្នោតសកល ឬអសកល (សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់)
- ទំនៀមទម្លាប់ប្រពៃណី ។ល ។

❖ ក្នុងការជ្រើសរើសអ្នកតំណាង ត្រូវពិចារណាចំណុចមួយចំនួនដូចខាងក្រោម ៖

- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយមានសមត្ថភាព និងលទ្ធភាពអាចបំពេញតួនាទីជាអ្នកតំណាងបាន

- ជាតំណាងពិតប្រាកដឲ្យក្រុមជាក់លាក់ណាមួយ
- ជ្រើសរើស ឬតែងតាំងអ្នកតំណាងទៅតាមនីតិវិធីដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែង
- កំណត់តួនាទី និងការទទួលខុសត្រូវឲ្យបានច្បាស់លាស់
- មានផែនការការងារច្បាស់លាស់
- មាននិតិវិធីផ្លាស់ប្តូរសមាជិកអ្នកតំណាងច្បាស់លាស់
- មានកម្មវិធីពង្រឹងសមត្ថភាព និងការគាំទ្រជាប្រចាំដល់អ្នកតំណាង ។ល ។

វិធីសាស្ត្រដើម្បីជំរុញការចូលរួម ដើម្បីជំរុញឲ្យសកម្មភាពចូលរួមកាន់តែមានភាពប្រសើរឡើង និងដើម្បីធានាឲ្យប្រជាពលរដ្ឋនឹងអ្នកតំណាងដើម្បីឲ្យមានឱកាសចូលរួមពេញលេញ ជាពិសេសតំណាងក្រុមអ្នកក្រីក្រ ក្រុមស្ត្រី និងក្រុមងាយរងគ្រោះ។ ចំណុចមួយចំនួនដែលគួរពិចារណាមានដូចខាងក្រោម៖

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសារៈសំខាន់ និងភាពចាំបាច់នៃការចូលរួមរបស់ពួកគេ
- ផ្សព្វផ្សាយព័ត៌មានស្តីពីកិច្ចប្រជុំ និងព័ត៌មានផ្សេងៗឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ
- កំណត់ពេលវេលា និងទីកន្លែងប្រជុំឲ្យបានសមស្រប
- រៀបចំទីកន្លែងប្រជុំប្រកបដោយផាសុខភាព
- រៀបចំឲ្យមានប្រព័ន្ធទទួល និងផ្តល់ព័ត៌មានដែលមានលក្ខណៈងាយស្រួល និងអាចទទួលយកបាន
- បង្កើតទំនាក់ទំនងល្អ និងស្និទ្ធស្នាលជាមួយប្រជាពលរដ្ឋ ។ល ។

**១.៤.១.២ នីតិរដ្ឋ**

នីតិរដ្ឋក្នុងន័យអភិបាលកិច្ចល្អ ទាមទារឲ្យមានឯកសារក្របខណ្ឌច្បាប់គ្រប់គ្រាន់ដើម្បីបម្រើ និងការពារផលប្រយោជន៍សាធារណៈ ការពារសិទ្ធិមនុស្ស ជាពិសេសក្រុមងាយរងគ្រោះ ឬក្រុមភាគតិច ហើយច្បាប់ទាំងនោះត្រូវបានអនុវត្តដោយមិនលម្អៀង។ លើសពីនេះ ក៏ត្រូវមានប្រព័ន្ធទទួលខុសត្រូវមានប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ និងសមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលម្អៀង និងមិនពុករលួយ។

នីតិរដ្ឋក្នុងន័យអភិបាលកិច្ចល្អផ្តោតជាសំខាន់ទៅលើ :

- ឯកសារក្របខណ្ឌច្បាប់
- ការការពារសិទ្ធិមនុស្ស
- ប្រព័ន្ធទទួលខុសត្រូវ
- ប្រព័ន្ធយុត្តិធម៌
- សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលម្អៀង និងមិនពុករលួយ ។

ក. ឯកសារក្របខណ្ឌច្បាប់

ឯកសារក្របខណ្ឌច្បាប់ គឺជាលិខិតបទដ្ឋានគតិយុត្ត ដែលរួមមាន ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច សេចក្តីណែនាំ ដីកា និងលិខិតបទដ្ឋានគតិយុត្តនានា។ ឯកសារក្របខណ្ឌច្បាប់ដែរសំខាន់ៗ រួមមាន :

- គោលការណ៍ : តាមការវិវត្តរបស់សង្គម និងតាមតម្រូវការនៃការគ្រប់គ្រងរដ្ឋ
- ច្បាប់ផ្ទៃក្នុង : ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ។ល ។
- ច្បាប់អន្តរជាតិ : សន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា ពិធីសារ ។ល។

ខ. ការការពារសិទ្ធិមនុស្ស

សិទ្ធិមនុស្ស គឺជាសេចក្តីត្រូវការចាំបាច់របស់មនុស្សគ្រប់ៗរូបដែលមានតាំងពីកំណើត ដើម្បីទាមទារនូវអ្វីៗដែលធ្វើឲ្យមនុស្សរស់នៅប្រកបដោយវិចារណញ្ញាណ និងសេចក្តីថ្លៃថ្នូរ។ ការទទួលស្គាល់នូវសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្សព្រមទាំងសិទ្ធិស្មើៗគ្នារបស់មនុស្សទាំងអស់ ដែលមិនអាចលក់ ប្តូរ ផ្ទេរ ឬដកហូតបានជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាព។ សិទ្ធិជាមូលដ្ឋានធំបំផុតសម្រាប់មនុស្សគ្រប់រូបគឺ ជីវិត សេរីភាព និងការស្វះស្វែងរកសុភមង្គល ។

គ. ប្រព័ន្ធទទួលខុសត្រូវ

ប្រព័ន្ធទទួលខុសត្រូវសំខាន់ៗបំផុតរួមមាន :

- ខាងអំណាចនយោបាយ : សភា រដ្ឋាភិបាល ប្រមុខរដ្ឋ
- ខាងអំណាចនីតិបញ្ញត្តិ : សភាទទួលខុសត្រូវនៅក្នុងការតាក់តែងច្បាប់
- ខាងអំណាចប្រតិបត្តិ : រដ្ឋបាល អាជ្ញាធរដែនដី មន្ត្រីរាជការ
- ខាងអំណាចតុលាការ : ជាអ្នកធ្វើឲ្យមានការគោរពច្បាប់

ឃ. ប្រព័ន្ធយុត្តិធម៌

គោលការណ៍នៃប្រព័ន្ធយុត្តិធម៌គឺ ឯករាជ្យ និងយុត្តិធម៌។ តុលាការមានតួនាទីកាត់ក្តី និងជម្លោះនានាដោយយុត្តិធម៌ និងមិនលម្អៀង។ ដូច្នេះតុលាការឯករាជ្យ និងយុត្តិធម៌ ជាយន្តការស្នូលមួយក្នុងការជំរុញឲ្យមានការគោរព និងអនុវត្តច្បាប់។ ប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា រួមមាន :

- ប្រព័ន្ធតុលាការ :
    - តុលាការរាជធានី ខេត្ត និងតុលាការយោធា
    - សាលាឧទ្ធរណ៍
    - តុលាការកំពូល

- ក្រៅប្រព័ន្ធតុលាការ
- ការចរចា
- សន្ធានកម្ម ( ការនាំសម្រុះសម្រួល)
- មជ្ឈត្តវិនិច្ឆ័យ (ការវិនិច្ឆ័យក្នុងឋានៈជាអាជ្ញាកណ្តាល)

ង. សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់មិនលម្អៀង និងមិនពុករលួយ

ឯកសារក្របខណ្ឌច្បាប់ ត្រូវបានដាក់ឲ្យប្រើប្រាស់ជាបន្តបន្ទាប់។ រាល់ការអនុវត្តត្រូវតែធ្វើឡើងដោយស្រប តាមឯកសារក្របខណ្ឌច្បាប់ទាំងនោះពេញលេញ ត្រឹមត្រូវ យុត្តិធម៌ និងមិនលម្អៀង។ សមត្ថកិច្ចទទួលខុសត្រូវ ត្រូវអនុវត្តតាមច្បាប់ដោយមិនលម្អៀង និងមិនពុករលួយ គឺជាការរួមចំណែកយ៉ាងខ្លាំងក្នុងអភិបាលកិច្ចល្អ ។

**១.៤.១.៣ តម្លាភាព**

តម្លាភាពក្នុងន័យអភិបាលកិច្ចល្អមានន័យថា រាល់ការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចនោះត្រូវ ធ្វើឡើង :

- ដោយអនុលោមទៅតាមច្បាប់ និងបទដ្ឋាននានា
- ព័ត៌មានពាក់ព័ន្ធនឹងការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្ត ត្រូវផ្សព្វផ្សាយជាចំហ តាមរយៈប្រព័ន្ធសមស្រប និងអាចស្វែងរកបាន ជាពិសេសចំពោះអ្នកដែលទទួលរងនូវផល ប៉ះពាល់ពីការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តទាំងនោះ
- ព័ត៌មានទាំងនោះត្រូវតែមានលក្ខណៈគ្រប់គ្រាន់ និងងាយយល់ ។

**១.៤.១.៤ ការព្រមព្រៀងឯកភាពគ្នា**

ការព្រមព្រៀងឯកភាពគ្នាក្នុងន័យអភិបាលកិច្ចល្អ គឺជាការពិចារណាទូលំទូលាយ និងវែងឆ្ងាយលើផល ប្រយោជន៍ និងតម្រូវការរបស់អ្នកពាក់ព័ន្ធផ្សេងៗគ្នានៅក្នុងសង្គម ហើយឈានទៅរកការសម្រេចចិត្តដោយមាន ការព្រមព្រៀងឯកភាពគ្នាលើជម្រើស និងវិធីសាស្ត្រល្អណាមួយដែលបម្រើផលប្រយោជន៍សាធារណៈ ។

ក. ភាពផ្សេងៗគ្នានៅក្នុងសង្គម

ក្រុមមនុស្សក្នុងសង្គមតែងតែមានគំនិត បញ្ហា តម្រូវការអាទិភាព ដំណោះស្រាយ ការពេញចិត្ត ចំណេះ ដឹង និងការយល់ឃើញផ្សេងៗគ្នា។ ហេតុដូច្នេះហើយ ការពិចារណាឲ្យបានយ៉ាងទូលំទូលាយ និងវែងឆ្ងាយលើ ផលប្រយោជន៍នៃអ្នក។

ពាក់ព័ន្ធផ្សេងៗគ្នាទាំងនោះត្រូវគិតដល់ចំណុចមួយចំនួនដូចជា :

- ស្ថានភាពរួមមាន បញ្ហា តម្រូវការ អាទិភាព ភេទ អាយុ ឋានៈក្នុងសង្គម មុខរបរ។ល។
- ក្រុមជនងាយរងគ្រោះ រួមមាន អ្នកជំងឺអេដស៍ ជនពិការ អ្នកប្រើប្រាស់គ្រឿងញៀន កុមារកំព្រា

- ស្រ្តីរកស៊ីផ្លូវភេទ ទុរគតជន ចាស់ជរា។ល ។
- ប្រវត្តិសាស្រ្ត រួមមាន ប្រវត្តិរបស់ក្រុម ឬជនជាតិនីមួយៗ
- វប្បធម៌ ទំនៀមទម្លាប់ប្រពៃណី រួមមាន ភាសា ពិធីអាពាហ៍ពិពាហ៍ ពិធីបុណ្យប្រពៃណីផ្សេងៗ ទៀត
- ជំនឿសាសនា រួមមាន សាសនាព្រះពុទ្ធ សាសនាឥស្លាម សាសនាគ្រិស្ត ។ល ។
- គណបក្សនយោបាយ រួមមាន គណបក្សប្រជាជន ហ៊្វុនស៊ិនប៉ិច សមរង្ស៊ី ។ល។
- ក្រុមជាតិសាសន៍ រួមមាន គួយ ភ្នង ចារាយ គ្រឹង កាចក់ ចិន ចាម វៀតណាម ។ល។

ខ. គោលការណ៍ណែនាំសម្រាប់សម្របសម្រួលឲ្យមានការព្រមព្រៀងឯកភាពគ្នា

- លក្ខខណ្ឌនៃការព្រមព្រៀងឯកភាពគ្នា រួមមាន :

- ការព្រមព្រៀងគ្នាប្រកបដោយសុខដុមរមនា
- ការពិគ្រោះយោបល់ជាមួយក្រុមពាក់ព័ន្ធទាំងអស់
- ការចូលរួមពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត
- ការយល់ដឹងអំពីគ្នាទៅវិញទៅមក រវាងក្រុមពាក់ព័ន្ធទាំងអស់ ។

- ដំណើរការនៃការព្រមព្រៀងឯកភាពគ្នា

ដើម្បីធ្វើការសម្រុះសម្រួលឲ្យមានការព្រមព្រៀងឯកភាពគ្នា :

- រៀបចំឲ្យមានការជួបជុំគ្នារវាងក្រុមពាក់ព័ន្ធទាំងអស់
- ស្វែងយល់គ្នាទៅវិញទៅមករវាងក្រុមអ្នកពាក់ព័ន្ធទាំងអស់ និងបង្កើតការយោគយល់គ្នា
- ពិភាក្សាជាមួយក្រុមពាក់ព័ន្ធទាំងអស់អំពីផលប្រយោជន៍ និងបង្កើតជម្រើសនានា
- សម្រុះសម្រួល ដើម្បីសម្រេចយកជម្រើសល្អមួយដែលបម្រើនូវផលប្រយោជន៍រួម ដោយមានការព្រមព្រៀងឯកភាពគ្នាប្រកបដោយសុខដុមរមនា។

**១.៤.១.៥ សមធម៌**

សមធម៌ក្នុងន័យអភិបាលកិច្ចល្អមានន័យថា ក្រុម ឬជនគ្រប់រូបទាំងអស់ ជាពិសេសក្រុមភាគតិច និងក្រុមដែលងាយរងគ្រោះមានឱកាសគ្រប់គ្រាន់នៅក្នុងការចូលរួម បញ្ចេញយោបល់ លើកឡើងនូវតម្រូវការពិតអនុវត្តសកម្មភាព និងទទួលផលប្រយោជន៍សមស្រប ដើម្បីកែលម្អ និងថែរក្សាសុខុមាលភាពរបស់ពួកគេ។ លើសពីនេះទៀត ពួកគេមានអារម្មណ៍ថាខ្លួនគឺជាសមាជិកពិតប្រាកដរបស់សង្គម និងមិនត្រូវបានសង្គមបោះបង់ចោលនោះទេ ។

សុខុមាលភាពរបស់សមាជិក ឬក្រុមនីមួយៗ គឺជាសុខុមាលភាពរបស់សង្គមទាំងមូល។ ដូចនេះ ដំណើរ

ការនៃការសម្រេចចិត្ត និងការអនុវត្តសេចក្ដីសម្រេច។

ចិត្តប្រកបដោយសមធម៌ នឹងធ្វើឲ្យគ្រប់សមាជិកទាំងអស់នៅក្នុងសង្គមមានអារម្មណ៍ថា ពួកគេម្នាក់ៗគឺជាសមាជិកពិតប្រាកដរបស់សង្គម និងបានចូលរួមចំណែកនៅក្នុងដំណើរការអភិវឌ្ឍសង្គមនោះ ។ លើសពីនេះទៀត មិនមានសមាជិកណាម្នាក់គិតថាខ្លួនគេត្រូវបានសង្គមបោះបង់ចោលឡើយ ។

**១.៤.១.៦ ប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិ**

ប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិក្នុងន័យអភិបាលកិច្ចល្អ មានន័យថាជាដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រងការប្រើប្រាស់ធនធានឲ្យអស់លទ្ធភាព និងសន្សំសំចៃខ្ពស់ ដើម្បីជាការបង្កើតលទ្ធផលដែលអាចប្រកបដោយគុណភាពខ្ពស់ បរិមាណច្រើនអាចបម្រើផលប្រយោជន៍ជាអតិបរមា និងបានឆ្លើយតបទៅតម្រូវការពិតរបស់សង្គម ។ គោលគំនិតនៃភាពស័ក្ដិសិទ្ធិនៅក្នុងបរិបទអភិបាលកិច្ចល្អក៏បានបញ្ចូលផងដែរចំពោះការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការការពារបរិស្ថាន។

ដើម្បីឲ្យមានប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិក្នុងការអនុវត្ត ត្រូវពិចារណាចំណុចមួយចំនួន ដូចខាងក្រោម :

- ការប្រើប្រាស់ធនធានឲ្យបានត្រឹមត្រូវ (ធនធានមនុស្ស ហិរញ្ញវត្ថុ សម្ភារ ពេលវេលា)
- ការអនុវត្តសកម្មភាពដែលជាអាទិភាពខ្ពស់
- ជៀសវាងអនុវត្តនូវការិយាធិបតេយ្យ
- ការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ
- គ្មានអំពើពុករលួយ
- ការសម្រេចចិត្តតាមបែបចូលរួម ។ល ។

**១.៤.១.៧ គណនេយ្យភាព**

គណនេយ្យភាពក្នុងន័យអភិបាលកិច្ចល្អ មានន័យថា ជាការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការ និងអនុវត្តសេចក្ដីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយរាយការណ៍ ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្ត ។

គណនេយ្យភាព គឺមិនត្រឹមតែជាការទទួលខុសត្រូវចំពោះមុខអ្នកណាម្នាក់ដែលបានស្នើសុំឲ្យធ្វើអ្វីមួយនោះទេ ក៏ប៉ុន្តែវាគឺជាការទទួលខុសត្រូវនូវសកម្មភាពដែលបានអនុវត្តចំពោះមុខអ្នកពាក់ព័ន្ធទាំងអស់ផងដែរ។ មិនមែនមានតែស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាលប៉ុណ្ណោះទេដែលត្រូវមានគណនេយ្យភាព អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនឯកជនក៏ត្រូវឲ្យមានគណនេយ្យភាពជាសាធារណៈ ចំពោះអ្នកពាក់ព័ន្ធទាំងអស់របស់ខ្លួនផងដែរ ពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់អំពីការសម្រេចចិត្ត ។

ក្នុងន័យគណនេយ្យភាពនេះ រួមមាន គណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំ និងគណនេយ្យភាពចំពោះ

មុខសាធារណជន។

### ១.៤.១.៨ ការឆ្លើយតប

ការឆ្លើយតបក្នុងន័យអភិបាលកិច្ចល្អមានន័យថា ជាការព្យាយាមខិតខំប្រឹងប្រែងរបស់អង្គភាព ស្ថាប័ន ដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ដោយស្មើភាពគ្នានឹងមិនរើសអើងនៅក្នុងក្របខណ្ឌពេលវេលាមួយដ៏សមហេតុផល។ ការឆ្លើយតបអាចជា :

- ការបំពេញសេវាកម្មជូនប្រជាពលរដ្ឋតាមការស្នើសុំ
- ដំណោះស្រាយដែលស្តែងឡើងជាសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬការលំបាកនានា
- ការឆ្លើយបំភ្លឺអំពីមូលហេតុដែលមិនអាចឈានដល់ការធ្វើសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬការលំបាកទាំងនោះបាន
- សំណើសុំអន្តរាគមន៍ពីស្ថាប័ន អង្គភាពមានសមត្ថកិច្ច ដើម្បីជួយដោះស្រាយបញ្ហា ឬការលំបាកទាំងនោះ ព្រមទាំងជំរាបអំពីសំណើសុំអន្តរាគមន៍នេះដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងបញ្ហា ឬការលំបាកទាំងនោះ ។

### ១.៤.១.៩ ចក្ខុវិស័យជាយុទ្ធសាស្ត្រ

អ្នកដឹកនាំទាំងអស់ និងស្ថាប័នសាធារណៈនានាត្រូវមានទស្សនៈទូលំទូលាយ និងសម្រាប់រយៈពេលវែងអំពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្ស ដោយយកចិត្តទុកដាក់អំពីតម្រូវការចាំបាច់នានា ដែលត្រូវអភិវឌ្ឍលើការងារនេះ។ ជាងនេះទៀត អ្នកដឹកនាំទាំងអស់ត្រូវមានការយល់ដឹងឲ្យបានច្បាស់អំពីទិដ្ឋភាពនានាផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គមដែលពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ ។

# ជំពូកទី២
# ស្ថានភាពទូទៅរបស់ខណ្ឌចំការមន

# ជំពូកទី២
# ស្ថានភាពទូទៅរបស់ខណ្ឌចំការមន

## ២.១ ទិដ្ឋភាពទូទៅក្នុងខណ្ឌចំការមន

ខណ្ឌចំការមន គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងកើតទល់នឹងខណ្ឌច្បារអំពៅ ដោយដងទន្លេបាសាក់ ខាងលិចទល់នឹងខណ្ឌបឹងកេងកង ខាងត្បូងទល់នឹងខណ្ឌមានជ័យ ខាងជើងទល់នឹងខណ្ឌដូនពេញ។ ក្នុងនោះផងដែរខណ្ឌចំការមន មាន៥សង្កាត់ដូចជា សង្កាត់ទន្លេបាសាក់ សង្កាត់ទួលទំពូងទី១ សង្កាត់ទួលទំពូងទី២ សង្កាត់បឹងត្របែក និងសង្កាត់ផ្សារដើមថ្កូវ។

### ២.១.១ ប្រវត្តិរបស់សាលាខណ្ឌចំការមន

ខណ្ឌចំការមន ត្រូវបានបែងចែកទៅជា ១២ សង្កាត់ និង៨៥ ភូមិ។ ដែលសង្កាត់ទាំងនោះមាន ដូចជា សង្កាត់ទន្លេបាសាក់ សង្កាត់បឹងកេងកងទី១ សង្កាត់បឹងកេងកងទី២ សង្កាត់បឹងកេងកងទី៣ សង្កាត់ អូឡាំពិក សង្កាត់ទួលស្វាយព្រៃទី១ សង្កាត់ទួលស្វាយព្រៃទី២ សង្កាត់ទំនប់ទឹក សង្កាត់ទួលទំពូងទី១ សង្កាត់ទួលទំពូងទី២ សង្កាត់បឹងត្របែក សង្កាត់ផ្សារដើមថ្កូវ។ ខណ្ឌនេះមានផ្ទៃក្រឡាសរុប ១០,៧៨ គ.ម២។ តាមរយៈជំរឿនឆ្នាំ ១៩៩៨ របស់ប្រទេសកម្ពុជា ខណ្ឌនេះមានប្រជាជន ១៨៧,០០៤នាក់។ ឈ្មោះខណ្ឌ ត្រូវបានគេសរសេរជាអក្សរឡាតាំងថា Chamka Morn តាមរយៈប្រព័ន្ធឡាតាំងយានកម្មដែលបានប្រើប្រាស់ក្នុង ឆ្នាំ ១៩៥០ និងឆ្នាំ ១៩៦០។ អាសយដ្ឋានទំនាក់ទំនង សាលាខណ្ឌចំការមនចាស់ នៅ ផ្ទះលេខ១៦៩, ១៧១, ១៧៣, ១៧៥ មហាវិថីម៉ៅសេទុង សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ក្បែរស្តុបទួលទំពូង។

ខណ្ឌចំការមនត្រូវបានបំបែកជា២ យោងតាមអនុក្រឹត្យ លេខៈ ០៣ អនក្រ.បក ចុះ ថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតខណ្ឌបឹងកេងកងថ្មី នៃរាជធានីភ្នំពេញដែលបានយកទីតាំងសាលាខណ្ឌចំការមន ជាទីតាំងសាលាខណ្ឌបឹងកេងកងថ្មី និងទីតាំងសាលាខណ្ឌចំការមនថ្មី ត្រូវស្ថិតនៅសង្កាត់ទន្លេបាសាក់។

### ២.១.២ ស្ថានភាពភូមិសាស្ត្ររបស់ខណ្ឌចំការមន

ខណ្ឌចំការមន គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងកើតទល់នឹងខណ្ឌច្បារអំពៅ ដោយដងទន្លេបាសាក់ ខាងលិចទល់នឹងខណ្ឌបឹងកេងកង ខាងត្បូងទល់នឹងខណ្ឌមានជ័យ ខាងជើងទល់នឹងខណ្ឌដូនពេញ ដែលមានផ្ទៃដីសរុបមានទំហំ ៧,១៥១,៤២៤.៥៧ ម៉ែត្រការ៉េ ស្មើនឹង ៧១៥ហិកតា ១៤អា និង២៤សង់ទីអា។ ដោយការបង្កើតខណ្ឌបឹងកេងកងថ្មី បានបន្សល់ទុកឱ្យខណ្ឌចំការមនមានតែ៥សង្កាត់ ដូចជា សង្កាត់ទន្លេបាសាក់ សង្កាត់ទួលទំពូងទី១ សង្កាត់ទួលទំពូងទី២ សង្កាត់បឹងត្របែក និងសង្កាត់ផ្សារដើមថ្កូវ និងខណ្ឌបឹងកេងកង មានចំនួន០៧សង្កាត់គឺ សង្កាត់បឹងកេងកងទី១ សង្កាត់បឹង

កេងកងទី២ សង្កាត់បឹងកេងកងទី៣ សង្កាត់អូឡាំពិក សង្កាត់ទួលស្វាយព្រៃទី១ សង្កាត់ទំនប់ទឹក និងសង្កាត់ទួលស្វាយព្រៃទី២ ។

រាជធានីភ្នំពេញចែកចេញជាខណ្ឌចំនួន ១៤ ដែលមានសង្កាត់ចំនួន ១០៥។ ក្នុងចំណោមខណ្ឌទាំង ១៤ នោះគឺមានខណ្ឌ ២ ដែលទើបបង្កើតថ្មីកាលពីខែមករាកន្លងទៅ គឺខណ្ឌបឹងកេងកង និងខណ្ឌកំបូល។ ខណ្ឌថ្មីទាំង២ នេះបានកាត់សង្កាត់មួយចំនួនពីខណ្ឌផ្សេងៗ ពោលគឺខណ្ឌបឹងកេងកងកាត់ ៧ សង្កាត់ពីខណ្ឌ ចំការមន ចំណែកឯខណ្ឌកំបូលកាត់យក ៦ សង្កាត់ពីខណ្ឌពោធិសែនជ័យ និង១សង្កាត់ពីខណ្ឌដង្កោ។

សង្កាត់ទាំង ១០៥ ក្នុងខណ្ឌទាំង ១៤ របស់រាជធានីភ្នំពេញរួមមានដូចខាងក្រោម៖

- ខណ្ឌ ចំការមន ចែកចេញជា ៥ សង្កាត់ ៖ សង្កាត់ទន្លេបាសាក់, សង្កាត់ទួលទំពូងទី ១, សង្កាត់ទួលទំពូងទី ២, សង្កាត់បឹងត្របែក និង សង្កាត់ផ្សារដើមថ្កូវ។
- ខណ្ឌ ដូនពេញ ចែកចេញជា ១១ សង្កាត់ ៖ សង្កាត់ផ្សារថ្មីទី ១, សង្កាត់ផ្សារថ្មីទី ២, សង្កាត់ផ្សារថ្មីទី ៣, សង្កាត់បឹងរាំង, សង្កាត់ផ្សារកណ្ដាលទី១, សង្កាត់ផ្សារកណ្ដាលទី២, សង្កាត់ចតុមុខ, សង្កាត់ជ័យជំនះ, សង្កាត់ផ្សារចាស់, សង្កាត់ស្រះចក និងសង្កាត់វត្តភ្នំ។
- ខណ្ឌ ៧មករា ចែកចេញជា ៨ សង្កាត់ ៖ សង្កាត់អូរឫស្សីទី ១, សង្កាត់អូរឫស្សីទី ២, សង្កាត់អូរឫស្សីទី ៣, សង្កាត់អូរឫស្សីទី ៤, សង្កាត់មនោរម្យ, សង្កាត់មិត្តភាព, សង្កាត់វាលវង់ និងសង្កាត់បឹងព្រលឹត។
- ខណ្ឌ ទួលគោក ចែកចេញជា ១០ សង្កាត់ ៖ សង្កាត់ផ្សារដេប៉ូទី ១, សង្កាត់ផ្សារដេប៉ូទី ២, សង្កាត់ផ្សារដេប៉ូទី ៣, សង្កាត់ទឹកល្អក់ទី ១, សង្កាត់ទឹកល្អក់ទី ២, សង្កាត់ទឹកល្អក់ទី ៣, សង្កាត់បឹងកក់ទី ១, សង្កាត់បឹងកក់ទី ២, សង្កាត់ផ្សារដើមគរ និងសង្កាត់បឹងសាឡាង។
- ខណ្ឌ ដង្កោ ចែកចេញជា ១២ សង្កាត់ ៖ សង្កាត់ដង្កោ, សង្កាត់ពងទឹក, សង្កាត់ព្រៃវែង, សង្កាត់ព្រៃស សង្កាត់ក្រាំងពង្រ, សង្កាត់សាក់សំពៅ, សង្កាត់ជើងឯក, សង្កាត់គងនយ, សង្កាត់ព្រែកកំពឹស, សង្កាត់រលួស, សង្កាត់ស្ពានថ្ម និង សង្កាត់ទៀន។
- ខណ្ឌ មានជ័យ ចែកចេញជា ៧ សង្កាត់ ៖ សង្កាត់ចាក់អង្រែលើ, សង្កាត់ចាក់អង្រែក្រោម, សង្កាត់ស្ទឹងមានជ័យទី១, សង្កាត់ស្ទឹងមានជ័យទី២, សង្កាត់ស្ទឹងមានជ័យទី៣, សង្កាត់បឹងទំពុនទី១ និងសង្កាត់បឹងទំពុនទី២។
- ខណ្ឌ ឫស្សីកែវ ចែកចេញជា ៧ សង្កាត់ ៖ សង្កាត់ស្វាយប៉ាក, សង្កាត់គីឡូម៉ែត្រលេខ៦, សង្កាត់ឫស្សីកែវ, សង្កាត់ច្រាំងចំរេះទី ១, សង្កាត់ច្រាំងចំរេះទី ២, សង្កាត់ទួលសង្កែទី១ និងសង្កាត់ទួលសង្កែទី២។

- ខណ្ឌ សែនសុខ ចែកចេញជា ៦ សង្កាត់ ៖ សង្កាត់ភ្នំពេញថ្មី, សង្កាត់ទឹកថ្លា, សង្កាត់ឃ្មួញ, សង្កាត់ក្រាំងធ្នង់, សង្កាត់អូរបែកក្អម និងសង្កាត់គោកឃ្លាង។
- ខណ្ឌ ពោធិ៍សែនជ័យ ចែកចេញជា ៧ សង្កាត់ ៖ សង្កាត់ត្រពាំងក្រសាំង, សង្កាត់សំរោងក្រោម, សង្កាត់ចោមចៅទី១, សង្កាត់ចោមចៅទី២, សង្កាត់ចោមចៅទី៣, សង្កាត់កាកាបទី១ និងសង្កាត់កាកាបទី២។
- ខណ្ឌ ច្បារអំពៅ ចែកចេញជា ៨ សង្កាត់ ៖ សង្កាត់ច្បារអំពៅទី ១, សង្កាត់ច្បារអំពៅទី ២, សង្កាត់និរោធ, សង្កាត់ព្រែកប្រា, សង្កាត់វាលស្បូវ, សង្កាត់ព្រែកឯង, សង្កាត់ក្បាលកោះ និងសង្កាត់ព្រែកថ្មី។
- ខណ្ឌ ជ្រោយចង្វារ ចែកចេញជា ៥ សង្កាត់ ៖ សង្កាត់ជ្រោយចង្វារ, សង្កាត់ព្រែកលៀប, សង្កាត់ព្រែកតាសេក, សង្កាត់កោះដាច់ និងសង្កាត់បាក់ខែង។
- ខណ្ឌ ព្រែកព្នៅ ចែកចេញជា ៥ សង្កាត់ ៖ សង្កាត់ព្រែកព្នៅ, សង្កាត់ពញាពន់, សង្កាត់សំរោង , សង្កាត់គោករកា និងសង្កាត់ពន្សាំង។
- ខណ្ឌ បឹងកេងកង (ទើប បង្កើតថ្មី) ចែកចេញជា ៧ សង្កាត់ ៖ សង្កាត់ បឹងកេងកេង១, សង្កាត់ បឹងកេងកេង២, សង្កាត់ បឹងកេងកេង៣, សង្កាត់ អូរឡាំពិក, សង្កាត់ ទំនប់ទឹក, សង្កាត់ ទួលស្វាយព្រៃ១ និង សង្កាត់ ទួលស្វាយព្រៃ២។
- ខណ្ឌ កំបូល (ទើបបង្កើតថ្មី) ចែកចេញជា ៧ សង្កាត់ ៖ សង្កាត់ កំបូល, សង្កាត់ កន្ទោក, សង្កាត់ ឱឡោក សង្កាត់ ស្នោរ សង្កាត់ ភ្លើងឆេះ រទេះ សង្កាត់ បឹងធំ និងសង្កាត់ប្រទះឡាង។

### ២.១.៣ ស្ថានភាពប្រជាសាស្ត្រ

ប្រជាពលរដ្ឋនៅក្នុងខណ្ឌចំការមន មានចំនួន ៩,៤៤២គ្រួសារ ដោយមានគ្រួសារអចិន្ត្រៃយ៍ចំនួន ៧,៣៣៨គ្រួសារ និងគ្រួសារបណ្តោះអាសន្ន មានចំនួន ១,៩៦៥គ្រួសារ ដែរនៅក្នុងមានប្រជាពលរដ្ឋសរុបចំនួន ៤៧,០៥៣នាក់ ប្រជាពលរដ្ឋជាស្ត្រី មានចំនួន ២២,៦១២ ហើយប្រជាពលរដ្ឋខ្មែរ អាយុ ១៨ឆ្នាំឡើង មានចំនួន ៣០,៣៦៩ នាក់។

## ២.២ សន្តិសុខ និងសណ្តាប់ធ្នាប់ខណ្ឌចំការមន

នៅក្នុងខណ្ឌមួយ ដែលមានការស់នៅប្រកបទៅដោយចីរភាពបានលុះត្រាតែថា នៅក្នុងភូមិសាស្ត្រមួយនោះប្រកបដោយសន្តិសុខ និងសណ្តាប់ធ្នាប់។ ដែលនៅក្នុងសន្តិសុខត្រូវ បានកំណត់នៅក្នុងគោលដៅសំខាន់ ៣យ៉ាង រួមមាន៖ សុវត្ថិភាពបុគ្គល សុវត្ថិភាពសម្ភារៈ និងសុវត្ថិភាពចំណីអាហារ។

### ២.២.១ សុវត្ថិភាពបុគ្គល

ការរស់នៅរបស់បុគ្គលម្នាក់ៗ ក្នុងសហគមន៍មួយ សង្គមជាតិមួយដែលប្រកបដោយសុខសាន្ត ជាមួយគ្នានេះផងដោយឈរលើ គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដែលបានដាក់ចេញឱ្យអនុវត្តន៍ដោយក្រសួងមហាផ្ទៃ ក៏បានចូលរួមយ៉ាងសកម្មក្នុងការការពារសុវត្ថិភាពបុគ្គល គឺគេហៅថា សុវត្ថិភាពបុគ្គល ។ ហើយ គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព នេះលក្ខណសម្បត្តិ ៧ យ៉ាង រួមមានៈ

ទី១- ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាល ប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។

ទី២- គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

ទី៣- មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។

ទី៤- គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។

ទី៥- ដោះស្រាយវិវាទការនៅមូលដ្ឋាន ក្រៅប្រព័ន្ធតុលាការ ប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ទី៦- មានអនាម័យ មានសោភណ្ឌភាពល្អ និងមានបរិស្ថានល្អ។

ទី៧- ឆ្លើយតបបានទាន់ពេលវេលា ចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាត កាចសាហាវប្រកបដោយប្រសិទ្ធភាព។

ដើម្បីឆ្លើយតបទៅ នឹងស្ថានភាពបច្ចុប្បន្ន និងកៀរគរឲ្យមានការចូលរួមគាំទ្រកាន់តែច្រើនបន្ថែមទៀត រាជរដ្ឋាភិបាលសម្រេចកែលម្អលក្ខណៈសម្បត្តិ នៃគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ព្រមទាំងលើកកម្រិតគោលនយោបាយនេះជារបស់រាជរដ្ឋាភិបាល ដែលមានគោលបំណង និងសំណូមពរ ដូចខាងក្រោមៈ

ទី១- បន្តកសាង និងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គមលើកកម្ពស់អនាម័យ បរិស្ថាន សុខមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឲ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

ទី២- កសាងបានជា កម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដោយបំផុសឲ្យមានកិច្ចសហការចូលរួម ជាមួយសមត្ថកិច្ចពីវិស័យសាធារណៈវិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស។

ទោះជាទទួលបានលទ្ធផលគួរជាទីមោទនៈក៏ពិតមែន ក៏ប៉ុន្តែការប្រព្រឹត្តទៅនៃចលនាអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពនៅមានបញ្ហាប្រឈម ជាច្រើនដែលពាក់ព័ន្ធ ដល់ការងារពង្រឹងតួនាទីដឹកនាំការផ្សព្វផ្សាយគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ការកសាងកម្លាំងប្រជាការពារ ការរៀបចំវេទិកាសាធារណៈ ពិសេសការបំផុសចលនាប្រឡងប្រណាំង នៅមិនទាន់ស៊ីជម្រៅដែលមានលក្ខណៈ ស្មុគស្មាញ និងបន្ទុកការងារកាន់តែច្រើន។ ដូចនេះ គណៈបញ្ជាការឯកភាព ក្រុង ខណ្ឌ កងកម្លាំងមានសមត្ថកិច្ច ព្រមទាំងមាននូវអាជ្ញាធរពាក់ព័ន្ធត្រូវបន្តប្រកាន់ខ្ជាប់នូវទស្សនៈ ភូមិ-ឃុំ មានសុវត្ថិភាព ជាភារកិច្ចសំខាន់សម្រាប់កិច្ចការប្រចាំថ្ងៃរបស់ខ្លួន។ ត្រូវបង្កើនការប្រមូលផ្តុំដឹកនាំ ក្នុងមូលដ្ឋានឱ្យចូលរួមយ៉ាងសកម្ម រក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈតាមរយៈការកសាងផែនការប្រើប្រាស់កម្លាំងសរុបវិធានការសរុប ព្រមទាំងមធ្យោបាយសរុប និងមានកម្មវិធីប្រជុំបូកសរុប ដកពិសោធន៍តាមដំណាក់កាលនីមួយៗ សំដៅកែលម្អបង្កើនប្រសិទ្ធភាពថែមទៀតសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ របស់ខ្លួន។ បង្កើនការរៀបចំ នូវវេទិកាសាធារណៈឲ្យកាន់តែសកម្មបន្ថែមទៀតដោយយកចិត្តទុកដាក់ខ្ពស់អំពីគុណភាព នៃការទទួលបានព័ត៌មាន អំពីទុក្ខកង្វល់របស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ ព្រមទាំងបានខិតខំដោះស្រាយនូវរាល់សំណូមពរដែលប្រជាពលរដ្ឋបានលើកឡើងឲ្យរួសរាន់ប្រកបដោយស្មារតីទទួលខុសត្រូវ គឺសំដៅដល់ការធ្វើឱ្យវេទិកាសាធារណៈមួយឲ្យទទួលបាននូវគុណប្រយោជន៍ពិតៗ ហើយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ក្នុងរាជធានី/ខេត្ត ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឲ្យការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ទទួលបានលទ្ធផលល្អ ធានាការពារសន្តិសុខ និងសណ្តាប់ធ្នាប់ជូនដល់ប្រជាពលរដ្ឋគ្រប់ទីកន្លែង ដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ។

### ២.២.២ សុវត្ថិភាពសម្ភារ

សុវត្ថិភាពសម្ភារ គឺត្រូវបានសំដៅដល់ការគ្រប់គ្រងសម្ភាររួមរបស់ប្រជាពលរដ្ឋនៅក្នុងខណ្ឌមួយដោយមិនមានភាពចលាចលនៅក្នុងខណ្ឌ ដូចជាមិនមានការលួចសម្ភារ ឬគាស់ផ្ទះរបស់ប្រជាជន មិនមានក្មេងទំនើង មិនមានការប្រព្រឹត្តអំពើអនាចារ អំពើល្បែងស៊ីសង មិនមានអំពើលួច ឬបំផ្លិចបំផ្លាញវត្ថុសាធារណៈ មិនមានការប្លន់ ឬគាស់ទូរធនាគារ ឬអំពើចារកម្មផ្សេងៗដែលនាំឱ្យមានភាពអសន្តិសុខ ដែលធ្វើឲ្យមានភាពភ័យខ្លាចដល់ការរស់នៅរបស់ប្រជាជននៅតាមតំបន់ផងដែរ។ ជាមួយគ្នានេះដែរ ក៏ត្រូវមានសន្តិសុខ សុវត្ថិភាពដោយមានយកចិត្តទុកដាក់ពីសំណាក់មន្ត្រីជំនាញ ឬមន្ត្រីដែលពាក់ព័ន្ធបន្ថែមសម្រាប់ផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋជាមួយនឹងការការពារ ដោយការយកចិត្តទុកដាក់ខ្ពស់ជាមួយ នឹងបញ្ហាសន្តិសុខដោយអនុវត្តតាមគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព។ លើសពីនេះទៅទៀត តាមរយៈសុវត្ថិភាពសម្ភារនេះផងដែលធ្វើឲ្យមានការអភិវឌ្ឍន៍ និងការវិនិយោគជាច្រើនដែលធ្វើឲ្យប្រជាពលរដ្ឋនៅក្នុងតំបន់ មានឱកាសទទួលបានការងារ និងឲ្យមានសេដ្ឋកិច្ច

នៅក្នុងគ្រួសារកាន់តែកើនឡើង។

### ២.២.៣ សុវត្ថិភាពចំណីអាហារ

ចំណីអាហារ គឺជាវត្ថុមួយដែលគេបរិភោគ និងផឹកដើម្បីទទួលបាននូវសារជាតុចិញ្ចឹមនានា និងផ្តល់ថាមពលដែលសម្រាប់លូតលាស់ និងធ្វើសកម្មភាពនានា។ សុវត្ថិភាពចំណីអាហារនៅកម្ពុជា មិនទាន់ស្របទៅតាមស្តង់ដារសុវត្ថិភាព ទៅតាមការចង់បានរបស់ភ្ញៀវទេសចរណ៍នៅឡើយទេអាចនិយាយជារួម និងដោយឡែកសម្រាប់អ្នកធ្វើការក្នុងវិស័យទេសចរណ៍នៅកម្ពុជា។ ហើយបច្ចុប្បន្ននេះទាំងអាជ្ញាធរកាំកុងត្រូល និងរដ្ឋាភិបាលក៏ដូចជាមន្ត្រីពាក់ព័ន្ធផ្សេងៗបានខិតខំព្យាយាមទប់ស្កាត់ បន្លែ ផ្លែឈើ សាច់ ត្រី គ្រឿងសមុទ្រ និងចំណីអាហារកំប៉ុង ដែលមិនមានគុណភាពមានការចែកចាយនៅក្នុងទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះដែល ដោយសារតម្រូវការចំណីអាហារនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានច្រើន ដូចនេះហើយដើម្បីបំពេញតម្រូវការឱ្យគ្រប់នូវការប្រើប្រាស់នេះ ត្រូវទាមទារឲ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងការដាំដំណាំ បន្លែផ្លែឈើ គ្មានសារជាតិគីមីដោយខ្លួនឯង ទុកប្រើប្រាស់ផង និងដាក់លក់នៅលើទីផ្សារផង ដើម្បីផ្តល់សុវត្ថិភាពដល់ខ្លួនឯង ក្រុមគ្រួសារ និងសង្គមជាតិផងដែរ។ ក្នុងនោះផងដែល ចំពោះអ្នកផលិតម្ហូបអាហារដើម្បីចូលរួម ក្នុងការបម្រើដល់សុខភាព របស់អ្នកប្រើប្រាស់ត្រូវមានគុណធម៌ សច្ចធម៌ មានបច្ចេកទេសខ្ពស់ កុំដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួនធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់អ្នកដទៃតាមរយៈការលក់របស់ដែលមិនមានគុណភាពទៅកាន់អតិថិជន។ ចំពោះអ្នកប្រើប្រាស់ក៏គួរគប្បីស្វែងយល់ឱ្យបានច្រើននូវរាល់ ផលិតផលណាដែលគួរប្រើប្រាស់ និងមិនគួរប្រើប្រាស់ដូចគ្នាផងដែរ។ សម្រាប់អ្នកប្រើប្រាស់ទាំងអស់ ដើម្បីទទួលបានសុវត្ថិភាពចំណីអាហារ បើអាចពិនិត្យលើគុណភាពចំណីអាហារ ក៏គួរគប្បីមុននឹងទិញផលិតផលយកទៅប្រើប្រាស់ យ៉ាងហោចណាស់ក៏បានពិនិត្យមើលទៅលើ កាលបរិច្ឆេទផុតកំណត់ឱ្យបានមួយចំណុចជាមុនសិន។ ដើម្បីធានាឲ្យដឹងថាផលិតផលនោះនៅអាចប្រើប្រាស់បាន ហើយបើកន្លែងបរិច្ឆេទផុតកំណត់មានការកោសលុប ឬមានជាន់គ្នានោះ យើងមិនត្រូវទិញយកទៅប្រើប្រាស់នោះឡើយ។

ជារួមអាហារដែលមានសុវត្ថិភាព គឺយើងត្រូវពិនិត្យទៅលើបញ្ហាមួយចំនួនដែលជាកត្តាចាំបាច់ដូចជា៖ កាលបរិច្ឆេទនៃការផុតកំណត់ អនាម័យ ការវេចខ្ចប់ ការទទួលស្គាល់ជាលក្ខណៈស្តង់ដារ ជាពិសេសជាងនេះទៀតចំពោះស្ថាប័នដែលពាក់ព័ន្ធផ្នែកចំណីអាហារ គឺត្រូវបានដើរតួនាទីមួយយ៉ាងសំខាន់ក្នុងការថែរក្សាសុខភាពប្រជាជន និងអនុវត្តយ៉ាងតឹងរឹងតាមរយៈការចុះត្រួតពិនិត្យទំនិញខុសច្បាប់ និងដាក់ទោសជនដែលនាំចូល ឬលក់ផលិតផលចំណីអាហារដែលខូចគុណភាព ដែលនាំឲ្យមានផលប៉ះពាល់ដល់អ្នកប្រើប្រាស់។ ជាមួយគ្នានេះផងដែរ ប្រជាពលរដ្ឋដែលលក់ចំណីអាហារក៏ត្រូវចូលរួមចំណែកដូចគ្នា ក្នុងការថែរក្សាអនាម័យចំណីអាហារដើម្បីសុខភាពអ្នកបរិភោគ។

បើយោងតាមសេចក្តីណែនាំលេខ១៨ អយក.សណន ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនដែលត្រូវបានហាមឃាត់មាន៦ប្រភេទដូចខាងក្រោម៖

- ចំណីអាហារគ្រប់ប្រភេទដែលហួសកំណត់កាលបរិច្ឆេទ
- គ្រឿងស្រវឹង និងផលិតផលថ្នាំជក់គ្រប់ប្រភេទ
- ចំណីអាហារដែលមិនមានប្រភពច្បាស់លាស់
- ភេសជ្ជៈប៉ូវកម្លាំង ភេសជ្ជៈផ្អែមខ្លាំង កាហ្វេ ការ៉េម ទឹកស៊ីរ៉ូហ៍គ្រប់ប្រភេទ
- ស្ករសូកូឡា ស្ករគ្រាប់ និងស្ករកៅស៊ូគ្រប់ប្រភេទ
- ចាហួយគ្រប់ប្រភេទ នំដូណាត់ នំផ្អែមខ្លាំងៗ។

តាមការលើកឡើងរបស់ លោកប្រធានសហព័ន្ធសហជីពកម្មករនិយោជិកវិស័យទេសចរណ៍ និងសេវាកម្មកម្ពុជា ខណៈពេលដែល រដ្ឋាភិបាលកំពុងធ្វើសេចក្តីព្រាងច្បាប់ស្តីពី «សុវត្ថិភាពម្ហូបអាហារ»។ ហើយសេចក្តីព្រាងច្បាប់ស្តីពី សុវត្ថិភាពម្ហូបអាហារ ដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២១។

# ជំពូកទី៣
# តួនាទី និងភារកិច្ចរដ្ឋបាល
# ខណ្ឌចំការមន

# ជំពូកទី៣

# តួនាទី និងភារកិច្ចរដ្ឋបាលខណ្ឌចំការមន

## ៣.១. ក្រុមប្រឹក្សាខណ្ឌចំការមន

ក្រុមប្រឹក្សាខណ្ឌ ដែលបង្កើតឡើងដោយការបោះឆ្នោតស្របតាមច្បាប់[6] ។

ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ ជាអ្នកការពារ ព្រមទាំងជាអ្នកបម្រើឲ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ៣.១.១. សិទ្ធអំណាចក្រុមប្រឹក្សាខណ្ឌចំការមន

ក្រុមប្រឹក្សាខណ្ឌចំការមន មានសិទ្ធិអំណាចពីគឺៈ

- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ
- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ។

ក្រុមប្រឹក្សាខណ្ឌចំការមននីមួយៗ ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តព្រមទាំងការសម្រេចនានារបស់ក្រុមប្រឹក្សារាជធានីដែលពាក់ព័ន្ធដល់ខណ្ឌរបស់ខ្លួន។

ប្រធានក្រុមប្រឹក្សាខណ្ឌចំការមន នៅក្នុងនាមជាក្រុមប្រឹក្សាខណ្ឌរបស់ខ្លួនមានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រា រដ្ឋបាលខណ្ឌចំការមនលើៈ

- ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខណ្ឌចំការមនបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាខណ្ឌចំការមន
- កំណត់ហេតុប្រជុំដែលអង្គប្រជុំក្រុមប្រឹក្សាខណ្ឌចំការមនបានអនុម័តរួច
- សំណើដកហូតអភិបាលខណ្ឌ ឬអភិបាលរងខណ្ឌចេញពីមុខតំណែងតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាខណ្ឌចំការមន
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាខណ្ឌ
- ប្រតិទិនប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌចំការមនសម្រាប់រយៈពេល១២ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាខណ្ឌចំការមន

[6] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

- កិច្ចការដទៃទៀតតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។[7]

គណៈអភិបាលខណ្ឌចំការមន ត្រូវជួយក្រុមប្រឹក្សាខណ្ឌរបស់ខ្លួននៅក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែ ឯកសារសម្រាប់រៀបចំកិច្ចប្រជុំទាក់ទងនឹងសំណើដកហូតអភិបាលខណ្ឌចំការមន ឬអភិបាលរងខណ្ឌចំការមនចេញពីមុខតំណែង។ ក្រុមប្រឹក្សាខណ្ឌចំការមនប្រើប្រាស់សិទ្ធិអំណាច ដែលត្រូវបានកំណត់ដោយអនុក្រឹត្យលេខៈ២៨៦អនក្រ.បក ស្តីពីនីតិវិធីសម្រាប់ការរៀបចំការកែប និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី/ខេត្ត ក្រុង / ស្រុក / ខណ្ឌ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤។

### ៣.១.២. របៀបរបបការងាររបស់ក្រុមប្រឹក្សាខណ្ឌចំការមន

ការអនុវត្តនូវសិទ្ធិអំណាចរបស់ខ្លួន ក្រុមប្រឹក្សាខណ្ឌចំការមនត្រូវពិនិត្យពិចារណាលើចំណុចសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងរបៀបរបបការងារដូចខាងក្រោម ៖

- ក្នុងការអនុវត្តមុខងារ និងភារកិច្ចដែលបានទទួលអំណាចប្រតិភូកម្មពីក្រុមប្រឹក្សា រាជធានី ក្រុមប្រឹក្សាខណ្ឌចំការមនមានអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិតាមរយៈដីកា និងសេចក្តីសម្រេចខាងប្រតិបត្តិ រាល់សេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ ត្រូវធ្វើឡើងក្នុងអង្គប្រជុំក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន ហើយត្រូវធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដានវាយតម្លៃជាប្រចាំ។[8]
- ក្រុមប្រឹក្សាខណ្ឌ អាចចាត់ឲ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឲ្យ បង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី / ខេត្ត ក្រុង / ស្រុក / ខណ្ឌ ឬអាចបង្កើតគណៈ កម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានា ដើម្បីស្រាវជ្រាវ រៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេច តាមការចាំបាច់។ គណៈអភិបាលខណ្ឌចំការមន ត្រូវដឹកនាំនាយករដ្ឋបាលសាលាខណ្ឌ និងការិយាល័យពាក់ព័ន្ធនៃសាលាខណ្ឌដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ ព្រមទាំងធ្វើការសម្របសម្រួល ណែនាំដល់ការិយាល័យនានានៃសាលាខណ្ឌចំការមន ក្នុងការរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចដើម្បីដាក់ជូនក្រុមប្រឹក្សាខណ្ឌពិនិត្យ ពិភាក្សា និងអនុម័ត។ លើសពីនេះទៀត ក្នុងការរៀបចំសេចក្តីព្រាងដីកា ឬព្រាងសេចក្តីសម្រេច នាយករដ្ឋបាលសាលាខណ្ឌចំការមន

[7] មាត្រា៧១ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

[8] មាត្រា៦៨ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

អាចស្នើសុំធ្វើការ អ្នកពិគ្រោះយោបល់ជាមួយនាយករដ្ឋបាលសាលារាជធានី។ អភិបាលខណ្ឌចំការមន ត្រូវណែនាំ នាយករដ្ឋបាលសាលាខណ្ឌចំការមន ឲ្យរៀបចំដីកា សេចក្តីសម្រេចដែលក្រុមប្រឹក្សាខណ្ឌ បានអនុម័តរួចឱ្យស្របតាមទម្រង់ដែលបានកំណត់ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាខណ្ឌចុះហត្ថលេខា ក្នុងនាមក្រុមប្រឹក្សាខណ្ឌ និងត្រូវប្រថាប់ត្រារដ្ឋបាលខណ្ឌ[9]

ក្រុមប្រឹក្សាខណ្ឌចំការមន ត្រូវចាត់ឲ្យអភិបាលខណ្ឌចំការមនមានការចាត់ចែងផ្សព្វផ្សាយ ជាសាធារណៈ ជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខណ្ឌបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះព្រមទាំងចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាព។

### ៣.១.៣ .កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌចំការមន

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌចំការមន មានពីរប្រភេទ ៖

- **កិច្ចប្រជុំសាមញ្ញៈ** ក្រុមប្រឹក្សា ត្រូវប្រជុំសាមញ្ញយ៉ាងហោចណាស់ចំនួន១២ដង ក្នុងមួយឆ្នាំ
- **ការប្រជុំវិសាមញ្ញៈ** ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមចាំបាច់ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេស។

កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញអាចយកជាការបាន លុះត្រាតែកិច្ចប្រជុំទាំងនេះបានប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាខណ្ឌចំការមន ។ សេចក្តីសម្រេចទាំងឡាយណា ដែលធ្វើឡើងមិនស្រប នឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាខណ្ឌ រដ្ឋធម្មនុញ្ញ ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត នោះសេចក្តីសម្រេចពុំអាចមានសុពលភាពឡើយ។

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាខណ្ឌចំការមន ត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលខណ្ឌ និងជាវិធានការបែបបទ នីតិវិធីការងារតាមការចាំបាច់ដែលទាក់ទងទៅនឹង ៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីដែលបានធ្វើប្រតិភូកម្មពីក្រុមប្រឹក្សារាជធានី
- ការអនុវត្តមុខងារ និងភារកិច្ចដែលបានធ្វើប្រតិភូកម្មពីក្រុមប្រឹក្សារាជធានី
- ការអនុវត្តគម្រោង និងកម្មវិធីអភិវឌ្ឍនានារបស់ខណ្ឌ
- ការងារហិរញ្ញវត្ថុ ថវិកា និងក្របខណ្ឌចំណាយរយៈពេលមធ្យមតាមការកំណត់
- បញ្ហាហិរញ្ញវត្ថុផ្សេងៗទៀតរបស់ក្រុមប្រឹក្សាខណ្ឌ

[9] មាត្រា៧០ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សា ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាខណ្ឌចំការមន ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលខណ្ឌចំការមន
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជន នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌចំការមន រួមទាំងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់ និងការផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌ
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌ
- កិច្ចការផ្សេងទៀត ដែលកំណត់ដោយច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុទ្ធនានា។[10]

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាខណ្ឌចំការមន ត្រូវធ្វើការសម្រេចដូចរៀបរាប់ខាងលើ ក្រុមប្រឹក្សាខណ្ឌចំការមន អាចធ្វើការសម្រេចនៅក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញនូវកិច្ចការផ្សេងៗទៀតរួមមាន ៖

- ការកោះអញ្ជើញអភិបាលខណ្ឌចំការមន ឬអភិបាលរង ឬគណៈអភិបាលខណ្ឌចំការមន ឬបុគ្គលដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌចំការមន ឬហេតុការណ៍ណាមួយដែលកើតមានក្នុងខណ្ឌ ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយព្រមទាំងកិច្ចការផ្សេងទៀត ដែលពាក់ព័ន្ធដល់រដ្ឋបាលខណ្ឌ
- ការសម្រេចឲ្យមានការសិក្សាស្រាវជ្រាវ ឬបើកការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាខណ្ឌយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋខ្លួនជាតំណាង និងសម្រេចឲ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សា ស្រាវជ្រាវ ឬការធ្វើអង្កេតនេះព្រមទាំងណែនាំដល់គណៈអភិបាលខណ្ឌចំការមនអំពី វិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ
- ការពិនិត្យស្រាវជ្រាវ និងការធ្វើសេចក្ដីរាយការណ៍ទៅក្រសួងមហាផ្ទៃក្នុងករណីមានការរំលោភអំណាចកើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យ និងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដែលប្រព្រឹត្តដោយក្រុមប្រឹក្សាខណ្ឌ ឬសមាជិកក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ អភិបាលរងខណ្ឌ ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន

[10] មាត្រា៧២ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

- ការពិនិត្យ និងដោះស្រាយឲ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ានានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំរៀបចំដោយគណៈអភិបាលខណ្ឌ
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌយល់ឃើញថាមានការចាំបាច់ ។[11]

## ៣.២. គណៈអភិបាលខណ្ឌចំការមន

### ៣.២.១. តួនាទីរបស់គណៈអភិបាលខណ្ឌចំការមន

គណៈអភិបាលខណ្ឌចំការមន មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គណៈអភិបាលខណ្ឌចំការមន ត្រូវធ្វើកិច្ចការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខណ្ឌចំការមន អំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាខណ្ឌចំការមន ដើម្បីក្រុមប្រឹក្សាខណ្ឌចំការមនធ្វើការពិភាក្សា អនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង ៖
  - ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានធ្វើប្រតិភូកម្មក្រុមប្រឹក្សាខណ្ឌចំការមន និងរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
  - ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ពន្ធ ប្រព័ន្ធ និងធនធានដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រតិភូកម្មពីរដ្ឋបាលរាជធានី ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី / ខេត្ត ក្រុង / ស្រុក / ខណ្ឌ
  - ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានី
  - ក្របខណ្ឌចំណាយរយៈពេលមធ្យម និងការធ្វើបច្ចុប្បន្នភាព
  - ការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់ខណ្ឌ
  - ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
  - ការងារបុគ្គលិក និងក្របខណ្ឌ
  - ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក

[11] មាត្រា៧៣ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិក
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាខណ្ឌចំការមន គណៈអភិបាលខណ្ឌចំការមន និងបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាខណ្ឌចំការមន ពិនិត្យ និងអនុម័ត មិនឲ្យលើសពី៤៥ថ្ងៃបន្ទាប់ពីដំណាច់ឆ្នាំនីមួយៗដែលពាក់ព័ន្ធនឹង ៖
  + ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាខណ្ឌ និងសកម្មភាព
  + លទ្ធផលនៃការអនុវត្តបញ្ជាហិរញ្ញវត្ថុ និងថវិកា
  + វាយតម្លៃ អំពីការបំពេញការងាររបស់គណៈអភិបាលខណ្ឌ និងបុគ្គលិកក្រុមប្រឹក្សាខណ្ឌចំការមន
  + វិធានការចាំបាច់ដើម្បីធ្វើឲ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាខណ្ឌចំការមន
  + វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
  + កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាខណ្ឌយល់ឃើញថា មានភាពចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន
- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាម ការចាំបាច់ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- ការរៀបចំយុទ្ធសាស្ត្រ ផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារព័ត៌មានការបិទផ្សព្វផ្សាយនៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយដើម្បីផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន ។[12]

នៅពេលបានទទួលរបាយការណ៍ ឬព័ត៌មានអំពីការរំលោភអំណាច គណៈអភិបាលខណ្ឌចំការមន ត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើមានរកឃើញថា មានរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលខណ្ឌចំការមន ត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ទៅក្រុមប្រឹក្សាខណ្ឌ និងធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារាជធានី។

[12] មាត្រា៨៨ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

អភិបាលខណ្ឌចំការមន មានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងខណ្ឌ ។ នៅក្នុងតួនាទីជាតំណាងនេះអភិបាលខណ្ឌចំការមនត្រូវ ៖

- ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីច្បាប់ និងធានាឲ្យមានការអនុវត្តច្បាប់ព្រមទាំងធានាឲ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងខណ្ឌចំការមន
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពខណ្ឌនៅក្នុងការដឹកនាំសម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា និងសង្កាត់ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅក្នុងខណ្ឌ[13]
- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងាររបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខណ្ឌចំការមនឲ្យអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការិយាល័យអង្គភាព និងទីភ្នាក់ងារនីមួយៗ
- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ននានាដែលប្រចាំនៅខណ្ឌ ដើម្បីឆ្លើយតបទៅនេងតម្រូវការជាអាទិភាពនៅមូលដ្ឋាននោះ។ នៅក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធទៅដល់ជាច្រើនវិស័យ អភិបាលខណ្ឌចំការមន ត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាព ទីភ្នាក់ងារ ពាក់ព័ន្ធដើម្បីសហការអនុវត្តកិច្ចការ ដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាខណ្ឌ អភិបាលខណ្ឌចំការមន ត្រូវសម្របសម្រួលតម្រង់ទិសការិយាល័យ អង្គភាព ក៏ដូចជា ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខណ្ឌចំការមន នៅក្នុងការធ្វើសមាហរណកម្មផែនការ ក៏ដូចជា ថវិការបស់ខ្លួនដើម្បីឆ្លើយតបតម្រូវការជាអាទិភាពរបស់ខណ្ឌ
- ពិនិត្យ វាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានាដែលប្រចាំនៅក្នុងខណ្ឌចំការមន
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌចំការមនជាមុន ក្នុងការផ្តល់យោបល់ទៅលើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យ និងអង្គភាពនៃក្រសួង ស្ថាប័ន ប្រចាំនៅខណ្ឌរបស់ខ្លួន។ ករណីមិនគាំទ្របេក្ខភាពដែលស្នើតែងតាំងខាងលើនេះ អភិបាលខណ្ឌចំការមនត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ

[13] មាត្រា៩៥ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

ដោយបញ្ជាក់ច្បាស់អំពីហេតុផលនៃការមិនគាំទ្រនេះ ជូនអភិបាលរាជធានីធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរ និងអង្គភាពសាមីមុននឹងធ្វើសេចក្ដីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី

- រាយការណ៍ជាលាយលក្ខណ៍អក្សរ និងជាបន្ទាន់ទៅអភិបាលរាជធានីនៅក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យ អង្គភាព និងទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងខណ្ឌរបស់ខ្លួន ឬនៅក្នុងករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យអង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី ភារកិច្ចរបស់ខ្លួន។ អភិបាលរាជធានី ត្រូវណែនាំដល់មន្ទីរ អង្គភាពខ្សែបណ្ដោយសាមីនៅថ្នាក់រាជធានីដើម្បីស្រាវជ្រាវអំពីបញ្ហានេះ ឬចាត់តាំងគណៈកម្មការ ឬក្រុមការងារដែលមានការចូលរួមអំពីរដ្ឋបាលខណ្ឌពាក់ព័ន្ធឲ្យធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីធ្វើសេចក្ដីរាយការណ៍ជូនមន្ត្រី ឬប្រធានស្ថាប័នសាមីដោះស្រាយស្របតាមនីតិវិធី
- មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលរាជធានី ដើម្បីចាត់វិធានការផ្លាស់ប្ដូរ ឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ហើយដែលមិនអាចធ្វើយុត្តកម្មបាន។[14]

សេចក្ដីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំរបស់ការិយល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខណ្ឌត្រូវដាក់ជូនអភិបាលខណ្ឌចំការមន ដើម្បីពិនិត្យ និងផ្ដល់យោបល់។ ហើយប្រសិនបើអភិបាលខណ្ឌចំការមនឯកភាព អភិបាលខណ្ឌចំការមន ត្រូវចុះហត្ថលេខាលើរបាយការណ៍នោះ រួមជាមួយប្រធានការិយាល័យអង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។ ចំពោះសេចក្ដីរាយការណ៍ក្រៅពីនោះ ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខណ្ឌចំការមន ត្រូវចម្លងជូនសាលាខណ្ឌ។

### ៣.២.២. របៀបរបបការងាររបស់គណៈអភិបាលខណ្ឌចំការមន

នៅក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន គណៈអភិបាលខណ្ឌចំការមន អភិបាលខណ្ឌចំការមន អភិបាលរងខណ្ឌចំការមន ត្រូវពិនិត្យ ពិចារណាលើចំណុចសំខាន់ៗដែលពាក់ព័ន្ធនឹងរបៀបរបបអនុវត្តការងារដូចខាងក្រោម ៖

- នៅក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលខណ្ឌ ត្រូវគោរពគោលនយោបាយរាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំរបស់រាជរដ្ឋាភិបាល ស្ថាប័ននានា និងត្រូវមាន

[14] មាត្រា៩៤ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា និងការណែនាំពីអភិបាលរាជធានីស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា [15]

- ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន និងការងារផ្សេងៗទៀតដែលខ្លួនយល់ឃើញថាជាការចាំបាច់ អភិបាលខណ្ឌចំការមន ត្រូវតែយកការងារទាំងនោះមកពិគ្រោះពិភាក្សានៅក្នុងជួរ គណៈអភិបាលខណ្ឌរបស់ខ្លួនដោយឈរលើគោលការណ៍ច្បាប់ និងលិខិតបទដ្ឋាន និងគតិយុត្តនានាព្រមទាំងការសម្រេច និងគោលការណ៍ណែនាំពីក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន[16]
- អភិបាលខណ្ឌចំការមន ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាខណ្ឌ អំពីសកម្មភាព ការងារទាំងអស់របស់គណៈអភិបាលខណ្ឌរបស់ខ្លួន។ អភិបាលរងខណ្ឌត្រូវទទួលខុសត្រូវចំពោះមុខអភិបាលខណ្ឌលើភារកិច្ចនានាដែលបានប្រគល់ជូន ហើយត្រូវរួមជាមួយអភិបាលខណ្ឌទទួលខុសត្រូវអំពីការសម្រេច និង សកម្មភាពក្នុងគណៈអភិបាលខណ្ឌរបស់ខ្លួន
- ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារទាំងនេះ គណៈអភិបាលខណ្ឌចំការមន ត្រូវជួបប្រជុំប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗ ជាការប្រជុំប្រចាំខែ។ ក្រៅពីមានការប្រជុំប្រចាំអឌ្ឍមាស និងការប្រជុំប្រចាំខែ គណៈអភិបាលខណ្ឌចំការមនអាចកោះប្រជុំតាមការចាំបាច់
- គណៈអភិបាលខណ្ឌចំការមន ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលខណ្ឌ និងអភិបាលរងខណ្ឌចំការមន ហើយសុំការសម្រេចពីក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន។ អភិបាលរងខណ្ឌចំការមន ដែលបានទទួលការបែងចែក ភារកិច្ចនេះត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួននៅចំពោះមុខអភិបាលខណ្ឌចំការមន
- អភិបាលខណ្ឌចំការមន ចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តន៍សេចក្តីសម្រេចនៃក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន លើកលែងតែ ករណីលិខិតបទដ្ឋានដែលតម្រូវឲ្យប្រធានក្រុមប្រឹក្សាខណ្ឌចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន។ អភិបាលខណ្ឌចំការមន អាចប្រគល់សិទ្ធិដល់អភិបាលរងខណ្ឌនៅក្នុងការចុះហត្ថលេខាទៅលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួនក្នុងក្របខណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងខណ្ឌនីមួយៗ។ ក៏ប៉ុន្តែ អភិបាលខណ្ឌចំការមន ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទនីតិវិធីចំពោះឯកសារលិខិត

---

[15] មាត្រា៩៧ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

[16] មាត្រា៩០ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

ស្នាមដែលប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងខណ្ឌចំការមន ។ អភិបាលខណ្ឌចំការមន មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងខណ្ឌណាមួយ ដែលប្រើប្រាស់អំណាចមិនស្របច្បាប់ និងមិនស្របតាមបែបបទនីតិវិធី។ ការប្រគល់ និងដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាអភិបាលខណ្ឌចំការមន ត្រូវរាយការណ៍ក្រុមប្រឹក្សាខណ្ឌ[17]

- ក្នុងករណីអភិបាលខណ្ឌចំការមន អវត្តមាន អភិបាលខណ្ឌចំការមន ត្រូវផ្ទេរសិទ្ធិលាយលក្ខណ៍អក្សរជូនអភិបាលរងខណ្ឌចំការមនមួយរូបឲ្យទទួលជាអភិបាលខណ្ឌចំការមនស្តីទី។ ប្រសិនបើអភិបាលខណ្ឌចំការមន អវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងខណ្ឌដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃប្រកាសតែងតាំង និងអភិបាលរងនៃគណៈអភិបាលខណ្ឌចំការមន ត្រូវធ្វើជាអភិបាលខណ្ឌចំការមនស្តីទី។ នៅក្នុងករណីអភិបាលស្តីទីអវត្តមាន អភិបាលរាជធានីត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងខណ្ឌមួយរូបឲ្យទទួលជាអភិបាលស្តីទីនឹងត្រូវធ្វើសេចក្តីរាយការណ៍ជូនទៅរដ្ឋបាលរាជធានីដើម្បីរដ្ឋបាលរាជធានីធ្វើសេចក្តីរាយការណ៍ មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលខណ្ឌចំការមន ស្តីទីត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលខណ្ឌចំការមន នៅពេលដែលអភិបាលខណ្ឌមានវត្តមានវិញ។ [18]

## ៣.៣. ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌចំការមន

ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌចំការមនមានដូចខាងក្រោម ៖

- អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ ដែលក្រុមប្រឹក្សាខណ្ឌចំការមន បានសម្រេចរួចគណៈអភិបាលខណ្ឌចំការមនត្រូវទទួលខុសត្រូវចាត់ចែងអនុវត្តនៅក្នុងនាមក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន។ ដូច្នេះគណៈអភិបាលខណ្ឌគឺជាអ្នកអនុវត្តទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- ក្រុមប្រឹក្សា ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាល ដើម្បីធានាថាគណៈអភិបាលខណ្ឌចំការមន អនុវត្តកិច្ចការទាំងនោះឲ្យបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សា

[17] មាត្រា៩៣ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

[18] មាត្រា៩៩ នៃអនុក្រឹត្យលេខ២១៥អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

- គណៈអភិបាលខណ្ឌចំការមន ត្រូវធ្វើសេចក្ដីរាយការណ៍ជូនក្រុមប្រឹក្សាខណ្ឌរបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌ
- គណៈអភិបាលខណ្ឌចំការមន ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាខណ្ឌរបស់ខ្លួនអំពីការអនុវត្តសេចក្ដីសម្រេចនានារបស់ក្រុមប្រឹក្សាខណ្ឌ និងមានគណនេយ្យភាព ចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតគតិយុត្តនានា
- អភិបាលខណ្ឌចំការមន ដោយមាននាយករដ្ឋបាលសាលាខណ្ឌជាជំនួយការ ត្រូវរៀបចំសេចក្ដីរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការអនុវត្តតួនាទី ជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័ននានាព្រមទាំងស្ថានភាពនៃការងារទាំងនោះក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដើម្បី រាយការណ៍ជូនក្រុមប្រឹក្សា
- ក្នុងករណីមានបញ្ហាណាមួយ ដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលខណ្ឌចំការមន ក្នុងនាមជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារតវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាខណ្ឌអាចតម្រូវឲ្យអភិបាលខណ្ឌចំការមនធ្វើសេចក្ដីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាខណ្ឌ
- ក្រុមប្រឹក្សាខណ្ឌចំការមន អាចផ្ដល់អនុសាសន៍ និងការណែនាំដល់អភិបាលអំពីការអនុវត្តតួនាទីខាងលើនេះដើម្បីឆ្លើយតបតម្រូវការជាអាទិភាព និងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។ អភិបាលត្រូវទទួលយកអនុសាសន៍ និងការណែនាំក្រុមប្រឹក្សាខណ្ឌរបស់ខ្លួនដើម្បីធ្វើការណែនាំ សម្របសម្រួល និងតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងាររបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខណ្ឌក្នុងការឆ្លើយតបនៅតម្រូវការទាំងនោះហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សាខណ្ឌរបស់ខ្លួនវិញ។

ក្រៅពីទំនាក់ទំនងនានាដូចបានរៀបរាប់ខាងលើ ទំនាក់ទំនងរវាងក្រុមប្រឹក្សាខណ្ឌចំការមន និងគណៈអភិបាលខណ្ឌក៏បានកំណត់ក្នុងតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌផងដែរ។

### ៣.៤. គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខណ្ឌចំការមន

គណៈកម្មាធិការចំនួនបី ដែលក្រុមប្រឹក្សាខណ្ឌចំការមន មានកាតព្វកិច្ចបង្កើតឡើងគឺ៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

ក្រៅពីគណៈកម្មាធិការជាកាតព្វកិច្ចទាំងបីខាងលើនេះ ក្រុមប្រឹក្សាខណ្ឌចំការមនអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់។ គណៈកម្មាធិការដែលបង្កើតបន្ថែមនេះ មិនត្រូវមានតួនាទី និងភារកិច្ចត្រួតគ្នាជាមួយនឹងតួនាទី ភារកិច្ចរបស់គណៈកម្មាធិការជាកាតព្វកិច្ចទាំងបីឡើយ។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សាខណ្ឌចំការមន អាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗទៀតតាមការស្នើសុំរបស់គណៈកម្មាធិការនានា ឬគណៈអភិបាលខណ្ឌ។ អនុគណៈ កម្មាធិការ ឬក្រុមការងារខាងលើនេះត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការ ឬគណៈអភិបាលខណ្ឌចំការមន ។

ក្នុងការរៀបចំបង្កើតគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាខណ្ឌត្រូវពិនិត្យពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម៖

- ក្រុមប្រឹក្សាខណ្ឌចំការមន អាចតែងតាំងសមាជិកជាក្រុមប្រឹក្សា អភិបាលខណ្ឌចំការមន អភិបាលរងតំណាងក្រុមប្រឹក្សាសង្កាត់ បុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌ តំណាងសហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់សម្រាប់ជាសមាជិកគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង
- ក្រុមប្រឹក្សាខណ្ឌចំការមន ត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬក្រុមការងារនីមួយៗការតែងតាំងប្រធាន អនុប្រធាន និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាដែលខ្លួនបានបង្កើត
- គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងតំណែងប្រធាន ឬអនុប្រធានគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ
- ក្រុមប្រឹក្សាខណ្ឌចំការមន អាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើងតាមការចាំបាច់ ឬតាមសំណើរបស់គណៈកម្មាធិការ ឬគណៈអភិបាលខណ្ឌចំការមន[19]
- គណៈអភិបាលខណ្ឌចំការមន អាចស្នើសុំក្រុមប្រឹក្សាខណ្ឌចំការមនដើម្បីឲ្យគណៈកម្មាធិការ ឬអនុ-គណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សាខណ្ឌចំការមន បានបង្កើតឡើងរួមទាំងគណៈកម្មាធិការជាកាតព្វកិច្ចទាំងបីខាងលើ ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួនដែល

[19]មាត្រា ៧៨ នៃអនុក្រឹត្យលេខៈ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

ស្ថិតនៅក្នុងសមត្ថកិច្ចរបស់គណៈអភិបាលខណ្ឌ[20]

- ក្រុមប្រឹក្សាខណ្ឌ ត្រូវទទួលខុសត្រូវរាល់ការសម្រេច និងសកម្មភាពរបស់គណៈកម្មាធិការនានា និងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនេះ[21]
- ក្រុមប្រឹក្សាខណ្ឌ ត្រូវណែនាំឲ្យគណៈអភិបាលខណ្ឌផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់ និងបច្ចេកទេសព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការជាកាតព្វកិច្ចទាំងបី ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាខណ្ឌបានបង្កើតឡើង[22]
- គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និង តាមតម្រូវការចាំបាច់នានា។ សេចក្តីរាយការណ៍នេះត្រូវចម្លងជូនគណៈអភិបាលដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនក្រុមប្រឹក្សាខណ្ឌ។ ក្រុមប្រឹក្សាខណ្ឌ អាចតម្រូវឲ្យគណៈកម្មាធិការណាមួយរាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេស និងបន្ទាន់ណាមួយនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាតាមការចាំបាច់។ [23]

## ៣.៤.១.គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

ក្រុមប្រឹក្សាខណ្ឌត្រូវរៀបចំឲ្យមានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ខ្លួន ដើម្បីជួយសិក្សា និងផ្តល់យោបល់ដល់ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌរបស់ខ្លួនលើបញ្ហាទាក់ទងនឹងការងារផែនការថវិកា ការសម្របសម្រួលកិច្ចការនានាជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀត និងបញ្ហាទាក់ទងនឹងមុខងារ ធនធានដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មឲ្យក្រុមប្រឹក្សាខណ្ឌ ។

### ៣.៤.១.១.សមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

គណៈកម្មាធិការនេះមានសមាសភាពដូចខាងក្រោម៖

- អភិបាលខណ្ឌចំការមន ប្រធាន
- អភិបាលរងខណ្ឌចំការមន ០១រូប អនុប្រធាន
- នាយករដ្ឋបាលសាលាខណ្ឌចំការមន សមាជិកអចិន្ត្រៃយ៍

[20] មាត្រា ៧៩ នៃអនុក្រឹត្យលេខៈ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

[21] មាត្រា ៨០ នៃអនុក្រឹត្យលេខៈ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

[22] មាត្រា ៨១ នៃអនុក្រឹត្យលេខៈ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

[23] មាត្រា ៨២ នៃអនុក្រឹត្យលេខៈ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

- សមាជិកក្រុមប្រឹក្សាខណ្ឌចំការមន យ៉ាងតិច ០២រូប សមាជិក
- ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅខណ្ឌចំការមន សមាជិក
- ប្រធានការិយាល័យទាំងអស់របស់សាលាខណ្ឌចំការមន សមាជិក
- ចៅសង្កាត់ទាំងអស់នៅក្នុងខណ្ឌចំការមន សមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាខណ្ឌ ០១រូប សមាជិក

អនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវស្នើដោយអភិបាលខណ្ឌចំការមន ។ ក្រុមប្រឹក្សាខណ្ឌចំការមន ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស។

### ៣.៤.១.២.តួនាទី និងភារកិច្ចគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមានតួនាទី និងភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សាខណ្ឌចំការមន និងគណៈអភិបាលខណ្ឌចំការមនលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

**ក.ផែនការអភិវឌ្ឍន៍ និងថវិកា**

- សេចក្តីព្រាង ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំដើម្បីដាក់បញ្ចូលនៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានី
- សេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- សេចក្តីព្រាងក្របខណ្ឌចំណាយរយៈពេលមធ្យម និងការធ្វើបច្ចុប្បន្នភាព
- កៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានាដល់គម្រោងវិនិយោគខណ្ឌ
- របាយការណ៍រីកចម្រើននានាទាក់ទងការងារផែនការអភិវឌ្ឍន៍កម្មវិធីវិនិយោគ។

**ខ.សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាជាមួយការិយាល័យអង្គភាពរបស់ក្រសួង ស្ថាប័ននានា**

- កិច្ចសហប្រតិបត្តិការ ការពិគ្រោះយោបល់ និងការសម្របសម្រួលកិច្ចការនានា របស់ក្រុមប្រឹក្សាខណ្ឌចំការមន ជាមួយការិយាល័យអង្គភាពរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលការផ្តល់សេវា និងការអភិវឌ្ឍដែលផ្តល់ដោយក្រសួង ស្ថាប័ន ឬដោយការិយាល័យអង្គភាពរបស់ក្រសួង ស្ថាប័នដើម្បីឆ្លើយតបតម្រូវការ
- ការសម្របសម្រួលភាពមិនចុះសម្រុងគ្នារវាងកិច្ចការរបស់ក្រុមប្រឹក្សាខណ្ឌ ជាមួយក្រសួង ស្ថាប័ន មន្ទីរ ការិយាល័យ អង្គភាពជំនាញនានា
- ការផ្តល់អនុសាសន៍ដើម្បីកែលម្អការផ្តល់សេវា និងការអភិវឌ្ឍន៍នានាស្របតាមតម្រូវការរបស់មូលដ្ឋាន

**គ.កិច្ចសហប្រតិបត្តិការ និងសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពខណ្ឌចំការមន**

- ការរៀបចំយន្តការពិគ្រោះយោបល់ និងការចូលរួមក្នុងដំណើរការអនុវត្តការងារនៃរដ្ឋបាលឯកភាពខណ្ឌ
- ការរៀបចំប្រព័ន្ធ និងនីតិវិធីបំពេញការងារព្រមទាំងទំនាក់ទំនងរបស់ការិយាល័យនានានៃសាលាខណ្ឌ
- ការសម្របសម្រួលនូវភាពមិនចុះសម្រុងគ្នា ក្នុងការអនុវត្តការងារការិយាល័យនានានៃសាលាខណ្ឌ។

**ឃ.កិច្ចសហប្រតិបត្តិការនិងសម្របសម្រួលរវាងក្រុមប្រឹក្សាខណ្ឌជាមួយក្រុមប្រឹក្សាសង្កាត់នៅក្នុងខណ្ឌចំការមន**

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាខណ្ឌ ជាមួយនឹងក្រុមប្រឹក្សាខណ្ឌ និងរវាងក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់នៅក្នុងខណ្ឌ
- ការឆ្លើយតបចំពោះអនុសាសន៍ សំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាសង្កាត់នៅក្នុងករណីដែលក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបាន
- ដោះស្រាយនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ និងរវាងក្រុមប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សាសង្កាត់។

**ង. ការងារទាក់ទងមុងងារ និងធនធាន**

- វិធានការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារ និងធនធានដែលបានផ្ទេរប្រតិភូកម្ម
- ការរៀបចំនូវលក្ខណសម្បត្តិ និងមធ្យោបាយដើម្បីទទួល និងអនុវត្តមុខងារ និងធនធានដែលបានប្រតិភូកម្មឲ្យរដ្ឋបាលខណ្ឌ
- ការផ្តួចផ្តើមស្នើឡើងនូវមុខងារ ក៏ដូចជា ធនធាន ដែលគួរត្រូវបានផ្ទេរប្រតិភូកម្មឲ្យមករដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់
- ការវាយតម្លៃលើការអនុវត្តមុខងារ និងធនធាន ដែលបានផ្ទេរប្រតិភូកម្មដោយរដ្ឋបាលរាជធានី។[24]

ក្រៅពីកិច្ចការខាងលើនេះ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសអាចទទួលអនុវត្តកិច្ចការផ្សេងទៀតតាមតម្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ឬតាមការប្រគល់ភារកិច្ចក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន ។

**៣.៤.១.៣.របបការងារគណៈកម្មាធិការ**

ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសត្រូវពិនិត្យ ពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខណ្ឌចំការមន ត្រូវជួបប្រជុំយ៉ាងតិចពីរខែ

[24] មាត្រា១៣ នៃអនុក្រឹត្យលេខៈ២១៧.អនក្រ.បកស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សារាជធានីភ្នំពេញ និង គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ

ម្តង។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងមូលចូលរួម។ សេចក្តីសម្រេចនៃកិច្ចប្រជុំ អាចយកជាការបានលុះត្រាមានសំឡេងអនុម័តលើសពីពាក់កណ្តាលចំនួនសមាជិកគណៈកម្មាធិការទាំងមូល។ ប្រធានគណៈកម្មាធិការជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ ។ គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការ ត្រូវមានកំណត់ហេតុដែលរៀបចំឡើងដោយនាយករដ្ឋបាលសាលាខណ្ឌចំការមន និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ ។ គណៈកម្មាធិការអាចកំណត់អំពីរបៀបរបបប្រជុំ ការអនុម័តរបៀបរបបការងារជាក់ស្តែង និងការបែងចែកភារកិច្ចដល់សមាជិកគណៈកម្មាធិការតាមការចាំបាច់[25]

- នៅក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការ ដែលជានាយករដ្ឋបាលសាលាខណ្ឌចំការមន ចៅសង្កាត់ ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅខណ្ឌចំការមន នៅការិយាល័យនៃសាលាខណ្ឌចំការមន អវត្តមានសមាជិកនោះអាចចាត់តំណាងដែលមានសិទ្ធិសម្រេចជំនួសខ្លួន ឲ្យចូលរួមប្រជុំគណៈកម្មាធិការបាន[26]
- អភិបាលខណ្ឌចំការមន អាចស្នើឲ្យអភិបាលរងខណ្ឌ មន្ត្រីទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធនានាចូលរួមកិច្ចប្រជុំគណៈកម្មាធិការតាមការចាំបាច់។ អភិបាលរងខណ្ឌចំការមន មន្ត្រីទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធទាំងនោះអាចផ្តល់ជាយោបល់នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការបានក៏ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ[27]
- នៅក្នុងកិច្ចប្រជុំនីមួយៗរបស់គណៈកម្មាធិការត្រូវមានរបៀបវារៈដែលបានត្រៀមរៀបចំជាមុន។ អភិបាលខណ្ឌចំការមន និងជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសដោយមាននាយករដ្ឋបាលសាលាខណ្ឌចំការមន ជាជំនួយការត្រូវរៀបចំរបៀបវារៈប្រជុំ ដោយផ្អែកតាម៖
    - តម្រូវការរបស់ក្រុមប្រឹក្សាខណ្ឌចំការមន
    - តម្រូវការរបស់គណៈអភិបាលខណ្ឌចំការមន
    - តម្រូវការនៃច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត

---

[25] មាត្រា១៩ នៃអនុក្រឹត្យលេខ:២១៧.អនក្រ.បកស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សារាជធានីភ្នំពេញ និង គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ

[26] មាត្រា១៥ នៃអនុក្រឹត្យលេខ:២១៧.អនក្រ.បកស្តីពីការបង្កើត ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និង គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ

[27] មាត្រា១៦ នៃអនុក្រឹត្យលេខ:២១៧.អនក្រ.បកស្តីពីការបង្កើត ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និង គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ

- សំណើរបស់សមាជិក យ៉ាងតិចមួយភាគបីនៃចំនួនសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស។[28]

ផ្អែកតាមតម្រូវការ និងសំណើដូចដែលមានខាងលើអភិបាលខណ្ឌចំការមន ត្រូវពិគ្រោះយោបល់ក្នុងគណៈអភិបាលរបស់ខ្លួនចាត់ឲ្យការិយាល័យមួយ ឬច្រើនដែលពាក់ព័ន្ធនៃសាលាខណ្ឌចំការមន ដើម្បីសិក្សារៀបចំឯកសារ បែបបទនីតិវិធីនានាតាមរបៀបវារៈនីមួយៗ។ នាយករដ្ឋបាលសាលាខណ្ឌចំការមន ត្រូវដឹកនាំការិយាល័យដែលពាក់ព័ន្ធក្នុងសាលាខណ្ឌចំការមន រៀបចំឯកសារបែបបទនីតិវិធីខាងលើនេះដោយសហការជាមួយការិយាល័យ អង្គភាព ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលប្រចាំនៅខណ្ឌចំការមន និងរដ្ឋបាលដែលពាក់ព័ន្ធ តាមការ ចាំបាច់។ ជាមួយគ្នា នាយករដ្ឋបាលសាលាខណ្ឌចំការមន អាចស្នើសុំយោបល់ និងការគាំទ្រពីនាយករដ្ឋបាលសាលារាជធានីក្នុងការរៀបចំឯកសារបែបបទនីតិវិធីខាងលើនេះ។ លើសពីនេះទៀតក្នុងការសិក្សារៀបចំឯកសារ បែបបទនេះ នាយករដ្ឋបាលសាលាខណ្ឌចំការមន ត្រូវផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី / ខេត្ត ក្រុង / ស្រុក /ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលឃុំ / សង្កាត់ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់អនុវត្តច្បាប់ទាំងនេះព្រមទាំងការណែនាំពីក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី។ ក្រោយពេលរៀបចំឯកសារ បែបបទនីតិវិធីតាមរបៀបវារៈនីមួយៗ រួចហើយនាយករដ្ឋបាលសាលាខណ្ឌចំការមន ត្រូវដាក់ជូនអភិបាលខណ្ឌចំការមនដើម្បីពិនិត្យ និងរៀបចំកោះប្រជុំគណៈកម្មាធិការ។

- អភិបាលខណ្ឌចំការមន ដោយមាននាយករដ្ឋបាលសាលាខណ្ឌជាជំនួយការត្រូវរៀបចំរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ ដើម្បីដាក់ជូនក្រុមប្រឹក្សាខណ្ឌចំការមន ចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌចំការមន ដាក់ជូនទៅគណៈអភិបាលខណ្ឌចំការមន ចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់គណៈ អភិបាលខណ្ឌ។[29]
- ដើម្បីជួយសម្រួលដល់កិច្ចការរបស់ខ្លួន គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសអាចស្នើសុំបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារតាមការចាំបាច់ ឬតាមតម្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ឬតាមការណែនាំក្រុមប្រឹក្សា ឬគណៈអភិបាលរាជធានី។ សមាសភាពអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើនេះអាចជ្រើសចេញពីសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មន្ត្រីការិយាល័យពាក់ព័ន្ធនៃសាលាខណ្ឌ សមាជិកក្រុមប្រឹក្សាសង្កាត់ និងការិយាល័យអង្គភាពពាក់ព័ន្ធ

[28] មាត្រា១៧ នៃអនុក្រឹត្យលេខៈ២១៧.អនក្រ.បកស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ

[29] មាត្រា១៩ នៃអនុក្រឹត្យលេខៈ២១៧.អនក្រ.បកស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ

នានាតាមការចាំបាច់។ ក្រុមប្រឹក្សាខណ្ឌត្រូវសម្រេចអំពីការបង្កើតការរៀបចំ និងមានការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើនេះ។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខណ្ឌផ្អែកលើការសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន ។[30]

### **៣.៤.២.គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**

ក្រុមប្រឹក្សាខណ្ឌចំការមន ត្រូវរៀបចំឲ្យមានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារដែលមានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សាខណ្ឌចំការមន គណៈអភិបាលខណ្ឌចំការមន អភិបាលខណ្ឌចំការមន និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សាខណ្ឌលើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័របញ្ហាស្តីអំពី យុវវ័យ និងកុមារដែលស្ថិតនៅក្នុងអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌចំការមន ។

#### **៣.៤.២.១.សមាសភាព**

គណៈកម្មាធិការនេះត្រូវមានសមាសភាពដូចខាងក្រោម៖

- សមាជិកក្រុមប្រឹក្សាជាស្ត្រីជ្រើសរើសដោយក្រុមប្រឹក្សា ប្រធាន
- សមាជិកក្រុមប្រឹក្សាជ្រើសរើសដោយក្រុមប្រឹក្សា អនុប្រធាន
- អភិបាលរងជាស្ត្រី ០១រូប អនុប្រធាន
- ប្រធាន ឬអនុប្រធានមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា(បើមាន) អនុប្រធាន
- ប្រធាន ឬអនុប្រធានការិយាល័យកិច្ចការនារី អនុប្រធានអចិន្ត្រៃយ៍
- នាយករងរដ្ឋបាល ០១រូប សមាជិក
- ប្រធាន ឬអនុប្រធានការិយាល័យផែនការ សមាជិក
- ប្រធាន ឬអនុប្រធានការិយាល័យសុខាភិបាល សមាជិក
- ប្រធាន ឬអនុប្រធានការិយាល័យអភិវឌ្ឍន៍ជនបទ សមាជិក
- ប្រធាន ឬអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា សមាជិក
- ប្រធាន ឬ អនុប្រធានការិយាល័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(បើមាន) សមាជិក
- ប្រធាន ឬ អនុការិយាល័យកសិកម្ម សមាជិក
- អធិការ ឬតំណាងអធិការដ្ឋាននគរបាល សមាជិក
- ប្រធាន ឬអនុប្រធានការិយាល័យពាក់ព័ន្ធនៃសាលាខណ្ឌ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់

[30] មាត្រា២០ នៃអនុក្រឹត្យលេខៈ២១៧.អនក្រ.បកស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ

ចំណុះ សមាជិក

- តំណាងពីស្ថាប័ន ឬអង្គភាពផ្សេងទៀតតាមការចាំបាច់ សមាជិក

ក្រុមប្រឹក្សា មិនមានសមាជិកជាស្ត្រីត្រូវជ្រើសរើសយកអភិបាលរងខណ្ឌចំការមន ជាស្ត្រីដើម្បីជាប្រធាន គ.ក.ស.ក។ ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្រុមប្រឹក្សាខណ្ឌចំការមន ត្រូវខិតខំធានាឲ្យ មានសមាជិកជាស្ត្រីសមស្របក្នុងគណៈកម្មាធិការនេះ។ ក្រុមប្រឹក្សា ត្រូវចេញសេចក្តីសម្រេច ទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃ គ.ក.ស.ក របស់ខ្លួន។

**៣.៤.២.២.តួនាទី និងភារកិច្ច**

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ធ្វើការចូលរួមក្នុងការកសាងចក្ខុវិស័យជាយុទ្ធសាស្ត្រ សម្រាប់ការអភិវឌ្ឍន៍នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌដើម្បីធ្វើឲ្យសម្រេចបាននូវសមភាពយេនឌ័រ និងការផ្តល់សេវាផ្សេងៗ ដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ
- ប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួនដើម្បីបញ្ចូលទៅក្នុងផែនការ សកម្មភាព និងថវិការបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- ចូលរួមក្នុងការរៀបចំតាក់តែង ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខណ្ឌទាក់ទងនឹងការលើកកម្ពស់ និងការឆ្លើយតបលើបញ្ហាសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ
- ស្វែងរកការគាំទ្រពីក្រុមប្រឹក្សាខណ្ឌចំការមន ពីគណៈអភិបាលខណ្ឌចំការមន និងពីគណៈកម្មាធិការផ្សេងទៀតនៃក្រុមប្រឹក្សាខណ្ឌចំការមន ដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- សហការ និងផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងការដោះស្រាយបញ្ហា ឬសំណូមពរ ឬសំណើនានាដែលគណៈកម្មាធិការរបស់ក្រុមប្រឹក្សាប្រភេទផ្សេងនោះមិនអាចដោះស្រាយបានក្នុងការអនុវត្តមុខងាររបស់ខ្លួន
- លើកសំណើ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាខណ្ឌចំការមន គណៈអភិបាលខណ្ឌចំការមន អំពីវិធានការសមស្របនានាដើម្បីជំរុញឲ្យមានការចូលរួមអំពីសមត្ថកិច្ចពាក់ព័ន្ធ ក៏ដូចជា ប្រជាពលរដ្ឋក្នុងការ

ដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងពាក់ព័ន្ធនឹងកិច្ចការស្ត្រី យុវវ័យ និងកុមារ

- ស្វែងរក និងទទួលបានរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងការងាររបស់គណៈកម្មាធិការ
- ជំរុញការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយនានាទាក់ទងនឹង សមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារដល់សហគមន៍នានានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- ជំរុញឲ្យមានការប្រមូលព័ត៌មានរបស់សហគមន៍ អំពីបញ្ហាដែលបានកើតមានជា ប្រចាំពាក់ព័ន្ធនឹង សមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ និងមានវិធានការដើម្បីឆ្លើយតប
- ស្វែងរកការគាំទ្រ ដើម្បីជំរុញឲ្យស្ត្រីបានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការងារអភិវឌ្ឍ នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- លើកយោបល់ និងផ្តល់អនុសាសន៍អំពីការពង្រឹងទំនាក់ទំនងកិច្ចសហការ និងការសម្របសម្រួលរវាង ក្រុមប្រឹក្សាប្រភេទផ្សេងទៀត មន្ទីរ អង្គភាពពាក់ព័ន្ធនានា អ្នកផ្តល់សេវា អង្គការមិនមែនរដ្ឋាភិបាល ក្រុមអ្នកស្ម័គ្រចិត្ត និងសហគមន៍ដើម្បីធានា ថាសកម្មភាពទាំងឡាយត្រូវបានគាំទ្រដល់ស្ត្រី យុវវ័យ និងកុមារ
- ពិនិត្យមើលលើការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពរបស់ស្ត្រី យុវវ័យ និងកុមារ ជាពិសេសដើម្បីកំណត់រកគម្លាតផ្សេងៗនៅក្នុងការទទួលបានសេវានានា និងដើម្បីលើកអនុសាសន៍ ក្នុងការដោះស្រាយបញ្ហាទាំងនេះ
- រាយការណ៍ជូនក្រុមប្រឹក្សាខណ្ឌ លើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រ ការបង្កើតសមត្ថភាពដល់ស្ត្រី និងបញ្ហារបស់យុវវ័យ និងកុមារ ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌចំការមន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់របស់ក្រុមប្រឹក្សាខណ្ឌ។[31]

ក្រុមប្រឹក្សាខណ្ឌចំការមន ត្រូវផ្តល់ការគាំទ្រផ្នែកលេខាធិការដ្ឋាន និងការគាំទ្រដទៃទៀតដល់ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ខ្លួន។

**៣.៤.២.៣.របៀបរបបការងារ**

នៅក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការត្រូវពិនិត្យពិចារណាលើចំណុចមួយចំនួនដូចខាងក្រោមៈ

- គណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារអាចធ្វើការស្នើសុំក្រុមប្រឹក្សាខណ្ឌចំការមន ដើម្បីបង្កើតអនុគណៈកម្មាធិការ ក្រុមការងារតាមតម្រូវការនៃច្បាប់ លិខិតបទដ្ឋាននានា និងតាមការចាំបាច់

[31] ប្រការ៧នៃប្រកាសលេខ៤៦៧៥.ប្រក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ដើម្បីជួយគណៈកម្មាធិការក្នុងការសិក្សា ស្រាវជ្រាវ ឬ លើកយោបល់លើបញ្ហានានាដែលទាក់ទងនឹងភារកិច្ចរបស់ខ្លួន[32]

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារតាមរយៈក្រុមប្រឹក្សាខណ្ឌ មានសិទ្ធិអញ្ជើញប្រធាន ឬតំណាងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី ខណ្ឌ និងសង្កាត់ ប្រធានមន្ទីរ អង្គភាព ក្រុមយុវវ័យ និងកុមារដែលពាក់ព័ន្ធនឹង កិច្ចការស្ត្រី យុវវ័យ និងកុមារ ឬអ្នកពាក់ព័ន្ធផ្សេងៗទៀតចូលរួមប្រជុំដើម្បីផ្តល់ព័ត៌មានពាក់ព័ន្ធដល់គណៈកម្មាធិការនានា[33]
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានសិទ្ធិចូលរួមនៅក្នុងរាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌចំការមន គណៈកម្មាធិការនានា និងគណៈអភិបាលខណ្ឌ លើកលែងតែកិច្ចប្រជុំសម្ងាត់។ គណៈកម្មាធិការ អាចចាត់តាំងសមាជិករបស់ខ្លួនយ៉ាងច្រើនពីររូប ដើម្បីចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌចំការមន គណៈអភិបាលខណ្ឌ និងកិច្ចប្រជុំរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខណ្ឌចំការមន ។ សមាជិកដែល ចាត់តាំងទាំងនេះ មានសិទ្ធិបញ្ចេញយោបល់ក្នុងកិច្ចប្រជុំនានាដូចគ្នានឹងសមាជិកដទៃផ្សេងទៀតនៃអង្គប្រជុំដែរ។ ក្នុងករណីសមាជិក ដែលត្រូវបានចាត់តាំងឲ្យចូលរួម ក្នុងកិច្ចប្រជុំជាសមាជិកក្រុមប្រឹក្សាខណ្ឌចំការមន សមាជិកនេះមានសិទ្ធិបោះឆ្នោតអនុម័ត ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌចំការមន ក៏ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតអនុម័តនៅក្នុងកិច្ច ប្រជុំរបស់គណៈអភិបាលខណ្ឌចំការមនបានឡើយ[34]
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារត្រូវរៀបចំ និងផ្ញើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូនក្រុមប្រឹក្សា។ របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារត្រូវរួមបញ្ចូលនូវ៖
    - ស្ថានភាពរួមនៃការចូលរួមរបស់ស្ត្រី ក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យ និងស្ថានភាពរបស់កុមារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

[32] ប្រការ ៥ នៃប្រកាសលេខ៤៦៧៥.ប្រក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

[33] ប្រការ ៦ នៃប្រកាសលេខ៤៦៧៥.ប្រក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

[34] ប្រការ៩នៃប្រកាសលេខ៤២៧៥.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

  - អនុសាសន៍ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ស្ត្រីក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យ។[35]
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារត្រូវធ្វើការប្រជុំមុននឹងលើកយោបល់លើបញ្ហាណាមួយ ឬមួយចំនួនជូនក្រុមប្រឹក្សាខណ្ឌ ឬគណៈអភិបាលខណ្ឌ ។ ម្យ៉ាងវិញទៀតនៅក្នុងកិច្ចប្រជុំទាំងនេះគណៈកម្មាធិការត្រូវៈ
  - ពិនិត្យ និងអនុម័តលើផែនការសកម្មភាពប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំរបស់ក្រុមប្រឹក្សាខណ្ឌនានារបស់ក្រុមប្រឹក្សាខណ្ឌ។
  - ពិភាក្សាលើដំណើរការ និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងគោលដៅ ផែនការសកម្មភាព និងលើកជាអនុសាសន៍សម្រាប់ដោះស្រាយ
  - ពិភាក្សាលើជំហានបន្ទាប់ សម្រាប់អនុវត្តផែនការសកម្មភាពរបស់គណៈកម្មាធិការ
  - ពិនិត្យ ក៏ដូចជា ពិភាក្សាលើរបាយការណ៍ ឬកំណត់ហេតុនៃកិច្ចប្រជុំមុននឹងដាក់ជូនក្រុមប្រឹក្សាខណ្ឌ។[36]

ក្នុងករណីចាំបាច់ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារអាចរៀបចំកិច្ចប្រជុំវិសាមញ្ញបានតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ឬតាមសំណើរបស់ក្រុមប្រឹក្សាខណ្ឌចំការមន ឬតាមសំណើរបស់គណៈអភិបាលខណ្ឌឬតាមសំណើរបស់សមាជិកមួយភាគបីនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។

- រាល់កិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រី និង កុមារអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកចូលរួមលើសពាក់កណ្ដាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។ សេចក្ដីសម្រេចរបស់អង្គប្រជុំអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័ត លើសពីពាក់កណ្ដាលនៃចំនួនសមាជិកគណៈកម្មាធិការ ទាំងមូល។ នៅក្នុងករណីដែលចំនួនសំឡេងស្មើគ្នា សំឡេងរបស់ប្រធានអង្គប្រជុំ មានឧត្តមានុភាព[37]
- រាល់កិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារត្រូវបានរៀបចំជាសាធារណៈ ។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារអាចរៀបចំកិច្ចប្រជុំជាលក្ខណៈសម្ងាត់បាន។

---

[35] ប្រការ១២នៃប្រកាសលេខ៤២៧៥.ប្រក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

[36] ប្រការ១៧ នៃប្រកាសលេខ៤២៧៥.ប្រក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

[37] ប្រការ១៨ នៃប្រកាសលេខ៤២៧៥.ប្រក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានសិទ្ធិទទួលបាននូវរបៀបវារៈ និងឯកសារសម្រាប់កិច្ចប្រជុំនោះដូចសមាជិកអង្គប្រជុំដទៃទៀតដែរ។

ក្រុមប្រឹក្សខណ្ឌចំការមន គណៈអភិបាលខណ្ឌ និងគណៈកម្មាធិការដទៃទៀតត្រូវតែយកចិត្តទុកដាក់យ៉ាងខ្លាំងលើអនុសាសន៍របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងធ្វើការសម្រេចដើម្បីចាត់វិធានការក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ៣.៤.៣.គណៈកម្មាធិការលទ្ធកម្ម

គណៈកម្មាធិការលទ្ធកម្មបានបង្កើតឡើងដោយក្រុមប្រឹក្សាខណ្ឌ។[38]

គណៈកម្មាធិការលទ្ធកម្ម មានការទទួលខុសត្រូវ ដើម្បីធានាឲ្យបានថាសកម្មភាពលទ្ធកម្មទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រព្រឹត្តធ្វើឡើងប្រកបដោយភាពស្មោះត្រង់ បើកចំហ តម្លាភាព មិនលម្អៀងដោយអនុលោមតាមច្បាប់បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។[39]

គោលបំណងធំរបស់គណៈកម្មាធិការលទ្ធកម្ម គឺត្រូវការពារផលប្រយោជន៍រួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

#### ៣.៤.៣.១.ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាចំពោះលទ្ធកម្ម

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី / ខេត្ត ក្រុង / ស្រុក / ខណ្ឌមានលក្ខណៈច្បាស់លាស់ដែលថាក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ អំពីរបៀបគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុខ្លួនរួមទាំងលទ្ធកម្ម។

ដូច្នេះជាការសំខាន់ណាស់ ដែលគណៈកម្មាធិការលទ្ធកម្មរបស់ខណ្ឌត្រូវមានតម្លាភាព និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា។ បើមិនដូច្នេះទេ គណនេយ្យភាពរបស់ក្រុមប្រឹក្សាខណ្ឌចំពោះប្រជាពលរដ្ឋនឹងមិនអាចកើតមានឡើយ។

#### ៣.៤.៣.២. បញ្ហាត្រូវដោះស្រាយ

ត្រូវដាក់ចេញប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកំណត់អំពីការបង្កើតការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម។[40]

ដោយសារជាការចាំបាច់ដែលគណៈកម្មាធិការលទ្ធកម្មត្រូវមានគណនេយ្យភាពចំពោះ ក្រុមប្រឹក្សា វាជាការប្រសើរនៅក្នុងការឲ្យមានសមាជិកក្រុមប្រឹក្សាធ្វើជាសមាជិករបស់គណៈកម្មាធិការលទ្ធកម្មនេះ។

លទ្ធកម្មសាធារណៈ ត្រូវមានតម្លាភាពនោះវាក៏អាចជួយផងដែរក្នុងការឲ្យមានប្រជាពលរដ្ឋអព្យាក្រឹតម្នាក់

[38] មាត្រា៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី / ខេត្ត ក្រុង / ស្រុក / ខណ្ឌ ឆ្នាំ២០០៨

[39] មាត្រា១៣៦ នៃ ច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី / ខេត្ត ក្រុង / ស្រុក / ខណ្ឌ ឆ្នាំ២០០៨

[40] មាត្រា១៣៧ នៃ ច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី / ខេត្ត ក្រុង / ស្រុក / ខណ្ឌ ឆ្នាំ២០០៨

ឬច្រើនជាងនេះនៅក្នុងគណៈកម្មាធិការលទ្ធកម្ម ប្រការនេះនឹងផ្តល់ការអះអាងយ៉ាងខ្លាំងក្លាដែលថាក្រុមប្រឹក្សាដំណើរការទៅដោយមានតម្លាភាព និងថាក្រុមប្រឹក្សានឹងលើកកម្ពស់ការចូលរួមរបស់សាធារណជននៅក្នុងកិច្ចការទាំងអស់របស់ក្រុមប្រឹក្សា។

**បញ្ជាក់: ប្រកាសអន្តរក្រសួង លេខ:៣២៤ សហវ.ប្រក ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និង អង្គភាពលទ្ធកម្ម ចុះថ្ងៃ១ ខែមេសា ឆ្នាំ២០១៣ និង សេចក្តីណែនាំលេខ០៣៤ សណន ស្តីពីការរៀបចំបង្កើតគណៈកម្មាធិការ លទ្ធកម្ម និង អង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី / ខេត្ត ក្រុង / ស្រុក ខណ្ឌ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៣ ។**

## ៣.៥. នាយករដ្ឋបាលសាលាខណ្ឌចំការមន

ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌត្រូវមាននាយករដ្ឋបាលមួយរូបហៅថា នាយករដ្ឋបាលសាលាខណ្ឌ។[41]នាយករដ្ឋបាលសាលាខណ្ឌត្រូវចាំបាច់មាននាយករងរដ្ឋបាលសាលាខណ្ឌយ៉ាងច្រើនពីររូប ជាជំនួយការ។

នាយករដ្ឋបាលសាលាខណ្ឌចំការមន មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជាជំនួយការដល់ក្រុមប្រឹក្សាខណ្ឌចំការមន គណៈអភិបាលខណ្ឌចំការមន និងអភិបាលខណ្ឌចំការមន នៅក្នុងការការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខណ្ឌ។ នៅក្នុងការអនុវត្តតួនាទីនេះនាយករដ្ឋបាលសាលាខណ្ឌចំការមន ត្រូវ ៖
    - រៀបចំ និងដាក់ជូនគណៈអភិបាលខណ្ឌចំការមន ពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាល ប្រចាំថ្ងៃក្នុងសាលាខណ្ឌ ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលខណ្ឌ ហើយត្រូវធានាថាកិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិត បទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល
    - រៀបចំ និងដាក់ជូនគណៈអភិបាលផ្លូវការ និងគោលការណ៍ក្នុងការអនុវត្ត ដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខណ្ឌ
    - ធ្វើជាសេនាធិការជូនអភិបាលខណ្ឌ និងប្រធានក្រុមប្រឹក្សាខណ្ឌក្នុងការត្រៀម រៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខណ្ឌ រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារ និងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗ នៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខណ្ឌចំការមន ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សា។ សេចក្តីព្រាងរបៀបវារៈ ឯកសារ និងខ្លឹម

[41] មាត្រា ១០១ នៃអនុក្រឹត្យលេខ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

សារទាំងអស់ដែលនាយករដ្ឋបាលសាលាខណ្ឌចំការមន បានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាខណ្ឌត្រូវដាក់ជូនគណៈអភិបាលដើម្បីពិនិត្យ និងផ្តល់យោបល់ជាមុន លើកលែងតែមានការកំណត់ផ្សេងដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាខណ្ឌ ក្នុងការរៀបចំ និងបែងចែកលិខិត អញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និង កំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខណ្ឌ
- ត្រៀមរៀបចំកិច្ចការនានា សម្រាប់បម្រើឲ្យកិច្ចប្រជុំអស់របស់គណៈអភិបាលខណ្ឌចំការមន តាមការណែនាំរបស់អភិបាល
- ធានាក្នុងការទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវដល់ក្រុមប្រឹក្សាខណ្ឌ អភិបាលខណ្ឌ និងអភិបាលរងខណ្ឌព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាពការិយាល័យ និងអ្នកពាក់ព័ន្ធនានា
- គ្រប់គ្រង និងប្រើប្រាស់ត្រារដ្ឋបាលខណ្ឌឲ្យបានត្រឹមត្រូវតាមការកំណត់
- ធានារក្សាទុកដាក់ឲ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ លិខិតបទដ្ឋានគតិយុត្តទាំងអស់របស់ក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌចំការមន និងរដ្ឋបាលរបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌចំការមន អភិបាលខណ្ឌ ឬដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ [42]

- មានសិទ្ធិចូលរួម និងបញ្ចេញយោបល់គ្រប់កិច្ចប្រជុំក្រុមប្រឹក្សាខណ្ឌ កិច្ចប្រជុំគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាខណ្ឌចំការមន និងនៅក្នុងកិច្ចប្រជុំគណៈអភិបាលខណ្ឌ ក៏ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលសាលាខណ្ឌជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយ[43]
- នៅក្នុងការចូលរួមក្នុងកិច្ចប្រជុំ និងការអនុវត្តការងារប្រចាំថ្ងៃ នាយករដ្ឋបាល សាលាខណ្ឌអាចផ្តល់យោបល់ដល់ក្រុមប្រឹក្សាខណ្ឌ គណៈកម្មាធិការ អនុគណៈ កម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលរបស់ ខ្លួនអំពីបញ្ហាច្បាប់ និងបច្ចេកទេសដើម្បីធានាថាសេចក្តីសម្រេច និងសកម្មភាពនានារបស់ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងអភិបាលខណ្ឌមានលក្ខណៈ

[42] មាត្រា ១០៤ នៃអនុក្រឹត្យលេខ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

[43] មាត្រា ១០៥ នៃអនុក្រឹត្យលេខ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

សមស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តព្រមទាំងបទដ្ឋានជាតិសម្រាប់សុវត្ថិភាព និងគុណភាពដែលបានកំណត់ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលាខណ្ឌ[44]

- នាយករដ្ឋបាលសាលាខណ្ឌចំការមន ត្រូវធានាឲ្យការិយាល័យ មន្ត្រី បុគ្គលិកទាំងអស់អនុវត្តការងារបានត្រឹមត្រូវទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានា និងតាមការសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌចំការមន និងគណៈអភិបាលខណ្ឌចំការមនរបស់ខ្លួន។[45]

គណៈអភិបាលខណ្ឌចំការមន ឬអភិបាលខណ្ឌចំការមនអាចធ្វើប្រតិភូកម្មដល់នាយករដ្ឋបាលសាលាខណ្ឌចំការមន ឲ្យលើកយោបល់លើកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាពនៃតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាលខណ្ឌចំការមន ឬអភិបាលខណ្ឌចំការមនពិនិត្យសម្រេចតាមការចាំបាច់។

## ៣.៦.ការិយាល័យចំណុះសាលាខណ្ឌចំការមន

### ៣.៦.១.សាលាខណ្ឌចំការមន

សាលាខណ្ឌចំការមន គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌ។ ត្រូវបើកធ្វើការឲ្យបានទៀងទាត់តាមពេលម៉ោងធ្វើការរបស់រដ្ឋ។ នៅក្នុងអំឡុងពេល ម៉ោងធ្វើការងារប្រជាពលរដ្ឋមានសិទ្ធិ៖

- ធ្វើទំនាក់ទំនង និងធ្វើការងារជាមួយក្រុមប្រឹក្សាខណ្ឌ និងជាមួយគណៈអភិបាល
- ទទួលពត៌មានអំពីសំណើ និងការងារនានាពីរដ្ឋបាលខណ្ឌ
- ចូលរួមយោបល់ ឬ សំណូមពរលើបញ្ហាណាមួយ។

នៅចន្លោះម៉ោងធ្វើការ ឬថ្ងៃឈប់សម្រាកជាផ្លូវការ ក្រុមប្រឹក្សា និងគណៈអភិបាល ខណ្ឌត្រូវធានាឲ្យមានមន្ត្រី បុគ្គលិកនៃរដ្ឋបាលរបស់ខ្លួនក្នុងចំនួនសមស្របប្រចាំការដើម្បីទទួល ឬដោះស្រាយសំណូមពរបន្ទាន់ពិសេសនានា។

រដ្ឋបាលខណ្ឌចំការមននីមួយៗ ត្រូវធ្វើជាម្ចាស់ និងទទួលខុសត្រូវចាត់ចែងលើរាល់លិខិតស្នាម ឯកសារទាំងអស់ដែលបានទទួលត្រឹមត្រូវឲ្យបានស្របតាមច្បាប់ជាធរមាន។ [46] រដ្ឋបាលខណ្ឌចំការមន ក៏ជាម្ចាស់ និងទទួលខុសត្រូវលើរាល់លិខិតស្នាម ឯកសារនានាដែលបានរៀបចំឡើងដោយ ក្រុមប្រឹក្សាខណ្ឌចំការមន ឬក្នុង

[44] មាត្រា ១០៦ នៃអនុក្រឹត្យលេខ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

[45] មាត្រា ១០៧ នៃអនុក្រឹត្យលេខ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

[46] មាត្រា ១១០ នៃអនុក្រឹត្យលេខ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

នាមក្រុមប្រឹក្សាខណ្ឌ និងដោយគណៈអភិបាលខណ្ឌចំការមននៅក្នុងនាមរដ្ឋបាល ព្រមទាំងជាម្ចាស់លើ ឧបករណ៍ មធ្យោបាយ និងសម្ភារនានានៃរដ្ឋបាលរបស់ខ្លួន ។ ដូច្នេះ រដ្ឋបាលខណ្ឌចំការមនត្រូវទុកដាក់ឯកសារ លិខិតស្នាម ឧបករណ៍ មធ្យោបាយ និង សម្ភារនានា រដ្ឋបាលរបស់ខ្លួនឲ្យបានត្រឹមត្រូវតាមការកំណត់មាន សណ្តាប់ធ្នាប់ល្អ និងគង់វង្ស។

ចំពោះត្រារដ្ឋបាលខណ្ឌចំការមន ត្រូវបានប្រគល់ឱ្យនាយករដ្ឋបាលសាលាខណ្ឌរបស់ខ្លួនដើម្បី ទទួលខុសត្រូវ និងគ្រប់គ្រងសម្រាប់ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌប្រើប្រាស់។[47]

រដ្ឋបាលខណ្ឌចំការមន ត្រូវរៀបចំឲ្យមានក្តារព័ត៌មានសាធារណៈនៅមុខសាលាខណ្ឌចំការមន របស់ខ្លួន ដែលសាធារណជនអាចពិនិត្យមើលបានដោយងាយស្រួល ។ ក្តារព័ត៌មានសាធារណៈ នេះត្រូវសរសេរ ឬបិទផ្សាយសេចក្តីជូនដំណឹងជាផ្លូវការដល់សាធារណជន។ ការសរសេរ និងការបិទផ្សាយនេះត្រូវរក្សាទុកឲ្យបាន យ៉ាងតិចដប់ថ្ងៃ ក្រៅពីក្តារព័ត៌មានសារធាណៈនៅមុខ សាលាខណ្ឌចំការមន ក្រុមប្រឹក្សាខណ្ឌនីមួយៗរួមជាមួយ ក្រុមប្រឹក្សារាជធានីពិគ្រោះ ពិភាក្សាអំពីការរៀប ចំក្តារព័ត៌មានសាធារណៈនៅទីសាធារណៈដទៃទៀតក្នុងខណ្ឌ របស់ខ្លួន ដើម្បីបិទផ្សាយព័ត៌មាន រួមគ្នារវាងរាជធានី / ខណ្ឌ និង សង្កាត់ដែលពាក់ព័ន្ធ។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សាខណ្ឌចំការមន ត្រូវស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ដើម្បីជូនដំណឹងអំពីកិច្ចការ នានានៃរដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ។

សាលាខណ្ឌចំការមន ត្រូវមានការិយាល័យ និងអង្គភាពចំណុះចាំបាច់ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងបុគ្គលិក
- ការិយាល័យផែនការ និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិ.សាធារណការ ដឹកជញ្ជូន អនាម័យបរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម

[47] មាត្រា ១១២ នៃអនុក្រឹត្យលេខ២១៥.អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី

- ការិយាល័យច្រកចេញចូលតែមួយ ។[48]

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធានការិយាល័យមួយរូប និងមានអនុប្រធានយ៉ាងច្រើនពីររូបជាជំនួយការ។

### ៣.៦.១.១.ការិយាល័យរដ្ឋបាល និងបុគ្គលិក

ការិយាល័យនេះ គឺជាសេនាធិការឲ្យរដ្ឋបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម ៖

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ព័ត៌មាន ពិធីការ ទំនាក់ទំនងសាធារណៈ និងការងារសហប្រតិបត្តិការអន្តរជាតិ
- ការងារអត្រានុកូលដ្ឋាន
- ការគ្រប់គ្រង និងការថែរក្សាត្រា ឯកសារ និងលិខិតបទដ្ឋានគតិយុត្តនានា
- ការពិនិត្យ និងលើកយោបល់លើការកែសម្រួលរចនាសម្ព័ន្ធ
- ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិកតាមការផ្ទេរសិទ្ធិពីរដ្ឋបាលរាជធានី
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក
- ការងាររបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

### ៣.៦.១.២.ការិយាល័យផែនការ និងហិរញ្ញវត្ថុ

ការិយាល័យនេះ គឺជាសេនាធិការឲ្យរដ្ឋបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ការរៀបចំ និង ការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ
- ការសិក្សា ការរៀបចំ និងការអនុវត្តគម្រោងនានា
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍនានា
- ការងារស្ថិតិប្រជាជន
- ការណែនាំ និងការជំរុញការប្រមូលទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ខណ្ឌ តាមការកំណត់
- ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ខណ្ឌ
- ការងារហិញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ

---

[48] មាត្រា៧ នៃអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃ២ខែធ្នូឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

- ការងាររបាយការណ៍ហិរញ្ញវត្ថុ
- ការគាំទ្រដល់រដ្ឋបាលសង្កាត់តាមការធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**៣.៦.១.៣.អង្គភាពលទ្ធកម្ម**

អង្គភាពនេះ គឺជាសេនាធិការឲ្យរដ្ឋបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម ៖

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្តល់ឯកសារដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃការរៀបចំទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្តីពីការបើកដេញថ្លៃ
- ការរៀបចំ និងសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- ការតាមដាន ការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**៣.៦.១.៤.ការិយាល័យលេខាធិការក្រុមប្រឹក្សា**

ការិយាល័យនេះ គឺជាសេនាធិការឲ្យរដ្ឋបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ការរៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា
- ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំ
- ការរៀបចំវេទិកាផ្សព្វផ្សាយ និងការពិគ្រោះយោបល់នានា
- ការគ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារនានា
- ការបិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្តីសម្រេច និងឯកសារនានា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចពីប្រធានក្រុមប្រឹក្សា និងអភិបាល។

**៣.៦.១.៥.ការិយាល័យអប់រំ យុវជន និងកីឡា**

ការិយាល័យនេះ គឺជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា

- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមមធ្យមសិក្សាចំណេះទូទៅ
- ការអប់រំក្រៅប្រព័ន្ធ
- ការអភិវឌ្ឍន៍យុវជន
- ការអប់រំកាយ និងកីឡា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**៣.៦.១.៦.ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល**

ការិយាល័យនេះ គឺជាសេនាធិការឲ្យរដ្ឋបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ការរៀបចំដែនដី និងនគរូបនីយកម្ម
- ការងារភូមិបាល
- ការងារសំណង់
- ការងារលំនៅឋាន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**៣.៦.១.៧.ការិយាល័យនីតិកម្ម និង សម្រុះសម្រួល វិវាទមូលដ្ឋាន**

ការិយាល័យនេះ គឺជាសេនាធិការឲ្យរដ្ឋបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ការសិក្សាស្រាវជ្រាវ ការរៀបចំ និងការផ្តល់យោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា
- ការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- ការផ្តល់ប្រឹក្សាយោបល់ផ្លូវច្បាប់ដល់ប្រជាពលរដ្ឋ
- ការរៀបចំ ការបណ្តុះបណ្តាលជំនាញសម្រុះសម្រួល និងច្បាប់ដល់រដ្ឋបាលសង្កាត់
- ការទទួលពាក្យបណ្តឹង និងការសម្រុះសម្រួលវិវាទនៅមូលដ្ឋាន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌចំការមន ។

**៣.៦.១.៨.ការិ.សាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់**

ការិយាល័យនេះ គឺជាសេនាធិការឲ្យរដ្ឋបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម ៖

- ការងារសាធារណការ និងដឹកជញ្ជូន
- ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ការគ្រប់គ្រងផ្សែង សំឡេង ក្លិន និងការបំពុលបរិយាកាស
- ការដាំ ការគ្រប់គ្រង ការថែទាំដើមឈើ និងសួនច្បារសាធារណៈ

- ការគ្រប់គ្រងភ្លើងបំភ្លឺសាធារណៈ
- ការគ្រប់គ្រងចំណតយានយន្តសាធារណៈ
- ការងារសណ្តាប់ធ្នាប់សាធារណៈ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌចំការមន

**៣.៦.១.៩.ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍ**

ការិយាល័យនេះ គឺជាសេនាធិការឲ្យរដ្ឋបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម ៖

- ការងារឧស្សាហកម្ម និងសិប្បកម្ម
- ការងាររ៉ែ និងថាមពល
- ការងារទេសចរណ៍
- ការងារពាណិជ្ជកម្ម
- ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការងារធនធានទឹក
- ការងារប្រៃសណីយ៍ និងទូរគមនាគមន៍
- ការងារអភិវឌ្ឍសហគមន៍
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**៣.៦.១.១០.ការិយាល័យសង្គមកិច្ច និងសុខុមាលភាព**

ការិយាល័យនេះ គឺជាសេនាធិការឲ្យរដ្ឋបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ការងារសុខាភិបាល
- ការងារកិច្ចការនារី
- ការងារធម្មការ និងសាសនា
- ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការងារគ្រោះមហន្តរាយ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**៣.៦.១.១១.ការិយាល័យច្រកចេញចូលតែមួយ**

ការិយាល័យនេះ គឺជាសេនាធិការឲ្យរដ្ឋបាលខណ្ឌលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

- ការទទួល និង ការផ្តល់សេវារដ្ឋបាលនានាជូនប្រជាពលរដ្ឋ
- ការប្រមូល និង បង់កម្រៃសេវារដ្ឋបាលតាមគោលការណ៍ និងនីតិវិធីកំណត់
- ការផ្តល់ព័ត៌មាននានា និងការផ្សព្វផ្សាយជាសាធារណៈនូវសេវាពាក់ព័ន្ធ
- ការដាក់ទុក ការថែរក្សា និងការគ្រប់គ្រងឯកសារពាក់ព័ន្ធនានា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។
- រដ្ឋបាលរាជធានី មានតួនាទីផ្តល់អនុលោមភាព ឬពិនិត្យសម្រេចទៅលើកិច្ចការដាក់លាក់របស់រដ្ឋបាលខណ្ឌចំការមន តាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

សកម្មភាពជាក់លាក់នៃមុខងារនីមួយៗពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមវិស័យនានាអាចកំណត់បន្ថែម។ រដ្ឋបាលខណ្ឌក៏អាចកំណត់បន្ថែមនូវតួនាទី ភារកិច្ច របស់ការិយាល័យ និងអង្គភាពនីមួយៗដោយផ្អែកតាមស្ថានភាព និងតម្រូវការជាក់ស្តែងនៃខណ្ឌនីមួយៗ។

### ៣.៦.២.របៀបរបបធ្វើការងាររបស់ការិយាល័យ និងអង្គភាពចំណុះរដ្ឋបាលខណ្ឌចំការមន

ការិយាល័យ និងអង្គភាពនីមួយៗត្រូវបំពេញមុខងារស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន៖ រដ្ឋបាលខណ្ឌចំការមន ត្រូវរៀបចំឲ្យមានលក្ខខណ្ឌការងារជាក់លាក់ សម្រាប់បុគ្គលិកម្នាក់ៗរដ្ឋបាលខណ្ឌចំការមន ដោយផ្អែកតាមតួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនីមួយៗ និងគោលការណ៍ណែនាំ។

រដ្ឋបាលខណ្ឌចំការមន ត្រូវមានរៀបចំឲ្យមានលក្ខខណ្ឌការងារជាក់លាក់សម្រាប់បុគ្គលិកម្នាក់ៗរដ្ឋបាលខណ្ឌចំការមនដោយផ្អែកតាមតួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនីមួយៗ និងគោលការណ៍ណែនាំ។

រដ្ឋបាលខណ្ឌចំការមន ត្រូវមានរៀបចំឲ្យមានលក្ខខណ្ឌការងារជាក់លាក់សម្រាប់បុគ្គលិកម្នាក់ៗរដ្ឋបាលខណ្ឌចំការមនដោយផ្អែកតាមតួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនីមួយៗ និងគោលការណ៍ណែនាំ។

លក្ខខណ្ឌការងារសម្រាប់បុគ្គលិកម្នាក់ៗ ត្រូវមានការឯកភាពពីរដ្ឋបាលរាជធានី និងត្រូវបំពេញតួនាទីភារកិច្ចស្របតាមលក្ខខណ្ឌការងារកំណត់។

លក្ខខណ្ឌការងារសម្រាប់បុគ្គលិកម្នាក់ៗ ត្រូវមានការឯកភាពពីរដ្ឋបាលរាជធានី និងត្រូវបំពេញតួនាទីភារកិច្ចស្របតាមលក្ខខណ្ឌការងារកំណត់។

ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃដោយមានការសហការជាមួយក្រសួងមុខងារសាធារណៈ និងស្ថាប័នពាក់ព័ន្ធអាចផ្តល់ការណែនាំបន្ថែមអំពីការរៀបចំលក្ខខណ្ឌការងារនេះ ។

ការិយាល័យ និងអង្គភាពនីមួយៗត្រូវរៀបចំផែនការសកម្មភាព និងរបាយការណ៍ ជាទៀងទាត់តាមគោលការណ៍កំណត់ព្រមទាំងរៀបចំកិច្ចប្រជុំជាទៀងទាត់ ដើម្បីត្រួតពិនិត្យលើការងារដែលបានអនុវត្តព្រមទាំងរៀបចំកិច្ចប្រជុំជាទៀងទាត់ដើម្បីត្រួតពិនិត្យលើការងារ ដែលបានអនុវត្តកំណត់បញ្ហាប្រឈមនានាដែលត្រូវដោះ-

ស្រាយ និងកំណត់ទិសដៅដែលត្រូវអនុវត្តបន្ត។

ប្រធានការិយាល័យ និងអង្គភាពនីមួយៗត្រូវធានាថាបុគ្គលិកមកបំពេញការងារជាទៀងទាត់ អនុវត្តន៍តួនាទី ភារកិច្ចតាមលក្ខខណ្ឌការងារ គោរពបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ វិជ្ជាជីវៈដែលបានកំណត់។

ប្រធានការិយាល័យ និងអង្គភាពនីមួយៗត្រូវគ្រប់គ្រង ចាត់ចែង និងអនុវត្តការងារ ពាក់ព័ន្ធនឹងបុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងការងាររដ្ឋបាលស្របតាមនីតិវិធីរដ្ឋបាល នីតិវិធី ហិរញ្ញវត្ថុ និងលក្ខខណ្ឌការងារដែលបានកំណត់។

រដ្ឋបាលខណ្ឌចំការមន ត្រូវរៀបចំរបៀបរបបការងារលំអិតសម្រាប់ការិយាល័យ និងអង្គភាពចំណុះដើម្បីធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដោយផ្អែកតាមគោលការណ៍ដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

## ៣.៧.ទំនាក់ទំនងការងារ

### ៣.៧.១.ទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌចំការមនជាមួយរដ្ឋបាលរាជធានី

ក្រៅពីទំនាក់ទំនងដែលបានកំណត់ក្នុងតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខណ្ឌចំការមន គណៈអភិបាលខណ្ឌ រដ្ឋបាលរាជធានី និងរដ្ឋបាលខណ្ឌចំការមននៅមានទំនាក់ទំនងមួយចំនួនទៀតដូចជា៖

- រដ្ឋបាលរាជធានី មានតួនាទីផ្តល់អនុលោមភាព ឬពិនិត្យសម្រេច និងសកម្មភាពពាក់ព័ន្ធការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មទៅឲ្យរដ្ឋបាលខណ្ឌចំការមន
- រដ្ឋបាលរាជធានី មានតួនាទីផ្តល់អនុលោមភាព ឬពិនិត្យសម្រេចទៅលើកិច្ចជាក់លាក់របស់រដ្ឋបាលខណ្ឌចំការមនតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- រដ្ឋបាលរាជធានី មានតួនាទីផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ បុគ្គលិក មធ្យោបាយ សម្ភារ បច្ចេកទេស ការធ្វើអន្តរាគមន៍ និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលខណ្ឌចំការមន
- រដ្ឋបាលរាជធានី មានតួនាទីតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងការធ្វើអធិការកិច្ចលើការអនុវត្តមុខងារ និងធនធានរបស់រដ្ឋបាលខណ្ឌចំការមន
- គណៈអភិបាលរាជធានី ត្រូវធ្វើការដឹកនាំ ណែនាំ សម្របសម្រួលដល់គណៈអភិបាលខណ្ឌចំការមន ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈពត៌មាន ច្បាប់ និងសិទ្ធិមនុស្ស
- រដ្ឋបាលរាជធានី អាចពិគ្រោះយោបល់ និងធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាលើ កិច្ចការចាំបាច់មួយចំនួនជាមួយរដ្ឋបាលខណ្ឌចំការមន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍ និងការផ្តល់សេវាសាធារណៈ
- រដ្ឋបាលខណ្ឌចំការមន ត្រូវបំពេញតួនាទីជាភ្នាក់ងាររបស់រដ្ឋបាលរាជធានី និងត្រូវធ្វើរបាយការណ៍ជា

ទៀងទាត់ជូនរដ្ឋបាលរាជធានីដើម្បីបូកសរុប និងរាយការណ៍ជូនក្រសួង ស្ថាប័នតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- កិច្ចការទំនាក់ទំនងផ្សេងៗទៀត តាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងតាមតម្រូវការជាចាំបាច់ ។ [49]

### ៣.៧.២.ទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌចំការមនជាមួយរដ្ឋបាលសង្កាត់

រដ្ឋបាលខណ្ឌចំការមន និងរដ្ឋបាលសង្កាត់មានទំនាក់ទំនងគ្នាដូចខាងក្រោម ៖

- រដ្ឋបាលខណ្ឌចំការមន មានតួនាទីផ្តល់ការគាំទ្រដល់រដ្ឋបាលសង្កាត់ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងគម្រោង ឬសកម្មភាពនានាតាមការធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី
- រដ្ឋបាលខណ្ឌចំការមន អាចពិគ្រោះយោបល់ និងធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាក្នុងការអភិវឌ្ឍ និងការផ្តល់សេវាសាធារណៈជាមួយរដ្ឋបាលសង្កាត់ និងសម្របសម្រួលដោះស្រាយសំណើ សំណូមពរ និងបញ្ហានានារបស់រដ្ឋបាលសង្កាត់តាមការស្នើសុំ ឬការផ្តល់អនុសាសន៍ពីរដ្ឋបាលសង្កាត់ ឬតាមការចាំបាច់
- រដ្ឋបាលខណ្ឌចំការមន ធ្វើការសិក្សា លើកយោបល់ជូនរដ្ឋបាលរាជធានីអំពីសមត្ថភាព និងតម្រូវការគាំទ្ររបស់រដ្ឋបាលសង្កាត់
- រដ្ឋបាលខណ្ឌចំការមន មានតួនាទីតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើអធិការកិច្ចលើការអនុវត្តមុខងាររបស់រដ្ឋបាលសង្កាត់តាមការធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី
- គណៈអភិបាលខណ្ឌចំការមន ធ្វើការដឹកនាំ និងណែនាំដល់ចៅសង្កាត់ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ
- កិច្ចការទំនាក់ទំនងផ្សេងៗទៀត តាមការកំណត់នៃច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។ [50]

### ៣.៧.៣.ទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌចំការមនជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត

ទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌចំការមនជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតរួមមាន ៖

- រដ្ឋបាលខណ្ឌចំការមន អាចធ្វើការសម្របសម្រួល ការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការរួមគ្នាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតក្នុងការអនុវត្តមុខងារ គម្រោង កម្មវិធីនានា និងការដោះស្រាយតម្រូវការ និងបញ្ហាប្រឈមនានាដែល មានការពាក់ព័ន្ធតាមរយៈការរៀបចំយន្តការគ្រប់គ្រងរួមគ្នា ឬការ

[49] មាត្រា៣៣ នៃអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃ២ខែធ្នូឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

[50] មាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃ២ខែធ្នូឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

ដាក់ចេញ នូវដីកា ឬសេចក្តីសម្រេចរួមគ្នា

- រដ្ឋបាលខណ្ឌចំការមន អាចធ្វើទំនាក់ទំនងការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត ក្នុងការចែករំលែកពីគ្នាទៅវិញទៅមកនូវព័ត៌មាន ចំណេះដឹង ជំនាញ និងមេរៀនបទពិសោធន៍នានា
- កិច្ចការទំនាក់ទំនងផ្សេងៗទៀត តាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។[51]

### ៣.៧.៤.ទំនាក់ទំនងរវាងរដ្ឋបាលខណ្ឌចំការមនជាមួយ វិស័យឯកជន និងសង្គមស៊ីវិល

- រដ្ឋបាលខណ្ឌចំការមន អាចធ្វើការសម្របសម្រួល និងផ្តល់ការលើកទឹកចិត្តដល់វិស័យ ឯកជន និងសង្គមស៊ីវិលនានាក្នុងការចូលរួមរៀបចំ និងអនុវត្តន៍ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ផែនការ គម្រោង ឬកម្មវិធីនានា
- រដ្ឋបាលខណ្ឌចំការមន អាចសម្របសម្រួលក្នុងការបង្កើតឡើងនូវភាពជាដៃគូជាមួយវិស័យ ឯកជន និងសង្គមស៊ីវិលដើម្បីរួមគ្នាលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ
- រដ្ឋបាលខណ្ឌចំការមន អាចផ្តល់ការគាំទ្រដល់វិស័យឯកជន និងសង្គមស៊ីវិលនានាក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានទៅតាមលទ្ធភាពធនធាន
- រដ្ឋបាលខណ្ឌចំការមន ផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជន និងសង្គមស៊ីវិលនានាក្នុង ការផ្តួចផ្តើមលើកឡើងនូវតម្រូវការ និងសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋ
- ដើម្បីឲ្យរដ្ឋបាលខណ្ឌចំការមន ដាក់ចេញនូវដីកា ឬសេចក្តីសម្រេច ឬផ្តល់កិច្ចអន្តរាគមន៍ដោះស្រាយ
- រដ្ឋបាលខណ្ឌចំការមន រៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយ វិស័យឯកជន និងសង្គមស៊ីវិលនានាដើម្បីចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមនានា។[52]

## ៣.៨.គណនេយ្យភាព

### ៣.៨.១. គណនេយ្យភាពចំពោះប្រជាពលរដ្ឋ

រដ្ឋបាលខណ្ឌចំការមន ត្រូវមានគណនេយ្យភាពដោយផ្ទាល់ ចំពោះប្រជាពលរដ្ឋក្នុងការបំពេញតួនាទីភារកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

ក្នុងការធ្វើគណនេយ្យភាពដោយផ្ទាល់ ចំពោះប្រជាពលរដ្ឋក្នុងសមត្ថកិច្ចខ្លួន រដ្ឋបាលខណ្ឌចំការមន ត្រូវរៀបចំឲ្យមានយន្តការ មធ្យោបាយ និងនីតិវិធីនៃការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋការទទួលព័ត៌មានត្រឡប់ពី

---

[51] មាត្រា៣៦ នៃអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃ២ខែធ្នូឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

[52] មាត្រា៣៧ នៃអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃ២ខែធ្នូឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

ប្រជាពលរដ្ឋ និងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដើម្បីធានាថារាល់សេចក្តីសម្រេចនានា និងរាល់សកម្មភាព ឬទង្វើរបស់រដ្ឋបាលខណ្ឌត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព បរិយាប័ន្ន និងសមធម៌សង្គម។[53]

**៣.៨.២. គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន**

រដ្ឋបាលខណ្ឌចំការមន ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នក្នុងការបំពេញតួនាទី ភារកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងការធ្វើគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន រដ្ឋបាលខណ្ឌត្រូវ ធានាថារាល់សេចក្តីសម្រេចនានា និងរាល់សកម្មភាព ឬទង្វើរបស់រដ្ឋបាលខណ្ឌត្រូវអនុលោមទៅតាមគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវារបស់ថ្នាក់ជាតិ។

សេចក្តីសម្រេចទាំងឡាយ ដែលធ្វើឡើងមិនស្របតាមគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវណែនាំ ឬធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ដើម្បីឲ្យរដ្ឋបាលខណ្ឌកែតម្រូវ ឬលុបចោលនូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះ ។[54]

អភិបាលខណ្ឌចំការមន ត្រូវមានគណនេយ្យភាពផ្ទាល់ចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នក្នុងការអនុវត្តមុខងារដែលបានការធ្វើប្រតិភូកម្មពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន។

**៣ .៨.៣.គណនេយ្យភាពផ្ទៃក្នុង**

អភិបាល និងគណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន ការអនុវត្តដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា។

គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា និងការិយាល័យប្រជាពលរដ្ឋត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សារបស់ខ្លួន។

នាយករដ្ឋបាល ត្រូវមានគណនេយ្យភាពផ្ទាល់ចំពោះក្រុមប្រឹក្សាអភិបាល គណៈអភិបាលរបស់ខ្លួន។

ប្រធានការិយាល័យ និងប្រធានអង្គភាពត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាល។

បុគ្គលិករដ្ឋបាលខណ្ឌចំការមន ត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានការិយាល័យ និងប្រធានអង្គភាពដោយផ្ទាល់របស់ខ្លួន ក៏ដូចជាត្រូវមានគណនេយ្យភាពដោយមានភាពប្រយោលចំពោះនាយករដ្ឋបាលអភិបាល គណៈអភិបាល និងក្រុមប្រឹក្សាតាមឋានានុក្រម។

[53] មាត្រា៣៩ នៃអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃ២ខែធ្នូឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

[54] មាត្រា៤១ នៃអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃ២ខែធ្នូឆ្នាំ២០១៩ ស្តីពីមុខងារ និង រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

បញ្ជាក់ៈ គ.ជ.អ.ប ត្រូវដឹកនាំ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងរដ្ឋបាល ថ្នាក់ក្រោមជាតិក្នុងការរៀបចំនូវកិច្ចការនានាពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ បុគ្គលិក ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងកិច្ចការចាំបាច់ផ្សេងទៀត ដើម្បីធានាឱ្យរដ្ឋបាលខណ្ឌអាចចាប់ផ្តើមអនុវត្តនូវមុខងារ និងតួនាទី ភារកិច្ចរបស់ខ្លួនតាមរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងដែលបានកំណត់ក្នុងអនុក្រឹត្យ។

# ជំពូកទី៤
# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៤
# បញ្ហាប្រឈម និងដំណោះស្រាយ

រាជរដ្ឋាភិបាលទទួលស្គាល់ថា រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាថ្នាក់រដ្ឋបាលដ៏មានសារៈសំខាន់ដែលមានលទ្ធភាពចូលរួមជាមួយរាជរដ្ឋាភិបាលផ្តល់ការដោះស្រាយបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច និងបញ្ហាបរិស្ថាននានា ហេតុនេះរាជរដ្ឋាភិបាលនឹងរៀបចំផ្ទេរការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឲ្យរដ្ឋបាលទាំងនោះអាចនឹងដោះស្រាយនូវបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋ ដែលមានរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ឃុំ សង្កាត់ និងសហគមន៍មូលដ្ឋាននានានៅកម្ពុជា បាននឹងកំពុងដោះស្រាយបញ្ហាប្រឈមដែលកំពុងជួបប្រទះមានដូចជា៖ ការបង្កើតឲ្យមានក្រុមប្រឹក្សានៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សង្កាត់ គឺជាការពង្រីកថ្នាក់រដ្ឋបាលដែលប្រជាពលរដ្ឋអាចចូលរួមដោះស្រាយបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាននានាជាមួយថ្នាក់រដ្ឋបាលទាំងនេះ។

## ៤.១ បញ្ហាប្រឈម

ទោះជាយ៉ាងនេះក្តី ក៏បច្ចុប្បន្ននេះ និរន្តរភាពនៃការឆ្លើយតបនៅក្នុងការដោះស្រាយបញ្ហាប្រឈមនានានៅមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែជាបញ្ហានៅឡើយ។ ការរៀបចំបង្កើតឲ្យមានតែគោលនយោបាយ និងការផ្ទេរធនធាន គឺមិនទាន់មានលក្ខណៈគ្រប់គ្រាន់សម្រាប់ការផ្តល់សេវាមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាពនោះឡើយ។ បញ្ហានេះទាមទារឲ្យមានការរៀបចំជាបន្ថែមទៀតនូវប្រព័ន្ធ និងនីតិវិធីសម្រាប់ផ្តល់សេវាសាធារណៈដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដូច្នេះហើយថ្នាក់ជាតិត្រូវរៀបចំឲ្យមានប្រព័ន្ធ និងនីតិវិធីនានាសម្រាប់ឲ្យមន្ត្រីប្រើប្រាស់សិទ្ធិអំណាច និងធនធាននានាដែលបានផ្ទេរឲ្យដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងឆ្លើយតបទៅនឹងសេចក្តីរំពឹងទុករបស់រាជរដ្ឋាភិបាលកម្ពុជា។

ទន្ទឹមនឹងនេះរដ្ឋបាលខណ្ឌចំការមន ក៏នៅជួបប្រទះបញ្ហាប្រឈមសំខាន់ៗមួយចំនួនជាអាទិ៍ ៖

- ការអនុវត្តតួនាទី ភារកិច្ចរបស់រដ្ឋបាលរាជធានី ខណ្ឌ សង្កាត់ នៅពុំទាន់ឆ្លើយតបគណនេយ្យភាព និងតម្លាភាពស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខណ្ឌ សង្កាត់ដែលបណ្តាលមកពីការដឹកនាំនៅរដ្ឋបាលរាជធានីនៅរក្សាទម្លាប់ចាស់ពុំទាន់ឆ្លើយតបទៅនឹងបរិបទថ្មី ព្រមទាំងការបម្រើសេវាសាធារណៈនៅមានកម្រិត ពុំទាន់ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាននៅមានកម្រិតនៅឡើយ ។
- រចនាសម្ព័ន្ធរបៀបរបបការងារនៅពុំទាន់មានប្រសិទ្ធភាព។
- រចនាសម្ព័ន្ធ និងរបៀបរបបការងារនៅរដ្ឋបាលខណ្ឌ ត្រូវបានរៀបចំឡើងតាមការណែនាំនៃលិខិត

បទដ្ឋានពាក់ព័ន្ធ ក៏ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានការឆកល្វែងមួយចំនួនដែលបណ្តាលឲ្យដំណើរការការងារនៅរដ្ឋបាលខណ្ឌ ហាក់ពុំទាន់មានភាពរលូនតាមការចង់បាន។

- បញ្ហាកង្វះមន្រ្តី និងបុគ្គលិកនៅរដ្ឋបាលខណ្ឌចំការមន ក្នុងការមកបំពេញការងារពេញលេញជាប្រចាំ ក៏ដូចជា សមត្ថភាពរបស់មន្ត្រីក៏នៅមានកម្រិតនៅឡើយ ក៏ដោយសារតែពុំទាន់ទទួលបានការ បណ្តុះបណ្តាលវិជ្ជាជីវៈជំនាញសមស្របនៅឡើយ ដោយមិនទាន់និយាយដល់កង្វះការតាំងចិត្ត និងឆន្ទៈរបស់មន្ត្រីមួយចំនួនដែលអាចបណ្តាលមកពីខ្វះការលើកទឹកចិត្តទាំងផ្នែកស្មារតី និងបៀវត្សនៅមានកម្រិតជាដើម។
- បញ្ហាប្រឈមពាក់ព័ន្ធនឹងមុខងាររបស់រដ្ឋបាលខណ្ឌចំការមន ។ រហូតមកទល់ពេលនេះ មុខងារដែលបានផ្ទេរទៅរដ្ឋបាលខណ្ឌ នៅមានចំនួន និងទំហំតិចតួចនៅឡើយ ដែលមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅក្នុងមូលដ្ឋាន និងពុំអាចធ្វើឲ្យរដ្ឋបាលខណ្ឌចំការមនអាចមានលទ្ធភាពក្នុងការធ្វើគណនេយ្យភាពប្រកបដោយប្រសិទ្ធភាពចំពោះប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានបានឡើយ។
- បញ្ហាប្រឈមពាក់ព័ន្ធថវិកាខណ្ឌចំការមន។ បច្ចុប្បន្នចំណូលភាគច្រើនបំផុតរបស់រដ្ឋបាលខណ្ឌចំការមន បានមកពីមូលនិធិដែលជាថវិកាផ្ទេរពីថ្នាក់ជាតិសម្រាប់ប្រតិបត្តិការការងារ និងការអភិវឌ្ឍនៅមានកម្រិតតិចតួច និងពុំទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅក្នុងមូលដ្ឋាននៅឡើយ។ ដោយឡែក ចំណូលនៅមូលដ្ឋានដែលអាចរួមមានពន្ធមូលដ្ឋាន ក៏ដូចជា កម្រៃសេវាជាដើមនៅមានកម្រិតតិចតួចណាស់។

## ៤.២ ដំណោះស្រាយ

### ៤.២.១ ការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលខណ្ឌចំការមន

**យុទ្ធសាស្រ្តទី១** : ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធការងារក្នុង អង្គភាព និងការគ្រប់គ្រងមន្ត្រី ការរៀបចំរចនាសម្ព័ន្ធការងារត្រូវមានភាពរលូនដោយជៀសវាង ការជាន់ភារកិច្ច និងការមានចន្លោះប្រហោង ព្រមទាំងត្រូវមានការកំណត់ភារកិច្ចទទួលខុសត្រូវច្បាស់ ដើម្បីឈានទៅសម្រេចបានលទ្ធផលល្អ។ ជាមួយគ្នានោះ យន្តការគ្រប់គ្រងធនធានមនុស្សត្រូវតែឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះតម្រូវការប្រតិបត្តិការរបស់អង្គភាព ក៏ដូចជាប្រកបដោយនិរន្តរភាព។ យុទ្ធសាស្រ្តនេះតម្រូវឲ្យ៖

- ពិនិត្យឡើងវិញនូវរចនាសម្ពន្ធប្រតិបត្តិរបស់អង្គភាពស្របតាមបេសកកម្ម និងទំហំការងារ។
- រៀបចំការពិពណ៌នាមុខតំណែង ដើម្បីកំណត់ការទទួលខុសត្រូវ និងភារកិច្ចរបស់មុខតំណែងនីមួយៗក្នុងអង្គភាពឲ្យបានច្បាស់លាស់។

- ប្រគល់ភារកិច្ច និងសិទ្ធិទទួលខុសត្រូវការងារទៅតាមមុខតំណែងឲ្យបានសមស្រប។
- រៀបចំផែនការការងារប្រចាំឆ្នាំសម្រាប់អង្គភាព ដោយកំណត់ឲ្យបានច្បាស់លាស់ពីសូចនាករ និងលទ្ធផលដែលរំពឹងទុក។
- រៀបចំផែនការធនធានមនុស្សរយៈពេលខ្លី មធ្យម វែង និងការបន្តវេន

**យុទ្ធសាស្ត្រទី២** : ពង្រឹងប្រសិទ្ធភាពនៃដំណើរការអនុវត្តការគ្រប់គ្រងធនធានមនុស្ស។

ដំណើរការនៃការគ្រប់គ្រងធនធានមនុស្ស សំដៅលើការធ្វើផែនការធនធានមនុស្ស ការគ្រប់គ្រងគុណផល ការសម្រាំងដើម្បីជ្រើសរើស និងតែងតាំង ការផ្លាស់ប្តូរស្ថានភាពបុគ្គលិក ការឈប់សម្រាក វត្តមាន និងអវត្តមាន ក្រមសីលធម៌ វិន័យ ការចាកចេញពីក្របខណ្ឌមុខងារសាធារណៈ ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ។ ដំណើរការទាំងនេះ ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពដោយផ្អែកលើគុណសម្បត្តិស័ក្តិសម ភាពត្រឹមត្រូវ និងតម្លាភាព។ យុទ្ធសាស្ត្រនេះតម្រូវឲ្យ៖

- ពិនិត្យឡើងវិញ និងកែលម្អរាល់ដំណើរការការគ្រប់គ្រងធនធានមនុស្សរបស់ក្រសួង ស្ថាប័នឲ្យមានប្រសិទ្ធភាពស្របតាមគោលនយោបាយនេះ។
- ជំរុញការអនុវត្តរាល់បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព។
- កសាងបទដ្ឋានគតិយុត្តចាំបាច់មួយចំនួនបន្ថែមទៀត ដើម្បីពង្រឹងឲ្យការអនុវត្តការងារស្របតាមគោលនយោបាយនេះ។
- ធ្វើឲ្យប្រសើឡើងនូវការគ្រប់គ្រង ក្រមសីលធម៌ វិន័យ និងសមធម៌
- បង្កើតការយល់ដឹងអំពី សិទ្ធិ កាតព្វកិច្ច និងការអនុវត្តបទដ្ឋានគតិយុត្ត

### ៤.២.២ ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ

ការអភិវឌ្ឍន៍សមត្ថភាព រដ្ឋបាលខណ្ឌត្រូវអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់ខ្លួនឲ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយសីលធម៌ មនសិការវិជ្ជាជីវៈ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ការប្រើប្រាស់ឲ្យកាន់តែប្រសើរឡើងនូវសមត្ថភាពដែលមានស្រាប់ និងការអភិវឌ្ឍសមត្ថភាពការងារថ្មី តម្រូវឲ្យមានវិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធព័ត៌មានដែលអាចជឿទុកចិត្តបានស្តីពី សមត្ថភាពការងារដែលមានស្រាប់ និងតម្រូវការប្រតិបត្តិការបច្ចុប្បន្ន និងអនាគត ការរៀបចំកម្មវិធីអភិវឌ្ឍធនធានមនុស្សត្រូវតែស្ថិតក្នុងគោលដៅអភិវឌ្ឍសមត្ថភាពការងារ ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍនៃតម្រូវការប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន។ កម្មវិធីអភិវឌ្ឍធនធានមនុស្សក៏ត្រូវជំរុញនិងលើកទឹកចិត្តឲ្យមានការអភិវឌ្ឍសមត្ថភាព គ្រប់គ្រង និង

ភាពជាអ្នកដឹកនាំ ព្រមទាំងការអភិវឌ្ឍជំនាញនានាដូចជា ជំនាញបច្ចេកទេស ជំនាញបុគ្គល និងជំនាញអន្តរបុគ្គលផងដែរ។ យុទ្ធសាស្ត្រនេះតម្រូវឲ្យ៖

- រៀបចំដាក់ឲ្យមានដំណើរការ ក៏ដូចជា ធ្វើបច្ចុប្បន្នកម្មមូលដ្ឋានទិន្នន័យមន្ត្រីរាជការស៊ីវិលជាទៀងទាត់។
- រៀបចំឲ្យមានយន្តការគ្រប់គ្រងសមត្ថភាពការងារ និងការធ្វើផែនការអាជីព។
- រៀបចំប្រវត្តិសមត្ថភាពការងារសម្រាប់មុខងារអទិភាព
- វាយតម្លៃ និងវិភាគជាទៀងទាត់ទៅលើការវិវត្តនៃតម្រូវការសមត្ថភាពការងារ
- បង្កើតយន្តការកៀរគរ និងប្រើប្រាស់ធនធានចាំបាច់នានាឲ្យមានប្រសិទ្ធភាពខ្ពស់
- ធ្វើការប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍសមត្ថភាព ដើម្បីកំណត់អំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់បុគ្គល និងស្ថាប័ននៃរដ្ឋបាលខណ្ឌចំការមន
- រៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលខណ្ឌចំការមន ផ្អែកទៅតាមលទ្ធផលនៃការប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍសមត្ថភាព
- រៀបចំតាក់តែង និងផ្តល់នូវកិច្ចអន្តរាគមន៍អភិវឌ្ឍសមត្ថភាព ផ្អែកតាមផែនការអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលខណ្ឌចំការមន
- វាយតម្លៃលទ្ធផលនៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលខណ្ឌដោយផ្តោតលើការប្រើប្រាស់ចំណេះដឹងទទួលបានពីការរៀនសូត្រ និងការផ្លាស់ប្តូររបៀបរបបការងាររបស់រដ្ឋបាលខណ្ឌចំការមន

### ៤.២.៣ ការរៀបចំហិរញ្ញវត្ថុ

ក្រុមប្រឹក្សាខណ្ឌចំការមន ត្រូវគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាដល់ការបង្កើតការជំរុញ និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដោយផ្តោតលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតដូចខាងក្រោម៖

- តម្រូវការរបស់រដ្ឋបាលខណ្ឌចំការមន ក្នុងការរៀបចំសម្រាប់ទទួលមុខងារភារកិច្ចនិងធនធានថ្មីៗ
- សេវា មធ្យោបាយ សម្ភារ និងហេដ្ឋារចនាសម្ពន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់
- ការកាត់បន្ថយភាពក្រីក្រ និងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនពិការ ជនចាស់ជរា ជនក្រីក្រ ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងទៀត។
- រដ្ឋបាលថ្នាក់ជាតិត្រូវដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់មានលក្ខណៈឆ្លើយតប

និងមានប្រសិទ្ធភាពនៅរដ្ឋបាលខណ្ឌចំការមន

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើការផ្ទេរមូលនិធិមានភ្ជាប់លក្ខខណ្ឌ និងមូលនិធិគ្មានភ្ជាប់លក្ខខណ្ឌទៅឲ្យរដ្ឋបាលឲ្យបានទាន់ពេលវេលា ដោយមានការផ្តល់នូវសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការប្រើប្រាស់ និងការបែងចែកដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងមានតម្លាភាព

ក្រុមប្រឹក្សាត្រូវមានការគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាលដោយអនុវត្តតាមបទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីហិរញ្ញវត្ថុដែលបានកំណត់ជាធរមាន។

### ៤.២.៤ ការផ្តល់សេវាសាធារណៈ

ដើម្បីបង្កិតសេវាសាធារណៈឲ្យកាន់តែខិតជិតនឹងប្រជាពលរដ្ឋ នោះរដ្ឋបាលខណ្ឌចំការមន បានបង្កើតការិយាល័យច្រកចេញចូលតែមួយ នៅខណ្ឌចំការមន ដើម្បីជំរុញការអនុវត្តលើការងារបម្រើសេវា សាធារណៈជូនប្រជាពលរដ្ឋឲ្យបានកាន់តែល្អប្រសើរ និងមានតម្លាភាព ជៀសសវាងមានការថ្នាំងថ្នាក់ពីសំណាក់ប្រជាពលរដ្ឋដែលតែងតែកើតមានកន្លងមក។ ខណៈដែលការិយាល័យច្រកចេញចូលតែមួយ នៅតាមបណ្តាខណ្ឌមួយចំនួនមិនទាន់បម្រើសេវាជូនប្រជាពលរដ្ឋបានល្អប្រសើរនៅឡើយ ដែលបញ្ហានេះតម្រូវឲ្យមន្ត្រីត្រូវពិនិត្យពីការងាររបស់ខ្លួនឡើងវិញ។

ការបង្កើតឡើងនូវការិយាល័យច្រកចេញចូលតែមួយ មានគោលបំណងសំខាន់ៗដូចខាងក្រោម ៖

- លើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អ ការកែទម្រង់ប្រព័ន្ធរដ្ឋបាលដោយពង្រីកវិសាលភាពសេវាកម្មដែលផ្តល់ដោយរដ្ឋបាលឲ្យបានទូលំទូលាយតាមរយៈការប្រមូលផ្តុំសេវាកម្មទាំងអស់ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួនដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋកន្លែងតែមួយ។
- កែលម្អការផ្តល់សេវារដ្ឋបាល កាត់បន្ថយអំពើពុករលួយ និងបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋមកលើប្រព័ន្ធរដ្ឋបាល។
- លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការផ្តល់មតិយោបល់ និងផ្តល់ការរិះគន់ស្ថាបនាដើម្បីកែលម្អការអនុវត្តលើប្រព័ន្ធរដ្ឋបាល។
- បង្កិតរដ្ឋបាលឲ្យនៅកៀកជិតប្រជាពលរដ្ឋ បង្កភាពងាយស្រួលក្នុងការផ្តល់សេវាជូនដល់ប្រជាពលរដ្ឋឲ្យបានឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាព ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការបកស្រាយ និងសិក្សាខាងលើយើងសង្កេតឃើញបើគិតចាប់ពីឆ្នាំ១៩៧៩ មកដល់បច្ចុប្បន្ន ការគ្រប់គ្រងរដ្ឋបាលដែនដីមានការប្រែប្រួលចំនួន៤លើក តាមការរៀបចំរដ្ឋធម្មនុញ្ញ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលរួមមាន រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ២០០៨។ ដោយឡែកវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ២០០៨ ក៏មានការកំណត់ការបែងចែកដែនដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានីភ្នំពេញ និងខេត្ត។

ការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលខណ្ឌមានការផ្លាស់ប្តូរជាបន្តបន្ទាប់ ទៅតាមរបបនយោបាយ ហើយនឹងតាមរយៈការរៀបចំដែនដីនៅកម្ពុជាទៅតាមសម័យកាលនីមួយៗ។ រហូតមកដល់បច្ចុប្បន្ន នេះការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ ខណ្ឌ សម្រេចបាននៅសមិទ្ធផលជាច្រើនហើយក៏មានចំណុចខ្វះខាតផងដែរ។ លទ្ធផលនៃការអនុវត្តដំណើរការគ្រប់គ្រងរដ្ឋបាលខណ្ឌ នៅមិនទាន់មានភាពរលូនស្របទៅតាមគោលការណ៍របស់រដ្ឋាភិបាលនៅឡើយនោះទេ ដោយសារតែរដ្ឋបាលខណ្ឌ នៅមានភាពខ្វះខាតទៅលើ ចំណុចមួយចំនួនដូចជា (១) កត្តាធនធានហិរញ្ញវត្ថុ ដែលជាចំណុចសំខាន់មួយដោយហេតុថា កញ្ចប់ថវិកានៃការទទួលបានរបស់រដ្ឋបាលខណ្ឌនៅមានកម្រិត ដែលជួនកាលមិនអាចបំពេញនូវការអនុវត្តនៅផែនការមួយចំនួនរបស់ខ្លួនបានដោយរលូនដោយត្រូវរង់ចាំកញ្ចប់ថវិកានៃថ្នាក់ជាតិដែលនាំឲ្យមានការរាំងស្ទះដល់ការអនុវត្តគម្រោងក៏ដូចជាការដោះស្រាយបញ្ហាឲ្យទាន់ពេលវេលាផងដែរ។ (២) កត្តាធនធានមនុស្ស សមត្ថភាពមន្ត្រីរាជការដែលមានស្រាប់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ មួយចំនួននៅមានកម្រិតសិក្សាទាប និងមានគំនិតអភិរក្សដែលសម្អាងលើបទពិសោធន៍ការងារដែលខ្លួនមាននានាពេលកន្លងមកដោយមិនបានព្យាយាមអភិវឌ្ឍខ្លួនទៅតាមភាពរីកចម្រើននៃប្រទេស។ (៣) ការធ្វើប្រតិភូកម្មមុខងាររបស់ក្រសួងស្ថាប័ននៅមានកម្រិតដែលធ្វើឲ្យការផ្តល់សេវាសារធារណៈរបស់រដ្ឋបាលខណ្ឌនៅមានកម្រិត និងការផ្ទេរនូវមុខងារពុំទាន់មានភាពច្បាស់លាស់។

# អនុសាសន៍

# អនុសាសន៍

ផ្អែកលើសេចក្តីសន្និដ្ឋានខាងលើ កត្តាមួយចំនួនដែលអាចជួយបង្កើនដល់ការអភិវឌ្ឍ សមត្ថភាពរបស់ក្រុមប្រឹក្សា និងបុគ្គលិកនៃសាលាខណ្ឌចំការមន ហើយក៏ជួយជំរុញឲ្យការអនុវត្ត និងការផ្តល់នូវសេវាសាធារណៈប្រកបទៅដោយប្រសិទ្ធភាព នោះរដ្ឋាភិបាលត្រូវធ្វើកំណែទម្រង់ដូចជា៖

- ក្រសួង ស្ថាប័ន ត្រូវធានាឲ្យមាននូវ ការផ្ទេរមុខងារយ៉ាងច្បាស់លាស់ពីក្រសួង ស្ថាប័នទៅឲ្យរដ្ឋបាលថ្នាក់ខណ្ឌដោយនៅក្នុងនេះភ្ជាប់ជាមួយការផ្ទេរធនធាននានារួមទាំងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដើម្បីបង្កិតការផ្តល់សេវាឲ្យកាន់តែកៀកជិតប្រជាពលរដ្ឋ។ ដោយឡែកសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក៏ចាំបាច់ត្រូវមានការបកស្រាយឲ្យបានច្បាស់លាស់ និងពង្រឹងបន្ថែមទៀតទាំងក្នុងក្របខណ្ឌលិខិតបទដ្ឋានគតិយុត្ត ក៏ដូចជាការអនុវត្តជាក់ស្តែង។ ការប្រាស្រ័យទាក់ទងគ្នារវាងរដ្ឋបាលថ្នាក់រាជធានី រដ្ឋបាលថ្នាក់ខណ្ឌ សង្កាត់ និងអង្គភាពពាក់ព័ន្ធជាកត្តាមួយសំខាន់ជួយជំរុញឲ្យមានការអភិវឌ្ឍបានល្អប្រសើរ និងស្របតាមគោលដៅដែលរាជរដ្ឋាភិបាលចង់សម្រេចឲ្យបាន។
- មូលនិធិរាជធានី ចាំបាច់ត្រូវមានថវិកាសមស្របដើម្បីផ្តល់លទ្ធភាពក្នុងការអភិវឌ្ឍនៅក្នុងតំបន់របស់ខ្លួនតាមរយៈមុខងារនូវអាណត្តិ។ ហើយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ខណ្ឌក៏ត្រូវធ្វើការកែលម្អដើម្បីធានាការប្រើប្រាស់មូលនិធិនេះកាន់តែមានប្រសិទ្ធភាព និងតម្លាភាព។ ទន្ទឹមនឹងនេះយន្តការប្រមូលផ្ទាល់ក៏ត្រូវមានការរៀបចំកែសម្រួលផងដែរ ដែលអាចជួយឲ្យរដ្ឋបាលខណ្ឌមានចំណូលបន្ថែមដើម្បីទ្រទ្រង់គម្រោង និងការអនុវត្តកិច្ចការនានារបស់ខ្លួន។
- ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់រដ្ឋបាលខណ្ឌចំការមន គឺមានសារៈសំខាន់ណាស់ដែល រាជរដ្ឋាភិបាលអាចបង្កើតឲ្យមានមជ្ឈមណ្ឌលបណ្តុះបណ្តាល ធនធានមនុស្សនៅតាមរាជធានី ខណ្ឌ សង្កាត់ ដែលប្រមូលនូវអ្នកដែលមានសមត្ថភាពក្នុងការចូលរួមអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកនៃស្ថាប័នរបស់ខ្លួន ទាំងចំណេះដឹង ជំនាញ ការប្រើប្រាស់ព័ត៌មានវិទ្យា និងឥរិយាបថក្នុងនាមជាមន្ត្រីរាជការ រួមទាំងសមត្ថភាពជាអ្នកដឹកនាំផងដែរដើម្បីពួកគាត់មានសមត្ថភាពពេញលេញក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភា

## ឯកសារយោង

### ក. ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃ២១ ខែកញ្ញា ឆ្នាំ១៩៩៣ ប្រកាសឲ្យប្រើនៅថ្ងៃ ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យលេខ ២១៥ អនក្រ.បក ស្តីពីតួនាទីភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលរាជធានីភ្នំពេញ និង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌរាជធានីភ្នំពេញ
- អនុក្រឹត្យលេខ១៨៣ អនក្រ.បក ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ
- ប្រកាសលេខ៤២៧៥.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

### ខ. សៀវភៅ និង បទបង្ហាញ

- សៀវភៅ ការគ្រប់គ្រងរដ្ឋបាលដែនដី របស់សាស្ត្រាចារ្យ ហៀង សាង និងអនុបណ្ឌិត ប៉េង ឆុង បោះពុម្ពលើកទី៣ ឆ្នាំ២០១៨
- សៀវភៅ ស្ថាប័នរដ្ឋបាល នៃព្រះរាជាណាចក្រកម្ពុជា របស់លោក ឥន យឿន ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី បោះពុម្ពលើកទី៣ ឆ្នាំ២០១៨
- សៀវភៅ អភិបាលកិច្ចល្អ របស់ក្រសួងមហាផ្ទៃ បោះពុម្ពផ្សាយលើកទី២ ឆ្នាំ២០១០
- សៀវភៅរដ្ឋបាលសាធារណៈ សាស្ត្រាចារ្យ កេត ឧត្តម ឆ្នាំ២០១៣

### គ. គេហទំព័រ

- គេហទំព័រ ក្រសួង មុខងារសាធារណៈ ៖ http://www.mcs.gov.kh/
- _គេហទំព័រអង្គការទិន្នន័យអំពីការអភិវឌ្ឍ (https://opendevelopmentcambodia.net/km/topics/administration/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១.ឧបសម្ព័ន្ធរូបភាព

- ឧបសម្ព័ន្ធទី១ ៖ ផែនទីខណ្ឌចំការមន
- ឧបសម្ព័ន្ធទី២ ៖ ទីតាំងសំខាន់នៅក្នុងខណ្ឌចំការមន និងសោភណ្ឌភាពរបស់ខណ្ឌចំការមន
- ឧបសម្ព័ន្ធទី៣ ៖ អគាររដ្ឋបាលខណ្ឌចំការមន
- ឧបសម្ព័ន្ធទី៤ ៖ សម្ភភាពទូទៅរដ្ឋបាលខណ្ឌចំការមន

## ២.ឧបសម្ព័ន្ធគតិយុត្ត

- ឧបសម្ព័ន្ធទី១៖ ច្បាប់ ស្ដីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លេខ នស/រកម/០៥០៨/០១៧
- ឧបសម្ព័ន្ធទី២៖ អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ របស់រាជរដ្ឋាភិបាលកម្ពុជា
- ឧបសម្ព័ន្ធទី៣៖ ប្រកាសលេខ៤២៧៥.ប្រក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១៖ ផែនទីខណ្ឌចំការមន




## ឧបសម្ព័ន្ធទី២៖ ទីតាំងសំខាន់នៅក្នុងខណ្ឌចំការមន និងសោភណ្ឌភាពរបស់ខណ្ឌចំការមន




ទីតាំង៖ រដ្ឋសភាជាតិ




ទីតាំង៖ ព្រឹទ្ធសភាជាតិ



ទីតាំង៖ ក្រសួងទំនាក់ទំនង ជាមួយរដ្ឋព្រឹទ្ធសភា-
និងអធិការកិច្ច



ទីតាំង៖ ក្រសួងមហាផ្ទៃ



ទីតាំង៖សាលាភូមិន្ទរដ្ឋបាល



ទីតាំង៖ មណ្ឌលសុខភាពផ្សារដើមថ្កូវ



ទីតាំង៖  អគារ The Bridge



ទីតាំង៖ អាគារ រីវើរ៉ា



ទីតាំង៖ អាងស្តុកទឹកបឹងត្របែក



ទីតាំង៖ ស្ថានីយបូមទឹកបឹងត្របែក

## ឧបសម្ព័ន្ធទី៣៖ អគាររដ្ឋបាលខណ្ឌចំការមន



ទីតាំង៖ សាលាខណ្ឌចំការមន

## ឧបសម្ព័ន្ធទី៤៖ សម្មភាពទូទៅរដ្ឋបាលខណ្ឌចំការមន





សកម្មភាព៖ គណៈអភិបាលចុះចែកអំណោយ






សកម្មភាព៖ មន្ត្រីការិយាល័យច្រកចេញចូលតែមួយ បម្រើសេវាជូនប្រជាពលរដ្ឋ




សកម្មភាព៖ ការប្រមូលសំរាម និងការលាងសម្អាតផ្លូវក្នុងខណ្ឌចំការមន




សកម្មភាព៖ យុទ្ធនាការចុះចាក់វ៉ាក់សាំងការពារជំងឺកូវីត-១៩ ជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានខណ្ឌ




សកម្មភាព៖ ការរៀបចំប្រព័ន្ធកែលម្អលូ និងការរៀបចំប្រលាយបឹងត្របែក

# ឧបសម្ព័ន្ធគតិយុត្តិ

# ឧបសម្ព័ន្ធទី១

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៨៦/០០១/២០០៨ កបធ.ច ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរដ្ឋបាល

# រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ជំពូកទី ១

## អំពីបទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ២.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**មាត្រា ៣.-**

ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លើកលែងតែបញ្ហាទាំងឡាយណាដែលបានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.-**

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ចែកជាខណ្ឌ ។

ខណ្ឌ ចែកជាសង្កាត់ ។

**មាត្រា ៥.-**

ខេត្ត ចែកជាក្រុង និងជាស្រុក ។

ក្រុង ចែកជាសង្កាត់ ។

ស្រុក ចែកជាឃុំ និងជាសង្កាត់ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះខេត្ត ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួង

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែមានតុល្យភាពរវាងចំណូល និងចំណាយ ។

**មាត្រា ៤៥.-**

ក្នុងការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ ក្រុមប្រឹក្សាត្រូវធានាអនុវត្តតាមបទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធី ដែលបានកំណត់ទាក់ទិនទៅនឹង :

-ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា

-គណនេយ្យ និងរបាយការណ៍

-ទ្រព្យសកម្ម និងទ្រព្យអកម្ម

-តម្លាភាព និងគណនេយ្យភាព

-ការគ្រប់គ្រង :

+ ចំណូលផ្ទាល់

+ ចំណូលដែលចែករំលែក មូលនិធិផ្ទេរពីថវិកាជាតិ និងថ្លៃសេវាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារក្នុងនាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល

+ ចំណូលពីប្រភពផ្សេងៗទៀត ។

-លទ្ធកម្មសាធារណៈ

-ការធ្វើសវនកម្មផ្ទៃក្នុង

-ការធ្វើសវនកម្មផ្ទៃក្រៅ

-តម្រូវការផ្នែកហិរញ្ញវត្ថុសាធារណៈផ្សេងៗទៀត ។

បទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៦.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យ

ស្ត្រី និងកុមារ និងអនុសាសន៍ ដើម្បីពង្រឹងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

-អនុសាសន៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ស្ត្រីក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១៣៥.–**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញប្រកាសណែនាំអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារតាមការចាំបាច់ ដោយផ្អែកតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ផ្នែកទី ៤
## គណៈកម្មាធិការលទ្ធកម្ម

**មាត្រា ១៣៦.–**

គណៈកម្មាធិការលទ្ធកម្មមានសិទ្ធិ និងភារកិច្ចធានាឱ្យសកម្មភាពកិច្ចលទ្ធកម្មទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រព្រឹត្តធ្វើឡើងប្រកបដោយភាពស្មោះត្រង់ បើកចំហ តម្លាភាព មិនលំអៀង ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដើម្បីការពារផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន ។

**មាត្រា ១៣៧.–**

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ៥
## គណៈអភិបាល

**មាត្រា ១៣៨.–**

ត្រូវរៀបចំឱ្យមានគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE du PALAIS ROYAL

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានបញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភាឆ្នាំ ២០០៨.

នស/រកម.០៥០៨.០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ: ៥៥៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ជិនគេន**

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៨៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅរាជធានីភ្នំពេញ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីៈ

- មុខងារ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលខណ្ឌ
- មុខងារ តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានីភ្នំពេញ និងការធ្វើប្រតិភូកម្មមុខងារពីរដ្ឋបាលរាជធានីភ្នំពេញទៅឱ្យរដ្ឋបាលខណ្ឌ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តនៅគ្រប់រដ្ឋបាលខណ្ឌ និងរដ្ឋបាលរាជធានីភ្នំពេញ។

## ជំពូកទី២

## មុខងាររបស់រដ្ឋបាលខណ្ឌ

**មាត្រា ៤.-**

រដ្ឋបាលខណ្ឌត្រូវបំពេញមុខងារតាមការកំណត់នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមុខងារដែលបានធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានីភ្នំពេញដូចមានកំណត់ក្នុងមាត្រា៤៨នៃអនុក្រឹត្យនេះ។

ក្រៅពីមុខងារដែលបានកំណត់ក្នុងវាក្យខ័ណ្ឌទី១នៃមាត្រានេះ រដ្ឋបាលខណ្ឌបំពេញមុខងារជាភ្នាក់ងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី មន្ទីរ និងអង្គភាពនានាតាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬតាមកិច្ចព្រមព្រៀងរវាងក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី មន្ទីរ និងអង្គភាពនានាជាមួយរដ្ឋបាលខណ្ឌ។

**មាត្រា ៥.-**

រដ្ឋបាលខណ្ឌមានកាតព្វកិច្ចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានីភ្នំពេញ ដោយផ្អែកតាមគោលការណ៍ នីតិវិធី ស្តង់ដាសេវាដែលបានកំណត់ និងធនធានដែលបានផ្ទេរមានភ្ជាប់លក្ខខណ្ឌ ព្រមទាំងអាចប្រើប្រាស់ធនធានដែលគៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត ដើម្បីអនុវត្តមុខងារទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព។

គោលការណ៍ នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលត្រូវបានធ្វើប្រតិភូកម្ម ត្រូវកំណត់ដោយក្រសួង ស្ថាប័ននៃវិស័យនីមួយៗ ឬដោយរដ្ឋបាលរាជធានីភ្នំពេញ។

**មាត្រា ៦.-**

រដ្ឋបាលរាជធានីត្រូវពិនិត្យមើលឡើងវិញនូវមុខងារនានារបស់ខ្លួន ដើម្បីបន្តផ្ទេរមុខងារសមស្របទៅឱ្យរដ្ឋបាលខណ្ឌ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣

## ការបង្កើត តួនាទី ភារកិច្ច និងរបៀបរបបការងារនៃការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលខណ្ឌ

### ផ្នែកទី១

### ការបង្កើតការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលខណ្ឌ

**មាត្រា ៧.-**

រដ្ឋបាលខណ្ឌនីមួយៗត្រូវមានការិយាល័យ និងអង្គភាពមួយចំនួនជាចំណុះដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងបុគ្គលិក
- ការិយាល័យផែនការ និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយាល័យច្រកចេញចូលតែមួយ។

**មាត្រា ៨.-**

អង្គការលេខរបស់រដ្ឋបាលខណ្ឌមានកំណត់នៅក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបំពេញមុខងារ តួនាទី ភារកិច្ច របៀបរបបការងារ និងបែបបទ នីតិវិធីស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៥
## ទំនាក់ទំនងការងារ

### ផ្នែកទី១
### ទំនាក់ទំនងការងាររវាងរដ្ឋបាលខណ្ឌជាមួយរដ្ឋបាលរាជធានីភ្នំពេញ

**មាត្រា ៣២.-**

រដ្ឋបាលខណ្ឌត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់រដ្ឋបាលរាជធានីភ្នំពេញ។

**មាត្រា ៣៣.-**

ទំនាក់ទំនងការងាររវាងរដ្ឋបាលខណ្ឌជាមួយរដ្ឋបាលរាជធានីភ្នំពេញរួមមានៈ

- រដ្ឋបាលរាជធានីមានតួនាទីត្រួតពិនិត្យនីត្យានុកូលភាពលើសេចក្តីសម្រេច និងសកម្មភាពនានាពាក់ព័ន្ធនឹងការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលខណ្ឌ
- រដ្ឋបាលរាជធានីមានតួនាទីផ្តល់អនុលោមភាព ឬពិនិត្យសម្រេចទៅលើកិច្ចការជាក់លាក់មួយចំនួនរបស់រដ្ឋបាលខណ្ឌតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រដ្ឋបាលរាជធានីមានតួនាទីផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ បុគ្គលិក មធ្យោបាយ សម្ភារៈ បច្ចេកទេស ការធ្វើអន្តរាគមន៍ និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលខណ្ឌ
- រដ្ឋបាលរាជធានីមានតួនាទីតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើអធិការកិច្ចលើការអនុវត្តមុខងារ និងធនធានរបស់រដ្ឋបាលខណ្ឌ
- គណៈអភិបាលរាជធានីភ្នំពេញត្រូវធ្វើការដឹកនាំ ណែនាំ សម្របសម្រួលដល់គណៈអភិបាលខណ្ឌដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌ
- រដ្ឋបាលរាជធានីអាចពិគ្រោះយោបល់ និងធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាលើកិច្ចការចាំបាច់មួយចំនួនជាមួយរដ្ឋបាលខណ្ឌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍ និងការផ្តល់សេវាសាធារណៈ
- រដ្ឋបាលខណ្ឌបំពេញតួនាទីជាភ្នាក់ងាររបស់រដ្ឋបាលរាជធានី និងត្រូវធ្វើរបាយការណ៍ជាទៀងទាត់ជូនរដ្ឋបាលរាជធានីដើម្បីបូកសរុប និងរាយការណ៍ជូនក្រសួង ស្ថាប័ន តាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- កិច្ចការទំនាក់ទំនងផ្សេងៗទៀតតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។

## ផ្នែកទី២
## ទំនាក់ទំនងការងាររវាងរដ្ឋបាលខណ្ឌជាមួយរដ្ឋបាលសង្កាត់ក្នុងខណ្ឌ

**មាត្រា ៣៤.-**

រដ្ឋបាលសង្កាត់ និងរដ្ឋបាលខណ្ឌត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី។

រដ្ឋបាលខណ្ឌអាចផ្តល់ការគាំទ្រ និងការត្រួតពិនិត្យលើរដ្ឋបាលសង្កាត់តាមការធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី។

**មាត្រា ៣៥.-**

ទំនាក់ទំនងការងាររវាងរដ្ឋបាលខណ្ឌជាមួយរដ្ឋបាលសង្កាត់ក្នុងខណ្ឌរួមមាន៖

- រដ្ឋបាលខណ្ឌមានតួនាទីផ្តល់ការគាំទ្រដល់រដ្ឋបាលសង្កាត់ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងគម្រោង ឬសកម្មភាពនានាតាមការធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី
- រដ្ឋបាលខណ្ឌអាចពិគ្រោះយោបល់ និងធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាក្នុងការអភិវឌ្ឍ និងការផ្តល់សេវាសាធារណៈជាមួយរដ្ឋបាលសង្កាត់ និងសម្របសម្រួលដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់រដ្ឋបាលសង្កាត់ តាមការស្នើសុំ ឬការផ្តល់អនុសាសន៍ពីរដ្ឋបាលសង្កាត់ ឬតាមការចាំបាច់
- រដ្ឋបាលខណ្ឌធ្វើការសិក្សា លើកយោបល់ជូនរដ្ឋបាលរាជធានីអំពីសមត្ថភាព និងតម្រូវការគាំទ្ររបស់រដ្ឋបាលសង្កាត់
- រដ្ឋបាលខណ្ឌមានតួនាទីតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើអធិការកិច្ចលើការអនុវត្តមុខងាររបស់រដ្ឋបាលសង្កាត់តាមការធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី
- គណៈអភិបាលខណ្ឌត្រូវធ្វើការដឹកនាំ និងណែនាំដល់ចៅសង្កាត់ក្នុងខណ្ឌដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ
- កិច្ចការទំនាក់ទំនងផ្សេងៗទៀតតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។

## ផ្នែកទី៣
## ទំនាក់ទំនងការងាររវាងរដ្ឋបាលខណ្ឌជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត

**មាត្រា ៣៦.-**

ទំនាក់ទំនងការងាររវាងរដ្ឋបាលខណ្ឌជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតរួមមាន៖

- រដ្ឋបាលខណ្ឌអាចធ្វើការសម្របសម្រួល ការពិគ្រោះយោបល់ និងកិច្ចសហការរួមគ្នាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតក្នុងការអនុវត្តមុខងារ គម្រោង កម្មវិធីនានា និងការដោះ

ស្រាយតម្រូវការ និងបញ្ហាប្រឈមនានាដែលមានការពាក់ព័ន្ធគ្នាតាមរយៈការរៀបចំយន្តការគ្រប់គ្រងរួមគ្នា ឬការដាក់ចេញនូវដីកា ឬសេចក្ដីសម្រេចរួមគ្នា

- រដ្ឋបាលខណ្ឌអាចធ្វើទំនាក់ទំនងការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតក្នុងការចែករំលែកពីគ្នាទៅវិញទៅមកនូវព័ត៌មាន ចំណេះដឹង ជំនាញ និងមេរៀនបទពិសោធន៍នានា
- កិច្ចការទំនាក់ទំនងផ្សេងៗទៀតតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។

## ផ្នែកទី៤

## ទំនាក់ទំនងការងាររវាងរដ្ឋបាលខណ្ឌជាមួយវិស័យឯកជន និងសង្គមស៊ីវិល

**មាត្រា ៣៧.-**

ទំនាក់ទំនងការងាររវាងរដ្ឋបាលខណ្ឌជាមួយវិស័យឯកជន និងសង្គមស៊ីវិលនានាដែលកំពុងប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនរួមមាន៖

- រដ្ឋបាលខណ្ឌអាចធ្វើការសម្របសម្រួល និងផ្ដល់ការលើកទឹកចិត្តដល់វិស័យឯកជន និងសង្គមស៊ីវិលនានាក្នុងការចូលរួមរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការ គម្រោង ឬកម្មវិធីនានារបស់រដ្ឋបាលខណ្ឌ
- រដ្ឋបាលខណ្ឌអាចសម្របសម្រួលក្នុងការបង្កើតឡើងនូវភាពជាដៃគូជាមួយវិស័យឯកជន និងសង្គមស៊ីវិល ដើម្បីរួមគ្នាលើកកម្ពស់ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ
- រដ្ឋបាលខណ្ឌអាចផ្ដល់ការគាំទ្រដល់វិស័យឯកជន និងសង្គមស៊ីវិលនានាក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានទៅតាមលទ្ធភាពធនធានរបស់រដ្ឋបាលខណ្ឌ
- រដ្ឋបាលខណ្ឌផ្ដល់ការលើកទឹកចិត្តដល់វិស័យឯកជន និងសង្គមស៊ីវិលនានា ក្នុងការផ្ដួចផ្ដើមលើកឡើងនូវតម្រូវការ និងសំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ ដើម្បីឱ្យរដ្ឋបាលខណ្ឌដាក់ចេញនូវដីកា ឬសេចក្ដីសម្រេច ឬផ្ដល់កិច្ចអន្តរាគមន៍ដោះស្រាយ
- រដ្ឋបាលខណ្ឌត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយវិស័យឯកជន និងសង្គមស៊ីវិលនានា ដើម្បីចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមនានា។

## ជំពូកទី៦

## គណនេយ្យភាព

## ផ្នែកទី១

## គណនេយ្យភាពចំពោះប្រជាពលរដ្ឋ

**មាត្រា ៣៨.-**

រដ្ឋបាលខណ្ឌត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋក្នុងការបំពេញតួនាទីភារកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ៣៩.-**

ក្នុងការធ្វើគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រដ្ឋបាលខណ្ឌត្រូវរៀបចំឱ្យមានយន្តការ មធ្យោបាយ និងនីតិវិធីនៃការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ ការទទួលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ និងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដើម្បីធានាថារាល់សេចក្តីសម្រេចនានា និងរាល់សកម្មភាព ឬទង្វើរបស់រដ្ឋបាលខណ្ឌត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព បរិយាប័ន្ន និងសមធម៌សង្គម។

## ផ្នែកទី២

## គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានីភ្នំពេញ

**មាត្រា ៤០.-**

រដ្ឋបាលខណ្ឌត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានីភ្នំពេញក្នុងការបំពេញតួនាទី ភារកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ៤១.-**

ក្នុងការធ្វើគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌត្រូវធានាថារាល់សេចក្តីសម្រេចនានា និងរាល់សកម្មភាព ឬទង្វើរបស់រដ្ឋបាលខណ្ឌត្រូវអនុលោមទៅតាមគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវាដែលបានកំណត់។

សេចក្តីសម្រេចទាំងឡាយណារបស់រដ្ឋបាលខណ្ឌដែលធ្វើឡើងមិនស្របតាមគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងក្របខ័ណ្ឌនៃសិទ្ធិអំណាចដែលកំណត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសិទ្ធិអំណាចដែលទទួលបានពីការធ្វើប្រតិភូកម្ម សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។

រដ្ឋបាលរាជធានីភ្នំពេញត្រូវណែនាំ ឬធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ ដើម្បីឱ្យរដ្ឋបាលខណ្ឌកែតម្រូវ ឬលុបចោលនូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះ។

ក្រសួងមហាផ្ទៃត្រូវណែនាំ ឬធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ ដើម្បីឱ្យរដ្ឋបាលរាជធានីភ្នំពេញចាត់វិធានការណែនាំឱ្យរដ្ឋបាលខណ្ឌកែតម្រូវ ឬលុបចោលនូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះ។

**មាត្រា ៤២.-**

អភិបាលខណ្ឌត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័ននានា និងរដ្ឋបាលរាជធានីភ្នំពេញក្នុងការអនុវត្តមុខងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ផ្នែកទី៣

## គណនេយ្យភាពផ្ទៃក្នុង

**មាត្រា ៦៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងក្រុមប្រឹក្សាសង្កាត់នៃរាជធានីភ្នំពេញត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ចន្ទ...៦...កើត...ខែ...មិគសិរ... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២...ខែ...ធ្នូ...ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៤៤៧៥ ប្រក

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០២នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលស្រុក និងក្រុមប្រឹក្សា គណៈអភិបាលក្រុង
- យោងតាមការសម្រេចនៃអង្គប្រជុំ គ.ជ.អ.ប លើកទី៣ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហៅកាត់ថា "**គ.ក.ស.ក**"។

**ប្រការ ២.-**

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវរៀបចំឱ្យមានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ដែលមានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សា លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារ ដែលស្ថិតនៅក្នុងអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សា។

## ជំពូកទី២

## សមាសភាព រចនាសម្ព័ន្ធ និងភារកិច្ច

**ប្រការ ៣.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ត្រូវមានសមាសភាព :

| | |
|---|---|
| - សមាជិកក្រុមប្រឹក្សាជាស្ត្រី ដែលជ្រើសរើសដោយក្រុមប្រឹក្សា | ប្រធាន |
| - សមាជិកក្រុមប្រឹក្សា ដែលជ្រើសរើសដោយក្រុមប្រឹក្សា | អនុប្រធាន |
| - អភិបាលរងជាស្ត្រី ០១រូប | អនុប្រធាន |
| - ប្រធាន ឬអនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| - ប្រធាន ឬអនុប្រធានមន្ទីរកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| - នាយករងរដ្ឋបាល ០១រូប | សមាជិក |
| - ប្រធាន ឬអនុប្រធានមន្ទីរផែនការ | សមាជិក |
| - ប្រធាន ឬអនុប្រធានមន្ទីរសុខាភិបាល | សមាជិក |
| - ប្រធាន ឬអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| - ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា | សមាជិក |
| - ប្រធាន ឬអនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

- ជួយសមាជិកគណៈកម្មាធិការក្នុងការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តសកម្មភាពទាក់ទងនឹងសមភាពយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងរៀបចំរបាយការណ៍ជូនគណៈកម្មាធិការអំពីសកម្មភាពពាក់ព័ន្ធទាំងនេះ
- សហការ និងសម្របសម្រួលជាមួយនឹងសមាជិកគណៈកម្មាធិការ និងអង្គភាពពាក់ព័ន្ធរបស់ក្រុមប្រឹក្សា ដើម្បីធានាការអនុវត្តនូវសេចក្តីសម្រេចរបស់គណៈកម្មាធិការដែលបានអនុម័តដោយក្រុមប្រឹក្សាឱ្យមានប្រសិទ្ធភាព
- ចូលរួម និងសម្របសម្រួលឱ្យមានការប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលទៅក្នុងកិច្ចការរបស់គណៈកម្មាធិការ
- បំពេញរាល់កិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីប្រធាន។

**ប្រការ ១៦.-**

សមាជិកគណៈកម្មាធិការ មានតួនាទី និងភារកិច្ច :

- ចូលរួមនៅក្នុងកិច្ចប្រជុំនានារបស់គណៈកម្មាធិការ
- ផ្តល់យោបល់ និងអនុសាសន៍ទាក់ទងនឹងការលើកកម្ពស់ និងការធ្វើឱ្យមាននិរន្តរភាពនូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលពាក់ពន្ធ័នឹងសមភាពយេនឌ័រ និងបញ្ហាស្ត្រី យុវវ័យ និងកុមារ
- ចូលរួមក្នុងការប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងបញ្ហាស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលទៅក្នុងកិច្ចការរបស់គណៈកម្មាធិការ
- សម្របសម្រួល និងស្វែងរកមតិគាំទ្រដើម្បីដាក់បញ្ចូលសមភាពយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារទៅក្នុងវិស័យនីមួយៗនៃផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា
- ចូលរួមតាមដានការអនុវត្តអនុសញ្ញាអន្តរជាតិនានា ដែលរួមមានអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារនៃការទប់ស្កាត់ ការបង្ក្រាប និងការដាក់ទោសលើការជួញដូរមនុស្ស ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- ចូលរួមក្នុងដំណើរការពិនិត្យឡើងវិញ ការពិភាក្សា និងការអនុម័តដែលពាក់ពន្ធ័នឹងសេចក្តីព្រាងផែនការសកម្មភាពត្រីមាស ឆមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីការអនុវត្តការងារ ដែលទាក់ទងនឹងវិស័យនីមួយៗរបស់គណៈកម្មាធិការ
- ចូលរួមក្នុងការរៀបចំរបាយការណ៍សកម្មភាពរបស់គណៈកម្មាធិការ។

**ប្រការ ១៧.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវធ្វើការប្រជុំ មុននឹងលើកយោបល់លើបញ្ហាណាមួយ

ឬមួយចំនួនជូនក្រុមប្រឹក្សា ឬ/និងគណៈអភិបាល ។

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារត្រូវរៀបចំកិច្ចប្រជុំសាមញ្ញប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជាទៀងទាត់ ដោយភ្ជាប់ជាមួយនូវរបៀបវារៈ និងឯកសារពាក់ព័ន្ធ ។ នៅក្នុងកិច្ចប្រជុំទាំងនេះ គណៈកម្មាធិការត្រូវ :

- ពិនិត្យ និងអនុម័តលើផែនការសកម្មភាពប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ពិភាក្សាលើដំណើរការ និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងគោលដៅនៃផែនការសកម្មភាព និងលើកជាអនុសាសន៍សម្រាប់ដោះស្រាយ
- ពិភាក្សាលើជំហានបន្ទាប់សម្រាប់អនុវត្តផែនការសកម្មភាពរបស់គណៈកម្មាធិការ
- ពិនិត្យ និងពិភាក្សាលើរបាយការណ៍ ឬកំណត់ហេតុនៃកិច្ចប្រជុំ មុននឹងដាក់ជូនក្រុមប្រឹក្សា ។

ក្នុងករណីចាំបាច់ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អាចរៀបចំកិច្ចប្រជុំវិសាមញ្ញបាន តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ឬតាមសំណើរបស់ក្រុមប្រឹក្សា ឬតាមសំណើរបស់គណៈអភិបាល ឬតាមសំណើរបស់សមាជិកមួយភាគបីនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល ។

**ប្រការ ១៨.-**

រាល់កិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកចូលរួមលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល ។

សេចក្តីសម្រេចរបស់អង្គប្រជុំអាចយកជាការបាន លុះត្រាមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល ។ ក្នុងករណីដែលចំនួនសម្លេងស្មើគ្នា សម្លេងរបស់ប្រធានអង្គប្រជុំមានឧត្តមានុភាព ។

រាល់កិច្ចប្រជុំរបស់គណៈកម្មាធិការ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ ។

**ប្រការ ១៩.-**

រាល់កិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវរៀបចំជាសាធារណៈ ។

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារអាចរៀបចំកិច្ចប្រជុំជាលក្ខណៈសម្ងាត់បាន ដូចជាករណីរំលោភសេពសន្ថវៈ ការរំលោភបំពានលើកុមារ ដែលតម្រូវឱ្យមានកិច្ចការពារកិត្តិយស ឬសុវត្ថិភាពរបស់បុគ្គល ។

ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីការរៀបចំកិច្ចប្រជុំជាលក្ខណៈសម្ងាត់ខាងលើ ។

## ជំពូកទី៤

## យន្តការគាំទ្រ

**ប្រការ ២០.-**

ក្រុមប្រឹក្សាត្រូវផ្តល់ការគាំទ្រផ្នែកលេខាធិការដ្ឋាន និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ។

**ប្រការ ២១.-**

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ត្រូវជួយក្រុមប្រឹក្សារបស់ខ្លួន ក្នុងការឆ្លើយតបនឹងតម្រូវការ និងផ្តល់ការគាំទ្រនានាដល់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងបញ្ហាស្ត្រី យុវវ័យ និងកុមារនៅក្នុងឃុំ សង្កាត់នីមួយៗ ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ ២២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ២៣.-**

ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ និងអង្គភាពនានាចំណុះក្រសួងមហាផ្ទៃ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ